**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៤០៥ **អយក.ចរ**

ថ្ងៃ អង្គារ ៥រោច ខែ បុស្ស ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០២៤

**គោរពជូន**
**ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**កម្មវត្ថុ៖** ការផ្ដល់ជូនរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**យោង៖** ប្រកាសលេខ ១១៣ សហវ.ប្រក ចុះថ្ងៃ ទី ២ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំ ស្ដីពីការពិនិត្យតាមដាន និងវាយតម្លៃវិភាគសមិទ្ធកម្ម ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមគោរពជូន **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ៖ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំ របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ២០២៣ ដូចមានរបាយការណ៍ជូនភ្ជាប់ ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ ដោយសេចក្ដីអនុគ្រោះ ។

សូម **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ
- ខុទ្ទកាល័យ ឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី «ដើម្បីជូនជ្រាបជាព័ត៌មាន»
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# របាយការណ៍សមិទ្ធកម្ម

## ប្រចាំឆ្នាំ២០២៣

ខែមករា ឆ្នាំ២០២៤

| មាតិកា | ទំព័រ |
|---|---|
| **១. សេចក្តីផ្តើម** | ១ |
| **២. វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា** | ១ |
| **២.១. វឌ្ឍនភាពនៃការអនុវត្តបរិវត្តកម្មនៃវិស័យអប់រំ** | ១ |
| **២.២. វឌ្ឍនភាពនៃការអនុវត្តស្តង់ដាសាលារៀនគំរូ** | ១១ |
| **៣. វឌ្ឍភាព នៃការអនុវត្តសកម្មភាពផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២៣** | ១២ |
| **៣.១. វឌ្ឍនភាព នៃការអនុវត្តថវិកាផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៣** | ១៣ |
| **៣.២. វឌ្ឍនភាព នៃការសម្រេចបានសូចនាករប្រចាំឆ្នាំ២០២៣** | ១៤ |
| ៣.២.១ សូចនាករលទ្ធផលចុងក្រោយកម្រិតកម្មវិធី | ១៤ |
| ៣.២.២. សូចនាករលទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី | ១៥ |
| ៣.២.៣. សូចនាករលទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព | ១៦ |
| **៤. លទ្ធផលសម្រេចបានតាមកម្មវិធី និងអនុកម្មវិធី ប្រចាំឆ្នាំ២០២៣** | ១៦ |
| **៤.១. កម្មវធីទី១៖ ការអភិវឌ្ឍអប់រំចំណេះទូទៅ និងអប់រំក្រៅប្រព័ន្ធ** | ១៦ |
| អនុកម្មវិធី ១.១៖ ការពង្រីកការអប់រំកុមារតូច | ១៧ |
| អនុកម្មវិធី ១.២៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា | ១៧ |
| អនុកម្មវិធី ១.៣៖ ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំ នៅមធ្យមសិក្សា | ១៨ |
| អនុកម្មវិធី ១.៤៖ ការពង្រីកការអប់រំក្រៅប្រព័ន្ធ | ១៨ |
| អនុកម្មវិធី ១.៥៖ ការពង្រឹងនិងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា | ១៩ |
| អនុកម្មវិធី ១.៦៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស | ២០ |
| អនុកម្មវិធី ១.៧៖ ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន | ២០ |
| អនុកម្មវិធី ១.៨៖ ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារៈសិក្សា និងបណ្ណាល័យ | ២១ |
| អនុកម្មវិធី ១.៩៖ ពង្រីកការអប់រំបរិយាបន្នគ្រប់ភូមិសិក្សា | ២២ |
| អនុកម្មវិធី ១.១០៖ ការគាំទ្រអប់រំបរិយាបន្ន | ២២ |
| **៤.២. កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ** | ២៣ |
| អនុកម្មវិធី ២.១៖ ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា | ២៣ |
| អនុកម្មវិធី ២.២៖ ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា | ២៤ |
| អនុកម្មវិធី ២.៣៖ ការពង្រឹងគុណភាពអប់រំ និងស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព(សា.ភូមិន្ទភ្នំពេញ) | ២៥ |
| អនុកម្មវិធី ២.៤៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំ បណ្តុះបណ្តាលនិងស្រាវជ្រាវ ប្រកបដោយប្រសិទ្ធភាព (សា. ហេង សំរិន ត្បូងឃ្មុំ) | ២៥ |
| អនុកម្មវិធី ២.៥៖ ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ (សា. ជា ស៊ីម កំចាយមារ) | ២៥ |
| អនុកម្មវិធី ២.៦៖ ការអភិវឌ្ឍការបណ្តុះបណ្តាល និងស្រាវជ្រាវ (វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា) | ២៦ |
| អនុកម្មវិធី ២.៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការណ្តុះបណ្តាល និងស្រាវជ្រាវ (វិ.ជាតិអប់រំ) | ២៦ |
| អនុកម្មវិធី ២.៨៖ ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ (សា.ស្វាយរៀង) | ២៧ |
| អនុកម្មវិធី ២.៩៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលនិងការស្រាវជ្រាវ (សា.ជាតិមានជ័យ) | ២៨ |

| | |
|---|---|
| អនុកម្មវិធី ២.១០៖ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវ (សា.ជាតិបាត់ដំបង) | ២៨ |
| អនុកម្មវិធី ២.១៣៖ ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា (គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា) | ២៩ |
| អនុកម្មវិធី ២.១៤៖ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវលើផ្នែកបច្ចេកទេស វិជ្ជាជីវៈ និងសេវាសហគមន៍ (វិ.កំពង់ឈើទាល) | ២៩ |
| អនុកម្មវិធី ២.១៥៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ(សា.ក្រចេះ) | ៣០ |
| អនុកម្មវិធី ២.១៦៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពអប់រំ និងការស្រាវជ្រាវលើផ្នែកអប់រំបច្ចេកទេស និងវិជ្ជាជីវៈ (វិ.កំពង់ស្ពឺ) | ៣១ |
| អនុកម្មវិធី ២.១៧៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំគ្រូបង្រៀនឆ្លើយតបតាមលក្ខខណ្ឌគុណវុឌ្ឍិជាតិ (វិ.គរុកោសល្យរាជធានីភ្នំពេញ) | ៣២ |
| អនុកម្មវិធី ២.១៨៖ ពង្រឹងគុណភាពបណ្តុះបណ្តាល វិក្រឹតការគ្រូនិងការស្រាវជ្រាវស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ (វិ.គរុកោសល្យបាត់ដំបង) | ៣៣ |
| **៤.៣ កម្មវិធីទី៣៖ ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា** | ៣៣ |
| អនុកម្មវិធី ៣.១៖ ការអភិវឌ្ឍកីឡាមហាជន | ៣៤ |
| អនុកម្មវិធី ៣.២៖ ការអភិវឌ្ឍអប់រំកាយ និងកីឡាសិស្ស និស្សិត | ៣៤ |
| អនុកម្មវិធី ៣.៣៖ ការបណ្តុះបណ្តាលធនធានមនុស្សផ្នែកអប់រំកាយ និងកីឡា | ៣៥ |
| អនុកម្មវិធី ៣.៤៖ ការអភិវឌ្ឍកីឡាកម្រិតខ្ពស់ | ៣៦ |
| អនុកម្មវិធី ៣.៥៖ ការអភិវឌ្ឍការប្រកួត និងគ្រប់គ្រង ព្រឹត្តិការណ៍កីឡាគ្រប់កម្រិត | ៣៦ |
| អនុកម្មវិធី ៣.៦៖ ការអភិវឌ្ឍផ្នែកព័ត៌មាន និងស្ថិតិកីឡាគ្រប់ប្រភេទ | ៣៧ |
| **៤.៤. កម្មវធីទី ៤៖ ការអភិវឌ្ឍជំនាញបច្ចេកទេស និងជំនាញទន់សម្រាប់យុវជន** | ៣៧ |
| អនុកម្មវិធី ៤.១៖ ការអភិវឌ្ឍសកម្មភាពយុវជន | ៣៧ |
| អនុកម្មវិធី ៤.២៖ ការអភិវឌ្ឍមជ្ឈមណ្ឌលយុវជន | ៣៨ |
| អនុកម្មវិធី ៤.៣៖ ការអភិវឌ្ឍកាយរឹទ្ធិកម្ម | ៣៨ |
| **៤.៥. កម្មវធីទី ៥៖ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ** | ៣៩ |
| អនុកម្មវិធី ៥.១៖ ការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធផែនការអប់រំ | ៣៩ |
| អនុកម្មវិធី ៥.២៖ ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស | ៤០ |
| អនុកម្មវិធី ៥.៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុ ការអភិវឌ្ឍសមត្ថភាព ការគាំទ្រការលើកកម្ពស់គុណភាពអប់រំ និងមូលដ្ឋានសម្ភារៈ | ៤០ |
| អនុកម្មវិធី ៥.៤៖ ការពង្រឹងការងារសវនកម្មផ្ទៃក្នុង | ៤២ |
| អនុកម្មវិធី ៥.៥៖ ការពិនិត្យតាមដាន វាយតម្លៃ និងអធិការកិច្ចប្រព័ន្ធធានាគុណភាពអប់រំ | ៤២ |
| អនុកម្មវិធី ៥.៦៖ អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ | ៤៣ |
| អនុកម្មវិធី ៥.៧៖ លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានអប់រំ និងសហប្រតិបត្តិការអាស៊ាន-ស៊ីមេអូ | ៤៣ |
| អនុកម្មវិធី ៥.៨៖ ការពង្រឹងការងារនីតិកម្ម | ៤៤ |
| អនុកម្មវិធី ៥.៩៖ ការពង្រឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ | ៤៤ |
| អនុកម្មវិធី ៥.១០៖ ការពង្រឹងការគ្រប់គ្រងការផ្គត់ផ្គង់សម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | ៤៥ |
| អនុកម្មវិធី ៥.១១៖ ការអភិវឌ្ឍ និងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងការធានាភាពស័ក្តសិទ្ធនៃសេវារដ្ឋបាលអប់រំ | ៤៥ |

| | |
|---|---|
| អនុកម្មវិធី ៥.១២៖ ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិលើវិស័យអប់រំ | ៤៦ |
| អនុកម្មវិធី ៥.១៣៖ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | ៤៧ |
| អនុកម្មវិធី ៥.១៤៖ ការស្រាវជ្រាវ និងអភិវឌ្ឍគោលនយោបាយអប់រំ | ៤៧ |
| អនុកម្មវិធី ៥.១៥៖ ការអភិវឌ្ឍនិងពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ | ៤៨ |
| អនុកម្មវិធី ៥.១៦៖ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានសម្រាប់ការងារអប់រំ យុវជន និងកីឡា | ៤៨ |
| អនុកម្មវិធី ៥.១៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពការងារប្រឡងនៅមធ្យមសិក្សានិងអប់រំបច្ចេកទេស | ៤៩ |
| ៥.៥.១៨ ការងារមជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេស | ៥០ |
| **៥. សេចក្តីសន្និដ្ឋាន** | ៥០ |

## ១. សេចក្តីផ្តើម

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ រៀបចំឡើងឆ្លើយតបយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដោយបន្សឹទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ព្រមទាំងបានដាក់ចេញនូវវិធានការកែលម្អការគ្រប់គ្រងថវិកាឱ្យមានប្រសិទ្ធភាព ក្នុងការផ្សារភ្ជាប់រវាងលទ្ធផល និងធនធានហិរញ្ញវត្ថុ តាមរយៈការរៀបចំផែនការយុទ្ធសាស្ត្រថវិកាផ្អែកលើលទ្ធផល ការដាក់ឱ្យដំណើរការប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការរៀបចំថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការកែលម្អស្វ័យភាពនៃដំណើរការគណនេយ្យ និងការរៀបចំរបាយការណ៍សមិទ្ធកម្មថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានការពិនិត្យតាមដាន ជាទៀងទាត់នូវផលសម្រេចរបស់កម្មវិធី និងអនុកម្មវិធី ផ្អែកលើគណនេយ្យភាពថវិកាសមិទ្ធកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ២០២៣ ឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ដែលផ្តោតលើការអនុវត្តបរិវត្តកម្មនៃវិស័យអប់រំ និងស្តង់ដាសាលារៀនគំរូ ឆ្លើយតបនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ «**គណនេយ្យភាពសមិទ្ធកម្ម**» ដោយផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម។ របាយការណ៍នេះ បង្ហាញពីការវាស់វែងលទ្ធផល ធៀបនឹងសូចនាករគន្លឹះដែលបានកំណត់ និងការតាមដានវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិកា ដើម្បីឆ្ពោះទៅសម្រេចបានគោលបំណង គោលនយោបាយរបស់ក្រសួង។

## ២. វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា

### ២.១ វឌ្ឍនភាពនៃការអនុវត្តបរិវត្តកម្មនៃវិស័យអប់រំ

#### អាទិភាពទី១៖ ការបើកសាលារៀនឡើងវិញប្រកបដោយសុវត្ថិភាព ការស្តារឡើងវិញនូវការរៀនសូត្រ និងការបន្តការសិក្សារបស់សិស្ស

- ការបង្កើតគណៈកម្មការសុខភាពសិក្សានៅតាមសាលារៀន ៩ ៤៦៧សាលា
- ការផ្សព្វផ្សាយគោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមា ស្តីពីទឹក ស្អាតនិងអនាម័យ
- ការផ្សព្វផ្សាយគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សានៅគ្រឹះស្ថានសិក្សា
- ការផ្សព្វផ្សាយគោលការណ៍បរិស្ថានសាលារៀនបៃតង សាលាស្អាតគ្មានសំរាម នៅគ្រឹះស្ថានសិក្សា
- ការរៀបចំបន្ទប់សុខភាពសិក្សាតាមគ្រឹះស្ថានសិក្សា ១ ៤៦២ (សាលាមត្តេយ្យ ២៩៥ សាលាបឋមសិក្សា ៨៤៩ អនុវិទ្យាល័យ ១៧០ និងវិទ្យាល័យ ១៤៨)
- ការពិនិត្យសុខភាពនិងកាយសម្បទាគរុសិស្សបឋមសិក្សានិងមធ្យមសិក្សា ៧៩៩នាក់ ស្រី ៣០២នាក់
- ការពិនិត្យសុខភាព និងកាយសម្បទានិស្សិតនិងកម្មសិក្សាការីដាប់អាហារូបករណ៍ទៅបរទេស ៣៤៥នាក់ ស្រី១៣០
- ការពិនិត្យសុខភាពនិងកាយសម្បទាបេក្ខជនដែលដាក់ពាក្យប្រឡងចូលរៀននៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ១ ២១០នាក់
- ការវាស់គំហើញ ការពិនិត្យភ្នែក និងកាត់វ៉ែនតាជូនដល់សិស្ស និងគ្រូបង្រៀនតាមសាលារៀន ៣០០ ៧០៥នាក់ ស្រី ១០០ ៥០១នាក់
- ការបំប៉នអំពីវិជ្ជាសង្គ្រោះបឋមដល់បុគ្គលិកអប់រំ ១២០នាក់ ស្រី ៥៧នាក់
- ការពិនិត្យសុខភាពភ្នែកសិស្សានុសិស្សនៅតាមសាលារៀន ១២ ៤០០នាក់ ស្រី ១៨ ៨៥៣នាក់ ក្នុងនោះទទួលវ៉ែនតា ៧ ១៩៣នាក់ ស្រី ៤៧១នាក់
- ការពិនិត្យសុខភាពភ្នែកបុគ្គលិកអប់រំនៅតាមសាលារៀន ៣ ៧៧៦នាក់ ស្រី១ ៣១៧នាក់ ក្នុងនោះទទួលវ៉ែនតា ២ ៣៤៥នាក់
- ការពង្រឹងការអនុវត្តសៀវភៅណែនាំ ការចម្អិនអាហារសម្រាប់ចុងភៅសាលារៀន និងការអនុវត្តសេចក្តី

ណែនាំលេខ១១ អយក. សណន ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការជំរុញដំណើរការសួនសាលារៀនសម្រាប់ធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ

- ការផលិតវីដេអូស្តីពីរបៀបនៃការចម្អិនអាហារសម្រាប់សាលារៀនដែលអនុវត្តកម្មវិធីផ្តល់អាហារពេលព្រឹក ១០វីដេអូ
- ការបោះពុម្ពសៀវភៅការណែនាំនិងបណ្ណផ្ទត់ ស្តីពីការចម្អិនអាហារ ១ ២៥០ក្បាល
- ការលើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងអនាម័យ សាងសង់កន្លែងលាងដៃ និងបង្គន់អនាម័យឱ្យបានគ្រប់គ្រាន់ក្នុងនោះ៖
  - សាលាមត្តេយ្យសិក្សារដ្ឋដាច់ដោយឡែក ៩៩,៧ភាគរយ មានបង្គន់អនាម័យ ៨២,៩ភាគរយ មានកន្លែងលាងដៃ ៧៨,៧ភាគរយ មានទឹកស្អាតសម្រាប់ទទួលទានគ្រប់គ្រាន់ និង ៣៨,៤ភាគរយ មានប្រអប់សង្គ្រោះបឋម
  - សាលាបឋមសិក្សា ៩៣,៤ភាគរយ បានអនុវត្តលក្ខខណ្ឌអប្បបរមាស្តីពីទឹកស្អាត និងអនាម័យ
  - សាលាបឋមសិក្សា ១០០ភាគរយ មានបង្គន់អនាម័យ ៨៦ភាគរយ មានកន្លែងលាងសម្អាតដៃ និង ៨៣ភាគរយ មានទឹកស្អាតសម្រាប់ទទួលទាន
  - អនុវិទ្យាល័យឆ្លើយតបនឹងស្តង់ដាអប្បបរមាទឹកស្អាត អនាម័យ សម្រេចបានជារួម ៨១,៣ភាគរយ
  - វិទ្យាល័យឆ្លើយតបនឹងស្តង់ដាអប្បបរមាទឹកស្អាត អនាម័យ សម្រេចបានជារួម ៨៤,០ភាគរយ
  - អនុវិទ្យាល័យ ៩៩,៩០ភាគរយ មានបង្គន់អនាម័យ ៧៩,៥០ភាគរយ មានទឹកស្អាត ៨៤,១០ភាគរយ មានកន្លែងលាងដៃ និង ៤៥,៣០ភាគរយ មានប្រអប់សង្គ្រោះបឋម
  - វិទ្យាល័យមានបង្គន់អនាម័យ ១០០ភាគរយ ទឹកស្អាត ៨៦,៧ភាគរយ កន្លែងលាងដៃ ៨៧,៦ភាគរយ និងប្រអប់សង្គ្រោះបឋម ៧២,៥ភាគរយ
- ការអនុវត្តកម្មវិធីសាលាកុមារមេត្រីបឋមសិក្សា ៥ ៦២៦ ក្នុងនោះសាលាកុមារមេត្រីកម្រិតមធ្យម ៣ ៥៨៨ ស្មើ ៥១,០៤ ភាគរយ និងកម្រិតអភិវឌ្ឍ ២ ០៣៨ ស្មើ ២៨,៩៩ភាគរយ
- ការបោះពុម្ពសៀវភៅសិក្សាមុខវិជ្ជាអប់រំសុខភាពសម្រាប់គ្រូ ៧៨ ៦៧៨ក្បាល និងសិស្សថ្នាក់ទី១, ៤, ៥, ៦, ៧ ៨ ៩ និងថ្នាក់ ទី១០ ចំនួន ២០៥ ៥២១ក្បាល
- ការផលិតវីដេអូផ្សព្វផ្សាយស្តីពីបច្ចុប្បន្នភាពនៃជំងឺកូវីដ១៩ (ជាភាសាសញ្ញា)។

## អាទិភាពទី២៖ កំណែទម្រង់កម្រិតសាលារៀន

- ការបង្កើតក្រុមការងារអន្តរក្រសួង តាក់តែងសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងទារកដ្ឋាន តាមរយៈលិខិតលេខ ៣៩ អយក.សសរ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣
- ការអនុញ្ញាតិឱ្យក្រសួងអប់រំ យុវជន និងកីឡា សហការបន្តជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍវិស័យឯកជន និងសហគមន៍ ដើម្បីជំរុញការរៀបចំ និងដំណើរការទារកដ្ឋាន សហគមន៍ រោងចក្រ សហគ្រាស តាមរយៈលិខិតលេខ១៣១៩ សជណ. អវ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២៣
- ការបើកមត្តេយ្យសិក្សានៅក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ តាមរយៈប្រកាសលេខ ៧៨៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣
- ការប្រែក្លាយថ្នាក់មត្តេយ្យសិក្សាសហគមន៍ទៅជាឧបសម្ព័ន្ធគ្រឹះស្ថានមត្តេយ្យសិក្សា ឬបឋមសិក្សាសាធារណៈ តាមរយៈប្រកាសលេខ ៨៧៤ អយក.ប្រក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២
- ការជ្រើសរើសបណ្តុះបណ្តាលគ្រូបង្រៀនមត្តេយ្យសិក្សា១២+២ ថ្នាក់បង់ថ្លៃសិក្សា ៣០នាក់
- ការណែនាំវិធីសាស្ត្របង្រៀនកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូងថ្នាក់ទី១ និងវិធីសាស្ត្របង្រៀន និងការប្រើ

ប្រាស់កញ្ចប់សម្ភារៈគណិតវិទ្យា សម្រាប់បំប៉នគ្រូឧទ្ទេសថ្នាក់ជាតិ ដើម្បីបំប៉នបន្តដល់គ្រូបង្រៀនថ្នាក់ទី១
- ការផលិតវីដេអូបង្រៀនសម្រាប់គណិតវិទ្យាថ្នាក់ទី១ ដល់ទី៦
- ការផលិតវីដេអូជាលក្ខណៈតុក្កតាបម្រើឱ្យការបង្រៀនស្រៈ ព្យញ្ជនៈ និងនិទានរឿង ១៥៩ឃ្លីប
- ការបំប៉នសមត្ថភាពនាយក នាយិកា ៥៨១ នាក់ ស្រី ១១៣នាក់ ស្តីពីកញ្ចប់សម្ភារៈគណិតវិទ្យាថ្នាក់ទី១
- ការបំប៉នសមត្ថភាពគ្រូបង្រៀនថ្នាក់ទី១ ចំនួន ២ ១៤៥នាក់ ស្រី ១ ២៩១នាក់ និងគ្រូថ្នាក់ទី២ ចំនួន ៤ ៧៧៩នាក់ ស្រី ២ ២៧៩នាក់ ស្តីពីកញ្ចប់សម្ភារៈគណិតវិទ្យាថ្នាក់ទី១ និងទី២
- ការបំប៉នកម្មវិធីប្រឹក្សាគរុកោសល្យដល់ទីប្រឹក្សាជំនាញ ទីប្រឹក្សាប្រចាំសាលារៀន ៧៦៣នាក់ ស្រី ៣៧២នាក់
- ការណែនាំការប្រើប្រាស់ប្រព័ន្ធកូបូសម្រាប់កម្មវិធីប្រឹក្សាគរុកោសល្យ ដល់ទីប្រឹក្សាគរុកោសល្យ ប្រធានកម្រង ១ ៤៤៨ នាក់ ស្រី ៦៨៩ នាក់
- ការផលិតវីដេអូបង្រៀនជាភាសាសញ្ញាដើម្បីចែកជូនដល់វិទ្យាល័យអប់រំពិសេស
- ការអភិវឌ្ឍ និងចងក្រងឯកសារណែនាំស្តីពីវង្វាយតម្លៃអំណានតំបូងសម្រាប់សិស្សពិការភ្នែក និងគថ្លង់
- ការអនុវត្តប្រព័ន្ធព័ត៌មានសាលារៀននៅមធ្យមសិក្សាកម្ពុជា(SIS)
- ការវាយតម្លៃសាលាមត្តេយ្យសិក្សាសាធារណៈ ១០ ត្រូវបានទទួលស្គាល់ជាសាលារៀនដែលទទួលបានការគាំទ្របន្ថែមក្នុងការអភិវឌ្ឍសាលារៀន តាមរយៈប្រកាសលេខ ៦៦៩ អយក.ប្រក. ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣
- ការវាយតម្លៃជ្រើសរើសគ្រូបង្រៀនល្អភាសាខ្មែរថ្នាក់ទី១ ទី២ និងទី៣
- ការវាយតម្លៃជ្រើសរើសគ្រូល្អ សាលារៀនល្អ នាយកល្អ នឹងអនុវត្តរៀងរាល់ចុងឆ្នាំសិក្សានីមួយៗ
- សាលារៀនជំនាន់ថ្មីកម្រិតមធ្យមសិក្សាមាន៧ និងពង្រីកបន្ថែម២ នៅវិទ្យាល័យព្រះអង្គឌួង ខេត្តព្រៃវែង និងអនុវិទ្យាល័យអរញ្ញរង្សី ខេត្តសៀមរាប
- សាលារៀនជំនាន់ថ្មី មានស្វ័យភាពក្នុងការអនុវត្តកម្មវិធីសិក្សាជាតិ ៤០ ទៅ ៤៣ម៉ោង ក្នុង១សប្តាហ៍ និងការអប់រំស្នែម ICT Coding ការរៀនបែបគម្រោង ការសិក្សាបែបស្ពានិយម
- ការផ្សព្វផ្សាយដាក់ឱ្យអនុវត្តស្តង់ដាសាលាគំរូ គ្រប់កម្រិតសិក្សា
- ការជ្រើសរើសសាលាមត្តេយ្យសិក្សាសាធារណៈ ៣១ សាលាបឋមសិក្សា ១៥០ ដើម្បីផ្តល់ថវិកាបង្វិក ឬមូលនិធិដំណើរការសាលារៀនបន្ថែសម្រាប់អនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនឱ្យសម្រេចស្តង់ដាអប្បបរមាសាលារៀនមានប្រសិទ្ធភាព
- ការធ្វើបច្ចុប្បន្នកម្មបញ្ញត្តិនៃការធានានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ ឱ្យស្របតាមកំណែទម្រង់អប់រំ បរិវត្តន៍កម្មអប់រំ ការអប់រំឌីជីថល
- ការផ្សព្វផ្សាយលទ្ធផលរបាយការណ៍អធិការកិច្ចតាមប្រធានបទ«ការបង្រៀន និងរៀនសំណេរថ្នាក់ទី៥» និងអធិការកិច្ចសាលារៀនតាមកាលកំណត់របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ការធ្វើអធិការកិច្ចតាមកាលកំណត់ ៨៧សាលា ក្នុងនោះសាលាបឋមសិក្សា ៤៤ អនុវិទ្យាល័យ ២៦សាលា និងវិទ្យាល័យ ១៧
- ការធ្វើអធិការកិច្ចតាមប្រធានបទស្តីពីការអនុវត្តកម្មវិធីសិក្សាលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី៨ ៨៦សាលា
- ការកសាងឧបករណ៍អធិការកិច្ចតាមប្រធានបទ
- ការបំប៉នសមត្ថភាពស្តីពីការលើកកម្ពស់ការអប់រំបរិយាបន្ន ការចូលរួមរបស់សហគមន៍ក្នុងការតាមដានការរៀន និងបង្រៀនកម្រិតថ្នាក់ដំបូង និងកម្មវិធីជួយកុមាររៀនបន្ថែមនៅផ្ទះ

- ការរៀបចំកម្មវិធីជួយសិស្សរៀនយឺត ដោយផ្តោតលើលទ្ធផលតេស្តដើមឆ្នាំ ខែ ត្រីមាស និងឆមាស
- ការបង្កើតកញ្ចប់សិក្សាជួយសិស្សរៀនយឺត ដែលរួមមានតេស្តវាយតម្លៃ និងខ្លឹមសារមេរៀនដែលត្រូវជួយសិស្សបន្ថែមនៅថ្ងៃព្រហស្បតិ៍
- ការរៀបចំកម្រងកិច្ចការផ្ទះភាសាខ្មែរ និងគណិតវិទ្យាកម្រិតថ្នាក់ទី១ ដល់ ទី៦
- ការបំប៉នសមត្ថភាពស្តីពីការគ្រប់គ្រងតាមសាលារៀន SBM ដល់នាយកសាលា និងគ្រូបង្រៀន ២ ០០០នាក់
- ការអនុវត្តតេស្តវាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី១១ លើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា
- ការអនុវត្តតេស្តសមត្ថភាពកុមារ និងមាតាបិតា សាលាមត្តេយ្យសិក្សាសាធារណៈចំនួន ២១៣សាលា
- ការផ្តល់ព័ត៌មានដល់មាតាបិតានិងសហគមន៍ តាមរយៈការពិនិត្យតាមដានប្រចាំខែ និងត្រីមាសដោយផ្តោតលើលទ្ធផលសិក្សារបស់សិស្សម្នាក់ៗ
- ការវាយតម្លៃមជ្ឈមណ្ឌលសិក្សាសហគមន៍ ៦ខេត្ត ដើម្បីប្រែក្លាយទៅជាមជ្ឈមណ្ឌលសិក្សាសហគមន៍គំរូ រួមមានខេត្តបន្ទាយមានជ័យ ក្រចេះ កំពត ព្រះសីហនុ បាត់ដំបង និងស្វាយរៀង
- ការផ្តល់សញ្ញាបត្របំពេញវិជ្ជាដល់បេក្ខជន ៣៦៣នាក់ ដែលប្រឡងជាប់កាលពីឆ្នាំ២០០៦
- ការអនុវត្តកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (ប៊ីប) នៅខេត្តត្បូងឃ្មុំ បាត់ដំបង កណ្តាល និងរាជធានីភ្នំពេញ
- ការប្រែក្លាយ ឬបង្កើតមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ៣១
- ការរៀបចំក្របខណ្ឌវាយតម្លៃស្ថានភាពដំណើរការរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍។

**អាទិភាពទី៣៖ ការអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាពខ្ពស់ តាមរយៈកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ**

- ការស្នើសុំឋានៈសាស្ត្រាចារ្យឧត្តម ២នាក់ និងសាស្ត្រាចារ្យរងឧត្តម ១នាក់ និងសាស្ត្រាចារ្យជំនួយឧត្តម ១០នាក់ ជូនវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ
- ការអភិវឌ្ឍក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន
- ការពិនិត្យឡើងវិញកម្មវិធីបណ្តុះបណ្តាលសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម
- ការកែលម្អកម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធក្រេឌីដ
- ការអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេស និងគណៈគ្រប់គ្រងលើ ១១ប្រធានបទ រួមមាន ១. ការសិក្សាសម្រាប់មនុស្សពេញ វ័យ, ២. អំណានវិជ្ជាជីវៈ, ៣. ចំណេះខ្លឹមសារគរុកោសល្យ និងបច្ចេកវិទ្យា, ៤. គរុកោសល្យសិស្សមជ្ឈមណ្ឌល, ៥. ចំណេះដឹងខ្លឹមសារគរុកោសល្យ, ៦. ការស្រាវជ្រាវប្រតិបត្តិ, ៧. កម្មវិធីប្រឹក្សាគរុកោសល្យ, ៨. ភាពជាអ្នកដឹកនាំ៖ គោលនយោបាយ និង ការគ្រប់គ្រង, ៩. ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស, ១០. ការកែលម្អកម្មវិធីបណ្តុះបណ្តាល និង ១១. ភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំ
- ការអភិវឌ្ឍសៀវភៅមុខវិជ្ជា៖ ការអភិវឌ្ឍភាពជាអ្នកដឹកនាំក្នុងកម្រិតមូលដ្ឋាន, ការធ្វើសេចក្តីសម្រេចចិត្តក្នុងភាពជាអ្នកដឹកនាំឱ្យមានប្រសិទ្ធភាព, ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅកន្លែងធ្វើការ, ការធ្វើបទបង្ហាញ/ជំនាញនិយាយជាសាធារណ, សមភាពយេនឌ័រនិងបរិយាបន្នសង្គម, ការផ្តល់ប្រឹក្សានៅកន្លែងធ្វើការ
- ការបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍភាពជាអ្នកដឹកនាំកម្រិត៖ L1/L2 អគ្គនាយក/អគ្គនាយករង និងប្រធាន/អនុប្រធាននាយកដ្ឋាន ២៦នាក់ ស្រី ៩នាក់ ក្នុងនោះបញ្ចប់ដោយជោគជ័យទទួលបាន ១ក្រេឌីតអវប ២២នាក់ ស្រី៩នាក់, កម្រិត L3 ប្រធាន/អនុប្រធានការិយាល័យ ៥០នាក់ ស្រី ២៣នាក់ ក្នុងនោះបញ្ចប់ដោយជោគជ័យទទួលបាន ១ក្រេឌីតអវប ៣៩នាក់ ស្រី ២០នាក់, បុគ្គលិកមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ខេត្តតាកែវ និងខេត្តព្រះសីហនុ ២៥នាក់ ស្រី ២៤នាក់ ក្នុងនោះបញ្ចប់ដោយជោគជ័យទទួលបាន ១ក្រេឌីតអវប ២៤នាក់ ស្រី២៣នាក់
- ការអនុវត្តកម្មវិធីសរសេរកូដក្រៅកម្មវិធីសិក្សាTec novation និង Sister of Code, និងកំពុងអនុវត្តកម្មវិធី

សរសេរកូដនៅតាមសាលាបំណិនជីវិតមូលដ្ឋាន

- ការអនុម័តឯកសារណែនាំការអនុវត្ត STEM ៥មុខវិជ្ជាគណិតវិទ្យា ជីវវិទ្យា គីមីវិទ្យា រូបវិទ្យា ផែនដីនិងបរិស្ថានវិទ្យា
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ និងគ្រូគណិតវិទ្យា និងវិទ្យាសាស្ត្រ នៅតាមសាលាជនជាន និងបណ្តាញលើមុខវិជ្ជាគណិត វិទ្យា ជីវវិទ្យា គីមីវិទ្យា រូបវិទ្យា ផែនដីនិបរិស្ថានវិទ្យា
- ការសាងសង់ និងបំពាក់សម្ភារបរិក្ខារអគារទោរកដ្ឋាន សហគមន៍ រោងចក្រ សហគ្រាស ១៣កន្លែង
- ការសាងសង់អគារសិក្សា និងបំពាក់បរិក្ខារមត្តេយ្យសិក្សាសហគមន៍ ១០០កន្លែង នៅខេត្តកំពត ៣៤កន្លែង កំពង់ស្ពឺ ៣៤កន្លែង ព្រះសីហនុ ១៦កន្លែង ពោធិ៍សាត់ ១៦កន្លែង
- ការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍តាមស្តង់ដា ៣៥ថ្ងៃ ១០០នាក់ នៅខេត្តកំពត ៣៤នាក់ កំពង់ស្ពឺ ៣៤នាក់ ព្រះសីហនុ ១៦នាក់ ពោធិ៍សាត់ ១៦នាក់
- ការផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តឯកសារកញ្ចប់អប់រំមាតាបិតាស្តីពីការចិញ្ចឹមបីបាច់កុមារតូចរយៈពេល ១០០០ថ្ងៃដំបូង
- ការបើកថ្នាក់អប់រំពហុភាសាសម្រាប់មត្តេយ្យសិក្សា១៣៣កន្លែង ក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ និងព្រះវិហារ
- ការបំប៉នសមត្ថភាពគ្រូស្តីពីការអប់រំបរិយាបន្នសម្រាប់មត្តេយ្យសិក្សា ១៣២នាក់ ស្រី ១២៥នាក់ ក្នុងខេត្តរតនគិរី និងខេត្តក្រចេះ
- ការបំប៉នសមត្ថភាពគ្រូបង្គោល ស្តីពីការប្រើប្រាស់កញ្ចប់ឯកសារបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាអប់រំពហុភាសា ៧២នាក់ ស្រី ៣៤នាក់ នៅខេត្តកំពង់ចាម
- ការបំប៉នសមត្ថភាគ្រូមត្តេយ្យសិក្សាអប់រំពហុភាសាស្តីពីវិធីសាស្ត្របង្រៀន និងភាសាកំណើតដែលមានអ្នកចូលរួម ១១៧នាក់ ស្រី ៨៤នាក់
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសដោយបញ្ជូនទៅសិក្សានៅក្រៅប្រទេស និងស្វែងរកអ្នកជំនាញពីក្រៅប្រទេសមក បណ្តុះបណ្តាលដល់វិទ្យាស្ថានជាតិអប់រំពិសេស
- ការផលិតសម្ភារសិក្សា និងអនុវត្តល្បែងសិក្សាអប់រំបរិយាបន្នសម្រាប់មត្តេយ្យសិក្សា
- ការអនុវត្តសាកល្បងប្រព័ន្ធ អ.រ.ប. និងHRMIS នៅសាលាបឋមសិក្សា ១០០
- ការទទួលស្គាល់គ្រឹះស្ថានបណ្តុះបណ្តាល (Provider) ចំនួន ៣គ្រឹះស្ថាន
- គ្រូបង្រៀននិងនាយកសាលា ៦ ៦៥៩នាក់ ទទួលបានក្រេឌីត CPD និងត្រៀមវាយតម្លៃចូលគន្លងអាជីពគ្រូបង្រៀន
- ការវាយតម្លៃជានាយកល្អ ២១នាក់ និងគ្រូបង្រៀនល្អ ៨០នាក់
- ការអនុវត្តកញ្ចប់សម្ភារអំណាន និងគណិតវិទ្យាថ្នាក់ដំបូងនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន, បំប៉នសមត្ថភាពស្តីពី ការប្រើប្រាស់កញ្ចប់សម្ភារអំណាន និងគណិតវិទ្យាថ្នាក់ដំបូងជូនគ្រូបង្រៀននៅតាមសាលាសហការ
- ការបន្តបំប៉នគ្រូទទួលបន្ទុកមុខវិជ្ជាអប់រំសុខភាពគ្រប់កម្រិតថ្នាក់ លើមុខវិជ្ជាអប់រំសុខភាព
- ការផ្សព្វផ្សាយ ស្តីពីការប្រើប្រាស់សៀវភៅថែទាំសុខភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន ៧៦នាក់ ស្រី ២០នាក់ មកពីសាលាបឋមសិក្សា ៣៦
- ការបំប៉នស្តីពីការប្រើប្រាស់គោលការណ៍ណែនាំប្រតិបត្តិស្តីពីការសង្គ្រោះផ្លូវចិត្តបឋមនៅតាមគ្រឹះស្ថានសិក្សា ដល់គ្រូបង្រៀនសាលាបឋមសិក្សា ៩០១នាក់ ស្រី ៣៩៤នាក់
- ការផ្សព្វផ្សាយអប់រំស្តីពីការអប់រំបង្ការការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ផលិតផលថ្នាំជក់បារីអេឡិចត្រូ

និក និងការបង្ការមេរោគអេដស៍ ជំងឺអេដស៍ និងការបង្ការគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកដល់ក្រុមប្រឹក្សាយុវជន យុវជនកាកបាទក្រហម និងយុវជនកាយរិទ្ធ ៣ ៦៨៧នាក់ ស្រី ២ ០៦២នាក់

- ការផ្សព្វផ្សាយពីការបង្ការការប្រើប្រាស់ផលិតផលថ្នាំជក់បារី អេឡិចត្រូនិចគ្រឿងញៀនខុសច្បាប់ មេរោគអេដស៍ គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក និងចំណីអាហារផ្សេងៗ និងបានអនុវត្តគ្រប់សាលាបឋមសិក្សាសាធារណៈ និងឯកជន
- ការធ្វើតម្រូវការសៀវភៅសិក្សាគោលតាមប្រព័ន្ធ TnT (Track and Trace)
- ការផ្គត់ផ្គង់សៀវភៅសិក្សាគោលគ្រប់កម្រិតថ្នាក់ ៥ ៣៥៣ ០០០ ក្បាល
- សាលាបឋមសិក្សាមានបណ្ណាល័យលក្ខណៈពេញលេញ ៤ ១៤៦ និងបណ្ណាល័យមានស្តង់ដា ១ ៥៨៩
- សាលាមធ្យមសិក្សាចំណោះទូទៅមានបណ្ណាល័យសរុប ១ ២៥១ ក្នុងនោះមានដំណើរការ ១ ០៣០
- ការបណ្តុះបណ្តាលអធិការអប់រំថ្មី ២៨៣នាក់ ស្រី ៤៣នាក់ លើតម្រូវការបណ្តុះបណ្តាល ៥២៥នាក់។

**អាទិភាពទី៤៖ ការអប់រំឌីជីថល**

- ការអនុវត្តប្រព័ន្ធព័ត៌មានសាលារៀននៅមធ្យមសិក្សាកម្ពុជា(SIS) និងអភិវឌ្ឍកម្មវិធីទូរសព្ទសម្រាប់សិក្សានៅលើទូរស័ព្ទ MoEYS eLearning APP ក្រោមកិច្ចសហការជាមួយ ស.ស.យ.ក និង e-School Cambodia
- ការបង្កើតបន្ទប់ស្ទូឌីយោសម្រាប់ផលិតមាតិកាឌីជីថល ២, ការផលិតវីដេអូជំនួយដល់ការបង្រៀន និងរៀននៅគ្រប់កម្រិតសិក្សាសម្រាប់ផ្សព្វផ្សាយក្នុងប្រព័ន្ធសិក្សាអេឡិចត្រូនិករបស់ក្រសួង
- គ្រឹះស្ថានឧត្តមសិក្សា ៥ (សា.ភូមិន្ទភ្នំពេញ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សា.ជាតិបាត់ដំបង សា.ស្វាយរៀង និងសា.ហេង សំរិន ត្បូងឃ្មុំ) បាននិងកំពុងផលិតមេរៀនសម្រាប់ការរៀន និងបង្រៀនតាមប្រព័ន្ធឌីជីថល លើមុខវិជ្ជា ២១ ស្មើនឹង ១៧៦មេរៀន
- ការផ្សព្វផ្សាយទស្សនាវដ្តីកម្ពុជាស្តីពីការស្រាវជ្រាវការអប់រំ និងស្ទែម (CJES: Cambodian Journal of Education and STEM) និងរៀបចំកម្មវិធីមគ្គុទ្ទេសក៍ស្រាវជ្រាវសម្រាប់និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ និងអ្នកស្រាវជ្រាវ តាមប្រព័ន្ធអនឡាញ អ្នកចូលរួម ១៨៤នាក់ ស្រី ៣៨នាក់
- ការចងក្រងពត៌មាន និងទិន្នន័យគម្រោងស្រាវជ្រាវ ទស្សនាវដ្តីស្រាវជ្រាវ និងការបោះពុម្ពអត្ថបទស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ១៣ ក្នុងនោះគម្រោងស្រាវជ្រាវមាន ៦៧៧គម្រោង ទស្សនាវដ្តីស្រាវជ្រាវ ១១ ទស្សនាវដ្តី និងបោះពុម្ព ៥៧លេខ និងបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ ៧៥៤អត្ថបទ
- ការចងក្រងវឌ្ឍនភាពនៃការបោះពុម្ពស្នាដៃស្រាវជ្រាវក្រោមគម្រោងកែលម្អការអប់រំឧត្តមសិក្សា នៅគ្រឹះស្ថានឧត្តមសិក្សាគោលដៅចំនួន០៥ ដែលបោះផ្សាយក្នុងកម្រិតជាតិ២០ អត្ថបទ និងកម្រិតអន្តរជាតិ ៧៧ អត្ថបទ
- ការវាយតម្លៃជ្រើសរើសអត្ថបទបោះពុម្ពជាផ្លូវការជាភាសាខ្មែរ ១៦អត្ថបទ ក្នុងនោះផ្នែកអប់រំ៨, ផ្នែកកសិកម្ម៦ និងផ្នែកស្ទែម២ ផ្សាយក្នុងទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម (CJES)
- ការគាំទ្របច្ចេកទេស និងផ្សព្វផ្សាយដំណើរការស្តីពីការរៀបចំបង្កើត គ្រប់គ្រងទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម (CJES)
- សាលារៀនមធ្យមសិក្សាទុតិយភូមិបានប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ សម្រាប់គាំទ្រការបង្រៀន និងរៀន មាន ២៦,៦៨ភាគរយ
- ការអភិវឌ្ឍសៀវភៅសិក្សាសិក្សាគោលមុខវិជ្ជា ICT សម្រាប់មធ្យមសិក្សាពីថ្នាក់ទី៧ ដល់ ១២
- ការបញ្ជូនគ្រូបង្រៀនទៅបណ្តុះបណ្តាលស្តីពីការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀននិងរៀនទៅសាធារណរដ្ឋកូរ៉េ

- ការអភិវឌ្ឍថ្នាលអប់រំឌីជីថល (e-learning) និងធនធានសិក្សាកម្ពុជា (OER) សម្រាប់ជំនួយគ្រូក្នុងការបង្រៀនតាមអេឡិចត្រូនិកនៅតាមសាលារៀន
- ការបំពាក់បន្ទប់រៀនឆ្លាតវៃ (Smart Classroom) នៅសាលាបឋមសិក្សាវត្តបូព៌
- ការបំពាក់បន្ទប់សិក្សាកុំព្យូទ័រនៅតាមសាលារៀនធនធាន
- ការផ្តល់កុំព្យូទ័របន្ទះសម្រាប់ការបង្រៀន និងរៀនតាមបែបឌីជីថល
- ការបង្កើតក្លឹបសិក្សាសរសេរកូដ សម្រាប់សិស្សានុសិស្សសិក្សានៅតាមសាលារៀន
- ការអនុវត្តកម្មវិធី Arduino និង Robotics រួមជាមួយការសរសេរកូដនៅសាលារៀនជំនាន់ថ្មី។

## អាទិភាពទី៥៖ ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

- ការរៀបចំបន្ទប់ពិសោធន៍វិទ្យាសាស្ត្រតាមមុខវិជ្ជា បន្ទប់កុំព្យូទ័រនិងបំពាក់កុំព្យូទ័រ បន្ទប់មុខវិជ្ជា បន្ទប់គ្រូបង្រៀន និងបណ្ណាល័យសតវត្សរ៍ទី២១ និងបំពាក់សម្ភារឧបទេស សម្ភារពិសោធនៅតាមវិទ្យាល័យធនធាន និងសាលារៀនជំនាន់ថ្មី
- ការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ ៣៧នាក់ លើការអភិវឌ្ឍកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងការវាយតម្លៃការសិក្សារបស់និស្សិត
- ការអនុម័តដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការគ្រប់គ្រងការស្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សាគោលដៅ ៦
- ការអនុវត្តសាកល្បងប្រព័ន្ធវាយតម្លៃការងារផ្អែកលើលទ្ធផលនៃការបំពេញការងារជាមួយបុគ្គលិកអប់រំ នៃគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៦
- ការអនុវត្តកម្មវិធីបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា ជាមួយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៥ ដើម្បីគាំទ្រការរៀន និងបង្រៀនតាមបែបឌីជីថល, សាកលវិទ្យាល័យអង្គរ បានទទួលការអនុញ្ញាតចូលរួមជាសមាជិកក្នុងការអនុវត្តកម្មវិធីបណ្តាញសាកលវិទ្យាល័យសាយប័រ
- ការរៀបចំសេចក្តីព្រាងនៃសៀវភៅណែនាំស្តីពីការបង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌលឧត្តមភាពជំរុញការស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា
- ការគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សាក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ (រៀបចំសៀវភៅណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ) និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមរយៈការផ្តល់ការបណ្តុះបណ្តាលដល់ជនបង្គោល
- គ្រឹះស្ថានឧត្តមសិក្សា ៣២ បានរៀបចំរបាយការណ៍ស្វ័យវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង
- គ្រឹះស្ថានឧត្តមសិក្សា ៤៩ បានបំពេញទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យឧត្តមសិក្សា Data Management
- ការអភិវឌ្ឍកម្មវិធីគ្រប់គ្រងទិន្នន័យឧត្តមសិក្សាតាមប្រព័ន្ធអនឡាញ
- ការបង្កើតគេហទំព័រអគ្គនាយកដ្ឋានឧត្តមសិក្សាដើម្បីផ្សព្វផ្សាយព័ត៌មាន និងទិន្នន័យឧត្តមសិក្សា។

## អាទិភាពទី៦៖ ការអភិវឌ្ឍជំនាញសតវត្សរ៍ទី២១ សម្រាប់យុវជន

- ការអនុវត្តកម្មវិធីយុវជន២១ ក្រោមប្រធានបទ សហគ្រិនឌីជីថល នវានុវត្តន៍អាជីវកម្ម និងកម្មវិធីការអប់រំសហគ្រិនភាព
- ការអប់រំស្តីពីសហគ្រិនភាពឌីជីថលក្នុងកម្មវិធីយុវជន២១ ក្រោមប្រធានបទ "នវានុវត្តន៍អាជីវកម្ម" ដល់យុវជន ៦៥៩នាក់ ស្រី ២៧៤នាក់
- ការបណ្តុះបណ្តាលការរៀបចំផែនការអាជីវកម្ម និងការប្រកួតប្រជែងផែនការអាជីវកម្មស្តីពី "ផែនការអាជីវកម្មខ្ញុំ" ដល់យុវជន ២១០នាក់ ស្រី ១២៩នាក់

- ការបណ្តុះបំណិនបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងសង្គម សម្រាប់កាយរឹទ្ធិជំទង់ និងកាយរឹទ្ធិរៀមច្បង ២០០នាក់ (ការបោះជំរំ JOTA-JOTI) និងប្រើប្រាស់បណ្តាញ scout.org
- ការបណ្តុះបំណិនមូលដ្ឋានស្តីពីអក្ខរកម្មហិរញ្ញវត្ថុដល់យុវជន ១០៥នាក់ ស្រី ៦៥នាក់
- ការបណ្តុះបណ្តាលចំណេះដឹងស្តីពីអក្ខរកម្មឌីជីថលដល់យុវជន ១ ២៨០នាក់ ស្រី ៦៩៤នាក់
- ការបណ្តុះបណ្តាលជំនាញទន់លើប្រធានបទ ការស្គាល់ខ្លួនឯង ការកំណត់ទស្សនវិស័យ ការងារជាក្រុម និងការដោះស្រាយបញ្ហាដល់យុវជន ១៨០នាក់ ស្រី ១០៤នាក់
- ការបោះជំរំកាយរឹទ្ធិប្អូនថ្នាក់ជាតិលើកទី១ ក្រោមប្រធានបទ "កុមារសតវត្សរ៍ទី២១" ដល់កាយរឹទ្ធិប្អូន កាយរឹទ្ធិជំទង់ និងអ្នកស្ម័គ្រចិត្ត ៤៥០នាក់ និងការបោះជំរំកាយរឹទ្ធិនៃបុណ្យសមុទ្រដល់កាយរឹទ្ធិជំទង់ និងអ្នកស្ម័គ្រចិត្ត ១៥០នាក់
- កម្មវិធីជជែកដេញដោលយុវជនថ្នាក់ជាតិ និងជំនាញនិយាយសាធារណៈ យុវជនចូលរួម ៣៩៦នាក់ ស្រី ២២៧នាក់ និងការប្រកួតប្រជែងស្នាដៃយុវជនសតវត្សទី២១ (គម្រោង STEM) យុវជនចូលរួម ៥៧០នាក់ ស្រី ២៨០នាក់
- ការជួសជុលមជ្ឈមណ្ឌលយុវជននៅខេត្តកំពង់ឆ្នាំង និងក្រចេះ
- ការបង្កើតកម្មវិធីសិក្សាពេញមួយជីវិតក្នុងមជ្ឈមណ្ឌលយុវជនខេត្ត ៥គឺ ខេត្តតាកែវ កំពង់ចាម កំពង់ធំ ស្វាយរៀង និងខេត្តកំពង់ធំ
- ការអនុម័តដាក់ឱ្យប្រើប្រាស់សៀវភៅក្រុមប្រឹក្សាយុវជនកម្ពុជា
- ការធ្វើបច្ចុប្បន្នកម្មសេចក្តីណែនាំ ស្តីពីការវាយតម្លៃដើម្បីជ្រើសរើសក្រុមប្រឹក្សា កុមារកម្ពុជាល្អ និងក្រុមប្រឹក្សា យុវជនកម្ពុជាល្អប្រចាំឆ្នាំ
- ការរៀបចំសេចក្តីព្រាងសៀវភៅណែនាំស្តីពីកាយរឹទ្ធិប្អូន កាយរឹទ្ធិជំទង់ កាយរឹទ្ធិរៀមច្បង និងមេដឹកនាំកាយរឹទ្ធិ
- ការចូលរួមកម្មវិធីផ្លាស់ប្តូរយុវជនអន្តរជាតិនៅក្នុងតំបន់អាស៊ាន និងទ្វីបអាស៊ី យុវជនចូលរួម ៩០នាក់ ស្រី ៤៥នាក់។

**អាទិភាពទី៧៖ ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅកម្រិតឧត្តមសិក្សា**

- ការបង្កើតអន្តេវាសិកដ្ឋានសិស្សស្រី ៤កន្លែង (កំពុងសាងសង់ NUBB ITC RUPP និងRUA)
- ការកែលម្អបន្ទប់សិក្សា បន្ទប់ពិសោធន៍ សង់រោងចិញ្ចឹមសត្វ (គោ និងពពែ) សង់រោងបន្លែ សង់ផ្ទះសំណាញ់ សង់អគារពាណិជ្ជកម្ម សង់អគារ Incubation Center នៅតាមគ្រឹះស្ថានឧត្តមសិក្សា ៩ (RUPP, RUA, SRU, NUBB, UHST, UME, PPIU, ITC និងBHI) និងរៀបចំប្រព័ន្ធទឹកភ្លើងនៅទីតាំងដីថ្មីរបស់សាកលវិទ្យាល័យស្វាយរៀង
- ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា ៤ រួមមាន សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាកលវិទ្យាល័យជាតិគ្រប់គ្រង
- ការកែលម្អបន្ទប់ពិសោធន៍ និងបំពាក់សម្ភារៈដល់គ្រឹះស្ថានឧត្តមសិក្សា ៦
- ការអនុវត្តកម្មវិធីបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា ជាមួយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៥ ដើម្បីគាំទ្រការរៀន និងបង្រៀនតាមបែបឌីជីថល
- ការបណ្តុះបណ្តាលបំណិនបច្ចេកទេស និងកសិកម្មដល់សិស្សសាលាមធ្យមសិក្សា ១០២ ដោយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៥
- ការបើកជំនាញថ្មីពាក់ព័ន្ធផ្នែកឌីជីថល ៨មុខជំនាញ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- ករៀបចំគោលការណ៍ស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ការតាំនិស្សិត HEMIS

- ការរៀបចំសៀវភៅណែនាំស្តីពីការទទួលស្គាល់គុណភាពអប់រំ
- ការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង
- ការស្រាវជ្រាវស្តីពីការអប់រំថ្នាក់ក្រោយបរិញ្ញាបត្រនៅកម្ពុជា៖ ផ្លូវទៅកាន់ឧត្តមភាពនៃការស្រាវជ្រាវ
- ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងស្នាដៃស្រាវជ្រាវ និងស្ថិតិនិស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ
- ការពិនិត្យ និងកែលម្អបន្ថែមលើលក្ខណៈវិនិច្ឆ័យលើក្នុងការរៀបចំយន្តការ នីតិវិធី និងការវាយតម្លៃលើឋានៈសាស្ត្រាចារ្យ សាស្ត្រាចារ្យរង សាស្ត្រាចារ្យជំនួយក្នុងវិស័យអប់រំ។

**អាទិភាពទី៨៖ ការពង្រឹងសមត្ថភាពស្ថាប័ន និងការកសាងប្រព័ន្ធអប់រំ**

- ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៣ សូចនាករសមិទ្ធកម្មឆ្នាំ២០២៣ និងផែនការយុទ្ធសាស្ត្រថវិកា ២០២៤-២០២៦
- ការសម្រួចសកម្មភាពអាទិភាពដោយបន្សីុជាមួយនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រោងថវិកាឆ្នាំ២០២៤ ដោយផ្សាភ្ជាប់ជាមួយនឹងផែនការសមិទ្ធកម្ម
- ការអភិវឌ្ឍប្រព័ន្ធ EFMS លើមុខងារគ្រប់គ្រងថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ
- ការអភិវឌ្ឍប្រព័ន្ធ EFMS លើមុខងារបេសកកម្មក្នុងប្រទេស និងក្រៅប្រទេស និងត្រៀមដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ២០២៤
- ការធ្វើបច្ចុប្បន្នកម្មប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុអប់រំ (EFMS) ដោយផ្សាភ្ជាប់របាយការណ៍ហិរញ្ញវត្ថុជាមួយនឹងរបាយការណ៍សមិទ្ធកម្ម
- ការរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មឆ្នាំ២០២៣ រវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ការវិភាគស្ថានភាពអប់រំនៃការអនុវត្តផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ក្នុងរយៈពេល៩ឆ្នាំ (ឆ្នាំ ២០១៤-២០២២)
- ការរៀបចំធាតុចូលរបស់វិស័យអប់រំសម្រាប់ការរៀបចំផែនយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤ -២០២៨
- ការផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០២១-២០២៥ និងការអប់រំ STEM ឆ្លើយតបនឹងយេនឌ័រ
- ការអនុម័តក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម
- ការដំឡើងម៉ាស៊ីនបម្រើ(Server) សម្រាប់ដំណើរការប្រព័ន្ធគ្រប់គ្រង់ទិន្នន័យសិស្ស(STS)
- ការរៀបចំឧបករណ៍បណ្តាញណិតវើក (Switch, Router, and Cable Network...) នៅថ្នាក់ជាតិ
- ការប្រមូលទិន្នន័យទីតាំងសាលារៀនកើតថ្មីជាមួយកម្មវិធីដំណើរការក្នុងទូរស័ព្ទដៃវៃឆ្លាត (Andriod & iOS)
- ការពង្រីកប្រព័ន្ធគ្រប់គ្រងទិន្នន័យសិស្សតាមអនឡាញសម្រាប់ថ្នាក់រាជធានី ខេត្ត
- ការបង្កើតគេហទំព័រ EMIS រួមមានផែនទីទីតាំងសាលារៀន (Digital School Mapping) ប័ណ្ណព័ត៌មានសាលារៀន (School Report Card)
- ការរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការផ្ទេរមុខងារវិស័យអប់រំ យុវជន និងកីឡា ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស
- ការរៀបចំគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- ការរៀបចំម៉ូឌុលស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពត្រូវបានដាក់ក្នុងប្រព័ន្ធ HRMIការរៀបចំក្របខណ្ឌនិងផែនការសកម្មភាពប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- ការរៀបចំប្រព័ន្ធផ្តល់ក្រេឌីដការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងសៀវភៅណែនាំអនុវត្ត

- ការរៀបចំផែនការអនុវត្តន៍ប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ២០២៣-២០២៨ និងផែនការយុទ្ធសាស្ត្រ HRMIS ២០២៣-២០២៨។

**អាទិភាពទី៩៖ ការអភិវឌ្ឍការអប់រំកាយ និងកីឡា**

- ការផ្គត់ផ្គង់សម្ភារៈកីឡាសម្រាប់បណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា
- ការបើកផ្តល់សម្ភារៈកីឡាជូនកីឡាករ កីឡាការិនីសម្រាប់ហាត់ហ្វឹកហ្វឺនគ្រប់គ្រាន់
- ការធ្វើផែនការលទ្ធកម្មឧបករណ៍ត្រួតពិនិត្យបច្ចេកទេសគុណផលកីឡា សម្ភារៈហ្វឹកហាត់ និងសម្ភារៈប្រើប្រាស់ សម្រាប់បំរើការបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា (ឆ្នាំ២០២៤)
- ការកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា
- ការជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ ទីលានកីឡាបាល់ទាត់សាលាតម្រង់ទិស ៨ទីលាន ក្នុងនោះមាន ខេត្តត្បូងឃ្មុំ ស្វាយរៀង កំពង់ឆ្នាំង ព្រៃវែង កំពង់ស្ពឺ តាកែវ កណ្តាល និងរាជធានីភ្នំពេញ
- ការលើកកម្ពស់សមត្ថភាពគ្រូក្នុងការប្រើប្រាស់សៀវភៅអប់រំកាយនៅគ្រឹះស្ថានបឋមសិក្សា ១៤០នាក់ ស្រី ៩នាក់
- ការកែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡាកម្រិតមូលដ្ឋាន១២+២
- ការរៀបចំកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រសិល្បៈមនុស្សសាស្ត្រឯកទេសអប់រំកាយ
- ការអភិវឌ្ឍសៀវភៅសិក្សាគោលមុខវិជ្ជាគរុកោសល្យ និងវិធីសាស្ត្របង្រៀនអប់រំកាយ និងបានចងក្រងសៀវភៅទិវាអប់រំកាយនៅមធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ ៨ និងថ្នាក់ទី៩ មាន ៦ក្បាល
- ការផលិតឯកសារវីដេអូអប់រំកាយ និងកីឡាជាមួយចង្វាក់ភ្លេង សម្រាប់អនុវត្តនៅតាមគ្រឹះស្ថានសិក្សា
- ការរៀបចំក្រុមកីឡាបាល់ទាត់អន្តរនាយកដ្ឋាន ការប្រកួតមិត្តភាព និងការប្រកួតអន្តរក្រសួងនានា និងថ្នាក់រាជធានី ខេត្ត
- ការពង្រឹងការពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពភាពបង្រៀន និងរៀនអប់រំកាយនៅតាមសាលាគោលដៅ ក្នុង ខេត្ត ១០៖ ខេត្តកំពត កែប ស្វាយរៀង បន្ទាយមានជ័យ រតនគិរី ព្រះវិហារ ព្រៃវែង បាត់ដំបង និងពោធិ៍សាត់
- ការរៀបចំទិវាអប់រំកាយថ្នាក់ជាតិលើកទី៣ នៅខេត្តពោធិ៍សាត់ គ្រូបង្រៀន និងសិស្សានុសិស្សចូលរួម ៦៥០នាក់ ស្រី ៣២៥នាក់
- ការបំផុសសកម្មភាពហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាពក្នុងទិវាអាស៊ានហាត់ប្រាណដើម្បីសុខភាពនៅរាជធានីភ្នំពេញ មានប្រជាជនចូលរួម ៨១៦នាក់ ស្រី៥៦១នាក់
- ការបំផុសសកម្មភាពហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាពក្នុងទិវាកីឡាអាស៊ាន និងទិវាកីឡាសម្រាប់ទាំងអស់គ្នា មានប្រជាជនចូលរួម ២ ២០៦នាក់ ស្រី ១ ២៩០នាក់
- ការរៀបផែនការហ្វឹកហាត់ប្រចាំឆ្នាំ ប្រចាំឆមាសប្រចាំ ខែ ប្រចាំសប្តាហ៍ ប្រចាំថ្ងៃ
- ការអនុវត្តន៍គោលការណ៍ស្តង់ដារ SOP សម្រាប់ការហាត់ហ្វឹកហ្វឺនក្នុងបរិបទកូវីដ-១៩ និងការហ្វឹកហាត់លក្ខណៈឯកត្តជន បង្ហាត់ពីចម្ងាយតាមប្រព័ន្ធ Online
- ការរៀបចំទីលានហាត់ហ្វឹកហ្វឺនទៅតាមលក្ខណៈស្តង់ដាជាតិ និងអន្តរជាតិ បំពាក់ឧបករណ៍បច្ចេកទេស និងសាលហ្វឹកហាត់សាច់ដុំ
- ការត្រួតពិនិត្យការហាត់ហ្វឹកហ្វឺនជាប្រចាំ ការអនុវត្តបទបញ្ជាផ្ទៃក្នុងនៃការប្រមូលផ្តុំហាត់ហ្វឹកហ្វឺន ការប្រើប្រាស់ឧបករណ៍តាមដានការហាត់ហ្វឹកហ្វឺនប្រចាំថ្ងៃ និងការធ្វើតេស្តជាបីដំណាក់កាល (ដំណាក់កាលរៀបចំ, ដំណាក់កាលរៀបចំប្រកួត, ដំណាក់កាលប្រកួត)
- ការប្រមូលផ្តុំត្រៀមលក្ខណៈចូលរួមប្រកួតកីឡាស៊ីហ្គេម និងត្រៀមលក្ខណៈការប្រកួតកីឡាអន្តរជាតិនានា (រៀបចំផែនការហាត់ហ្វឹកហ្វឺន, ការព្យាបាល, ការស្នាក់នៅ ហូបចុក, ទីលាន និងឧបករណ៍បច្ចេកទេស)

- ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងវិស័យអប់រំកាយ និងកីឡា
- ការរៀបចំកិច្ចព្រមព្រៀងស្តីពីការអនុវត្តថវិកាគាំទ្រទៅសហព័ន្ធកីឡាជាតិ៤៨
- ការរៀបចំសេចក្តីសម្រេច ស្តីពីការបង្កើតសហព័ន្ធកីឡាជាតិ
- ការចេញប្រកាសអនុញ្ញាតឱ្យសមាជិកគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាជាតិបំពេញភារកិច្ច ១២ សហព័ន្ធ
- ការរៀបចំសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីសិក្សាអប់រំកាយក្នុងម៉ោងសិក្សា និងកីឡាក្រៅម៉ោងសិក្សា នៅតាមគ្រឹះស្ថានបឋមសិក្សា និងគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
- ការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិលើ ១០ប្រភេទកីឡា មានប្រតិភូកីឡាចូលរួម ២ ៥០០នាក់
- ការប្រកួតកីឡាមធ្យមសិក្សាថ្នាក់ជាតិលើ ១២ប្រភេទកីឡា មានប្រតិភូកីឡាចូលរួម ៣ ៥០០នាក់
- ការរៀបចំបទបញ្ញត្តិ បទបញ្ជាបច្ចេកទេសតាមច្បាប់អន្តរជាតិ, ការចុះឈ្មោះតាមប្រព័ន្ធព័ត៌មានវិទ្យាលក្ខណៈអន្តរជាតិ, បញ្ជូនមន្ត្រីបច្ចេកទេសទៅចូលរួមតាមដាន និងវាយតម្លៃលទ្ធផលការប្រកួតលក្ខណៈអន្តរជាតិ
- ការបើកវគ្គបំប៉នសមត្ថភាពមន្ត្រីរៀបចំ និងគ្រប់គ្រងការប្រកួត មន្ត្រីបច្ចេកទេសទាំងអស់ដែលចូលរួមរៀបចំការប្រកួតកីឡាសិស្ស គឺមានវិញ្ញាបនបត្របណ្តុះបណ្តាក់ពីកម្រិតនៃការរៀបចំ។

## ២.២ វឌ្ឍនភាពនៃការអនុវត្តស្តង់ដាសាលារៀនគំរូ

### ២.២.១ ការពង្រឹងអភិបាលកិច្ចសាលារៀន

- ការអនុវត្តកម្មវិធីការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាពនៅតាមគ្រឹះស្ថានសិក្សារដ្ឋ ក្នុងនោះសាលាមត្តេយ្យសិក្សា ២១៣ សាលាបឋមសិក្សា ១ ៧០០ និងសាលាមធ្យមសិក្សា ៥០៦
- ការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- ការបង្កើនគណនេយ្យភាពនិងតម្លាភាពរបស់សាលារៀន ដោយបិទផ្សាយជាសាធារណៈនូវលទ្ធផលតេស្តស្តង់ដារបាយការណ៍ចំណូល-ចំណាយ និង រៀបចំការប្រជុំជាមួយសហគមន៍យ៉ាងទៀងទាត់
- ការរៀបចំឧបករណ៍ស្តង់ដាសាលារៀនគំរូ
- ការរៀបចំលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃស្តង់ដាសាលាបឋមសិក្សាគំរូ
- ការរៀបចំសេចក្តីណែនាំស្តីពីការអនុវត្តស្តង់ដាសាលាបឋមសិក្សាគំរូ និងដាក់ឱ្យអនុវត្តតាមរយៈប្រកាសលេខ ១២៦៩ អយក.បស ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣
- ការរៀបចំប្រកាសស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាសាលាបឋមសិក្សាគំរូ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤។

### ២.២.២ ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស

- ការអភិវឌ្ឍឯកសារស្តីពីការកែលម្អសៀវភៅសិក្សាគោល មុខវិជ្ជាភាសាខ្មែរ អក្សរសាស្ត្រខ្មែរ និងសិក្សាសង្គមកម្រិតមធ្យមសិក្សាថ្នាក់ទី៧-៩ និង១០-១២ ក្នុងនោះសៀវភៅសិក្សាគោលមុខវិជ្ជាសីលធម៌-ពលរដ្ឋ ៦ច្បាប់ ភូមិវិទ្យា ៦ច្បាប់ ប្រវត្តិវិទ្យា ៦ច្បាប់ សេដ្ឋកិច្ច ៦ច្បាប់ និងភាសាខ្មែរ ៦ច្បាប់ សរុប ៣០ច្បាប់
- ការអភិវឌ្ឍឯកសារ ស្តីពីកម្រិតសមត្ថភាពសិស្សថ្នាក់ទី៦ ទី៩ និងទី១២ ក្នុងនោះ ឯកសារកម្រិតសមត្ថភាពសិស្សថ្នាក់ទី៦ ថ្នាក់ទី៩ និងថ្នាក់ទី១២ ចំនួន៣ច្បាប់ លើមុខវិជ្ជាវិទ្យាសាស្ត្រ (រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី និង បរិស្ថានវិទ្យា) មុខវិជ្ជាវិទ្យាសាស្ត្រសង្គម (សីលធម៌-ពលរដ្ឋ ភូមិវិទ្យា ប្រវត្តិវិទ្យានិងសេដ្ឋកិច្ច គណិតវិទ្យា និងអក្សរសាស្ត្រខ្មែរ

- ការកែលម្អសៀវភៅសិក្សាគោលមុខវិជ្ជាភាសាខ្មែរ វិទ្យាសាស្ត្រ និងសិក្សាសង្គម ព្រមទាំងអភិវឌ្ឍសៀវភៅផ្សេងៗ ចំនួន ២៧ចំណងជើង
- កែលម្អសៀវភៅសិក្សាគោលសម្រាប់សិស្ស ១២ចំណងជើង (Ma7, Ma8, Ma9, Ma10, Ma11-SS, Ma11-SC1, Ma11-SC2, Ma12-SS, Ma12-SC1, Ma12-SC2, Ss1, Ss4) និងសៀវភៅអប់រំសុខភាព សម្រាប់សិស្សនិងគ្រូ ១២ចំណងជើង (អប់រំសុខភាពថ្នាក់ទី១, ៤, ៧, ៨, ៩, ១០)
- កែលម្អសៀវភៅហ្វឹកហាត់និងអំណានបន្ថែម ៣ចំណងជើង (អំពីបន្លែនិងផ្លែឈើ, រឿងសត្វសេក, និង រឿងកុមារចូលចិត្តធ្វើត្រាប់គេ)
- ការណែនាំអនុវត្តវិធីសាស្ត្របង្រៀនកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូងថ្នាក់ទី១ និងវិធីសាស្ត្របង្រៀននិងការប្រើប្រាស់កញ្ចប់សម្ភារៈគណិតវិទ្យា សម្រាប់បំប៉នដល់គ្រូឧទ្ទេសថ្នាក់ជាតិដើម្បីបំប៉នបន្ត ដល់គ្រូបង្រៀនថ្នាក់ទី១
- ការបង្កើតសៀវភៅណែនាំគ្រូសម្រាប់ជំនាញវិជ្ជាជីវៈមុខរបរងាយៗសម្រាប់កម្មវិធីបង្កើតប្រាក់ចំណូល
- ការពង្រឹងការអនុវត្តកម្មវិធីអប់រំកាយ និងកីឡាក្នុងម៉ោងសិក្សា និងក្រៅម៉ោងសិក្សានៅគ្រឹះស្ថានបឋមសិក្សា និងគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ។

### ២.២.៣ ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា

- ការវាស់គំហើញ ការពិនិត្យភ្នែក និងកាត់វ៉ែនតាជូនដល់សិស្ស និងគ្រូបង្រៀនតាមសាលារៀន ៣០០ ៧០៥ នាក់ ស្រី ១០០ ៥០១នាក់
- ការពិនិត្យសុខភាពភ្នែកសិស្សានុសិស្សនៅតាមសាលារៀន ១២ ៤០០នាក់ ស្រី ១៨ ៨៥៣នាក់ ក្នុងនោះទទួលវ៉ែនតា ៧ ១៩៣នាក់ ស្រី ៤៧១នាក់
- ការពិនិត្យសុខភាពភ្នែកបុគ្គលិកអប់រំនៅតាមសាលារៀន ៣ ៧៧៦នាក់ ស្រី១ ៣១៧នាក់ ក្នុងនោះទទួលវ៉ែនតា ២ ៣៤៥នាក់
- ការលើកកម្ពស់បរិស្ថានស្អាត បៃតង សុវត្ថិភាព អនាម័យ និងមេត្រីភាពតាមគ្រឹះស្ថានសិក្សា លើការរៀបចំធុងដាក់សំរាមតាមប្រភេទ ឡដុតសំរាមតាមបែបបច្ចេកទេស ការរៀបចំសួនផ្កា ការដាំដើមឈើ និងសួនជីវៈចម្រុះ និងការអនុវត្ត «គំនិតផ្តួចផ្តើមសាលារៀនគ្មានសំរាម»
- ការផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ២៦៩ ៨៣៨នាក់ ស្រី ១៣២ ៥៤០ នាក់
- ការពង្រឹងការអនុវត្តសៀវភៅណែនាំស្តីពីការចម្អិនអាហារសម្រាប់ចុងភៅសាលារៀន និងការអនុវត្តសេចក្តីណែនាំលេខ១១ អយក. សណន ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការជំរុញដំណើរការសួនសាលារៀនសម្រាប់ធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភនៅតាមគ្រឹះស្ថានសិក្សា

### ២.២.៤ ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូរដ្ឋ និងសហគមន៍ ដើម្បីការអប់រំ

- ការគាំទ្ររបស់សហគមន៍ តាមរយៈការកៀរគរមូលនិធិគាំទ្រសាលារៀន ដើម្បីជួយ គាំទ្រដល់ការសិក្សារបស់សិស្សានុសិស្ស
- ការពង្រឹងវិន័យ សីលធម៌ ចរិយាធម៌ សុជីវធម៌ គុណធម៌ និងឥរិយាបថល្អរបស់បុគ្គលិកអប់រំ និងសិស្សានុសិស្សដោយអនុវត្តការផ្តល់ពិន្ទុ ៨០ភាគរយលើចំណេះដឹង, ១០ភាគរយលើបំណិន និង១០ភាគរយលើសីលធម៌ ចរិយាធម៌ និងសកម្មភាពជួយសង្គម

- ការរៀបចំកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ រវាងសាលារៀនជាមួយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ការរៀបចំកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ រវាងក្រុមទីប្រឹក្សាគរុកោសល្យ/ក្រុមគាំទ្រ/ក្រុមគ្រូបង្វឹកជាមួយប្រធាននាយកដ្ឋាន
- ការបង្កើនអាហារូបករណ៍សម្រាប់និស្សិតសិក្សាជំនាញស្ទែមតាមរយៈការកៀគរថវិកាពីដៃគូ។

## ៣. វឌ្ឍនភាព នៃការអនុវត្តសកម្មភាពផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៣

ឆ្នាំ២០២៣ អង្គភាពថ្នាក់ជាតិ ៥៣ គ្រោងសកម្មភាពប្រចាំឆ្នាំសរុប ៧៨៩ ក្នុងនោះសកម្មភាពអនុវត្តចប់ ៦៦០ ស្មើ ៨៣,៦៥ភាគរយ កំពុងអនុវត្ត ៧០ ស្មើ ៨,៨៧ភាគរយ និងមិនបានអនុវត្ត ៥៩ ស្មើ ៧,៤៨ភាគរយ។ បើធៀបនឹងឆ្នាំ២០២២ សកម្មភាពគ្រោង ៩៣៦ សកម្មភាព ថយ ១៤៧ សកម្មភាព ស្មើ ១៧ភាគរយ ក្នុងនោះសកម្មភាពអនុវត្តចប់ ៦៧៤ ថយ ១៤ សកម្មភាព ស្មើ ២,១ភាគរយ កំពុងអនុវត្ត ១២២ ថយ ៥២សកម្មភាព ស្មើ ៥៤,២ភាគរយ និងមិនបានអនុវត្ត ១៤០ ថយ ៨១សកម្មភាព ស្មើ ៨១,៤ភាគរយ។

**រូបភាពទី១៖ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពប្រចាំឆ្នាំ**




### វឌ្ឍនភាពតាមចង្កោមសកម្មភាព

ការគ្រោងសកម្មភាពអនុវត្តប្រចាំឆ្នាំ២០២៣ តាមចង្កោមសកម្មភាពទី១ សរុប ៤៨៨ និងចង្កោមសកម្មភាពទី២ សរុប ៣០១។ ចង្កោមសកម្មភាពទី១ អនុវត្តចប់ ៤២២ ស្មើ ៨៦,៤៨ភាគរយ កំពុងអនុវត្ត ៣៨ ស្មើ ៧,៧៩ភាគរយ និងមិនបានអនុវត្ត ២៨ ស្មើ ៥,៧៤ភាគរយ។ ចង្កោមសកម្មភាពទី២ អនុវត្តចប់ ២៣៨ ស្មើ ៧៩,០៧ភាគរយ កំពុងអនុវត្ត ៣២ ស្មើ ១០,៦៣ភាគរយ និងមិនបានអនុវត្ត ៣១ ស្មើ ១០,៣០ភាគរយ។

**រូបភាពទី២៖ លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាពតាមចង្កោមសកម្មភាព**




## ៣.១ វឌ្ឍនភាព នៃការអនុវត្តថវិកា

ថវិកាក្រសួងឆ្នាំ២០២៣ សរុប ៣ ៣៦១ ៨២៥ ៦០០ ០០០រៀល អនុវត្តបាន ៣ ១៥៤ ៣៣១ ២៨៥ ២៤២រៀល ស្មើ ៩៣,៨៣ភាគរយ ក្នុងនោះរដ្ឋបាលកណ្ដាលចំនួន ៣៧៧ ៤៧៨ ៦០០ ០០០រៀល អនុវត្តបាន ២៩៣ ៣៤៧ ८៥៨ ៧២៩រៀល ស្មើ ៧៧,៧១ភាគរយ រាជធានី ខេត្តចំនួន ២ ៩៨៤ ៣៤៧ ០០០ ០០០រៀល អនុវត្តបាន ២ ៨៦០ ៩៨៣ ៤២៦ ៥១៣រៀល ស្មើ ៩៥,៨៧ភាគរយ។ ការអនុវត្តថវិកាតាមកម្មវិធី៖

**កម្មវិធីទី១** សរុប ៦២ ८៩០ ८០០ ០០០រៀល អនុវត្តបាន ៥៨ ៦៩៣ ८៥២ ៤០២រៀល ស្មើ ៩៣,៣៣ភាគរយ

**កម្មវិធីទី២** សរុប ៣៣ ៣៤៨ ៩០០ ០០០រៀល អនុវត្តបាន ២៨ ៦០០ ១៩១ ៥៣៥រៀល ស្មើ ៨៥,៧៦ភាគរយ

**កម្មវិធីទី៣** សរុប ៤៣ ៨៧៣ ៧០០ ០០០រៀល អនុវត្តបាន ២៦ ៤៨៥ ១២៨ ៥៤៥រៀល ស្មើ ៦០,៣៧ភាគរយ

**កម្មវិធីទី៤** សរុប ៩ ០០៧ ៧០០ ០០០រៀល អនុវត្តបាន ១៥ ៦៦៣ ៣១៤ ២១៦រៀល ស្មើ ១៧៣,៨៩ភាគរយ

**កម្មវិធីទី៥** សរុប ២២៨ ៣៥៧ ៥០០ ០០០រៀល អនុវត្តបាន ១៦៣ ៩០៥ ៣៧២ ០៣១រៀល ស្មើ ៧១,៧៨ ភាគរយ។

**រូបភាពទី៣៖ វឌ្ឍនភាពនៃការអនុវត្តថវិកា ប្រចាំឆ្នាំ២០២៣**




(ប្រភពនា.ហិរញ្ញវត្ថុ គិតត្រឹម ២៩/១២/២០២៣)

## ៣.២ វឌ្ឍនភាព នៃការសម្រេចបានសូចនាករប្រចាំឆ្នាំ២០២៣

### ៣.២.១ សូចនាករលទ្ធផលចុងក្រោយកម្រិតកម្មវិធី

ឆ្នាំ២០២៣ ក្រសួងបានកំណត់សូចនាករតាមកម្មវិធីសរុប ១១ សូចនាករ ក្នុងនោះ សម្រេចបានតាមចំណុចដៅ ៥ ស្មើ ៤៥,៤៥ភាគរយ អាចទទួលយកបាន ៥ ស្មើ ៤៥,៤៥ភាគរយ និងមិនសម្រេចបានតាមចំណុចដៅ ១ ស្មើ ៩,០៩ ភាគរយ។

**រូបភាពទី៤ ៖ វឌ្ឍនភាព នៃការសម្រេចលទ្ធផលសូចនាករចុងក្រោយកម្រិតកម្មវិធី**




បើពិនិត្យមើលតាមកម្មវិធីទាំង៥

*កម្មវិធីទី១ "ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ"* សរុប ៤សូចនាករ សម្រេចបានតាមចំណុចដៅ ២ ស្មើ ៥០ភាគរយ និងអាចទទួលយកបាន ២ ស្មើ ៥០ភាគរយ។

*កម្មវិធីទី២ "ការអភិវឌ្ឍឧត្តមសិក្សានិងការស្រាវជ្រាវ"* សរុប ២ សូចនាករ អាចទទួលយកបាន ១ ស្មើ ៥០ ភាគរយ សម្រេចមិនបានតាមចំណុចដៅ ១ ស្មើ ៥០ភាគរយ។

*កម្មវិធីទី៣ "ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា"* សរុប ៣ សូចនាករ សម្រេចបានតាមចំណុចដៅ ៣ ស្មើ ១០០ភាគរយ។

*កម្មវិធីទី៤ "យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត"* សរុប ១ សូចនាករ អាចទទួលយកបាន ១ ស្មើ ១០០ភាគរយ ។

*កម្មវិធីទី៥ "ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ"* សរុប១ សូចនាករ សម្រេចបានតាមចំណុចដៅ ១ ស្មើ ១០០ភាគរយ។

រូបភាពទី ៥ ៖ វឌ្ឍនភាពនៃការសម្រេចសូចនាករតាមកម្មវិធីទាំង៥




## ៣.២.២ សូចនាករលទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី

សូចនាករតាមអនុកម្មវិធី ក្រសួងបានកំណត់សរុប ១៤៦ សូចនាករ ក្នុងនោះ សម្រេចចំណុចដៅ ៩២ ស្មើ ៦៣,០១ភាគរយ អាចទទួលយកបាន ៣៩ ស្មើ ២៦,៧១ភាគរយ និងមិនសម្រេចតាមចំណុចដៅ ១៥ ស្មើ ១០,២៧ភាគរយ។

រូបភាពទី៦ ៖ វឌ្ឍនភាពនៃការសម្រេចសូចនាករលទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី




បើពិនិត្យតាមកម្មវិធីទាំង ៥ មាន៖

*កម្មវិធីទី១ "ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ"* មានអនុកម្មវិធី ៩ សរុប ៣១សូចនាករ សម្រេចបានតាមចំណុចដៅ ២២ ស្មើ ៧០,៩៧ភាគរយ អាចទទួលយកបាន ៦ ស្មើ ១៩,៣៥ភាគរយ និងមិនបានអនុវត្ត ៣ ស្មើ ៩,៦៨ភាគរយ។

*កម្មវិធីទី២ "ការអភិវឌ្ឍឧត្តមសិក្សានិងការស្រាវជ្រាវ"* មានអនុកម្មវិធី ១៨ សរុប ៤៨សូចនាករ សម្រេចបានតាមចំណុចដៅ ៣៧ ស្មើ ៧៧,០៨ភាគរយ អាចទទួលយកបាន ៧ ស្មើ ១៤,៥៨ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ៤ ស្មើ ៨,៣៣ភាគរយ។

*កម្មវិធីទី៣ "ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា"* មានអនុកម្មវិធី ៦ សរុប ៩សូចនាករ សម្រេចបានតាមចំណុចដៅ ៥ ស្មើ ៥៥,៥៦ភាគរយ អាចទទួលយកបាន ២ ស្មើ ២២,២២ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ២ ស្មើ ២២,២២ភាគរយ។

*កម្មវិធីទី៤ "យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត"* មានអនុកម្មវិធី ៣ សរុប ៥សូចនាករ សម្រេចបានតាមចំណុចដៅ ៤ ស្មើ ៨០ភាគរយ និងអាចទទួលយកបាន ១ ស្មើ ២០ភាគរយ ។

*កម្មវិធីទី៥ "ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ"* មានអនុកម្មវិធី១៨ សរុប ៥៣សូចនាករ សម្រេចបានតាមចំណុចដៅ ២៤ ស្មើ ៤៥,២៨ភាគរយ អាចទទួលយកបាន ២២ ស្មើ ៤១,៥១ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ៧ ស្មើ១៣,២១ភាគរយ។

### ៣.២.៣ សូចនាករលទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព

កម្រិតចង្កោមសកម្មភាព ក្រសួងបានកំណត់សូចនាករសរុប ២០៥ ក្នុងនោះចង្កោមសកម្មភាពទី១ សរុប ១២៩សូចនាករ និងចង្កោមសកម្មភាពទី២ សរុប ៧៦សូចនាករ ។ ចង្កោមសកម្មភាពទី១ សម្រេចបានតាមចំណុចដៅ ៨២ ស្មើ ៦៣,៥៧ភាគរយ អាចទទួលយកបាន ៣៣ ស្មើ ២៥,៥៨ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ១៤ ស្មើ ១០,៨៥ភាគរយ។ ចង្កោមសកម្មភាពទី២ សម្រេចបានតាមចំណុចដៅ ៤៨ ស្មើ ៦៣,១៦ភាគរយ អាចទទួលយកបាន ១៧ ស្មើ ២២,៣៧ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ១១ ស្មើ ១៤,៤៧ភាគរយ។

**រូបភាពទី៧ ៖ វឌ្ឍនភាពនៃការសម្រេចសូចនាករលទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព**




## ៤. លទ្ធផលសម្រេចបានតាមកម្មវិធី និងអនុកម្មវិធី ប្រចាំឆ្នាំ

### ៤.១ កម្មវិធីទី ១ ៖ ការអភិវឌ្ឍអប់រំចំណេះទូទៅ និងអប់រំក្រៅប្រព័ន្ធ

លទ្ធផលសម្រេចបានសូចនាករកម្មវិធីទី១

- អត្រាចូលរៀនកុមារអាយុ៥ឆ្នាំគ្រប់រូបភាពចំណុចដៅ ៦៣,១ភាគរយ សម្រេចបាន ៦៤,៨ភាគរយ
- អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាចំណុចដៅ ៨៧,៥ភាគរយ សម្រេចបាន ៨៦,៨ភាគរយ
- អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ចំណុចដៅ ៥៣,១ភាគរយ សម្រេចបាន ៥៥,៧ភាគរយ
- អត្រាអក្ខរកម្មពេញវ័យ (អាយុ១៥ ឆ្នាំឡើង) ចំណុចដៅ ៩០,៧ភាគរយ សម្រេចបាន ៨៤,៧ភាគរយ។

**រូបភាពទី ៨ ៖ វឌ្ឍនភាព នៃការសម្រេចបានសូចនាករអនុកម្មវិធីតាមអង្គភាព (កម្មវិធីទី១)**



## ការសម្រេចបានតាមអនុកម្មវិធី

### អនុកម្មវិធី ១.១៖ ការពង្រីកការអប់រំកុមារតូច (នាយកដ្ឋានអប់រំកុមារតូច)

សកម្មភាពសរុប ១៩ ក្នុងនោះអនុវត្តចប់ ១៩ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំសរុប ២ ក្នុងនោះសម្រេចតាមចំណុចដៅ ២ ស្មើ ១០០ភាគរយ។

### លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី

- អត្រាចូលរៀនកុមារអាយុ ៥ឆ្នាំនៅមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងឯកជន ចំណុចដៅ ៦៣,១ភាគរយ សម្រេចបាន ៦៤,៨ភាគរយ
- អត្រារួមនៃការសិក្សានៅមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងមត្តេយ្យសិក្សាឯកជន ចំណុចដៅ ៣៧,៤ភាគរយ សម្រេចបាន ៣៧,១ភាគរយ។

### លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព

- ចំនួនមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ចំណុចដៅ១ ៣៥០ សម្រេចបាន ១ ៣០៥
- ចំនួនសាលាមត្តេយ្យសិក្សាធនធាន សម្រេចបានតាមលក្ខណៈស្តង់ដា ចំណុចដៅ៤ សម្រេចបាន ១០
- ចំនួនសាលាមត្តេយ្យសិក្សារដ្ឋ បានអនុវត្តការគ្រប់គ្រងសាលារៀនសម្រាប់មត្តេយ្យសិក្សា ២១៣ សម្រេចបាន ២១៣។

### បញ្ហាប្រឈម

- សមត្ថភាពបុគ្គលិកមិនទាន់ឆ្លើតបតាមក្របខណ្ឌគុណវុឌ្ឍិផ្នែកអប់រំកុមារតូច។

### អនុកម្មវិធី ១.២៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា (នាយកដ្ឋានអប់រំបឋមសិក្សា)

សកម្មភាពសរុប ២៨ ក្នុងនោះអនុវត្តចប់ ១២ ស្មើ ៤២,៨៦ភាគរយ កំពុងអនុវត្ត ៥ ស្មើ ១៧,៨៦ភាគរយ មិនបានអនុវត្ត ១១ ស្មើ ៣៩,២៩ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ ក្នុងនោះសម្រេចតាមចំណុចដៅ ១ ស្មើ ៣៣,៣៣ភាគរយ អាចទទួលយកបាន ២ ស្មើ ៦៦,៦៧ភាគរយ។

### លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី

- អត្រាពិតនៃការសិក្សា ចំណុចដៅ ៩៣ភាគរយ សម្រេចបាន ៩៣ភាគរយ
- អត្រាត្រួតថ្នាក់ ចំណុចដៅ ៥ភាគរយ សម្រេចបាន ៧ភាគរយ
- អត្រាបោះបង់ការសិក្សា ចំណុចដៅ ៦ភាគរយ សម្រេចបាន ៧ភាគរយ។

### លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព

- ចំនួនបុគ្គលិកអប់រំបឋមសិក្សាទទួលការបំប៉នសមត្ថភាពបន្ថែមលើវិធីសាស្ត្ររៀននិងបង្រៀន ចំណុចដៅ ១០ ០០០ សម្រេចបាន ៩ ៨៧៥
- ចំនួនមន្ត្រីអប់រំបឋមសិក្សាបានទទួលការបំប៉នសមត្ថភាពលើការគាំទ្រការគ្រប់គ្រងតាមសាលារៀន ៥០០ សម្រេចបាន ៦៥០។

### បញ្ហាប្រឈម

- ខ្វះមន្ត្រីជាពិសេសអ្នកជំនាញភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន។

### អនុកម្មវិធី ១.៣៖ ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំ នៅមធ្យមសិក្សា (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ)

សកម្មភាពសរុប ៦ ក្នុងនោះ អនុវត្តចប់ ៥ ស្មើ ៨៣,៣៣ភាគរយ មិនបានអនុវត្ត ១ ស្មើ ១៦,៦៧ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចតាមចំណុចដៅ ២ ស្មើ ៤០ភាគរយ អាចទទួលយកបាន ២ ស្មើ ៤០ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ១ ស្មើ ២០ភាគរយ។

#### *លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ  ចំណុចដៅ ៧០,៤ភាគរយ សម្រេចបាន ៦៤,៨ភាគរយ
- អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ចំណុចដៅ ៣៨,៦ភាគរយ សម្រេចបាន ៤៤,២ភាគរយ
- អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិចំណុចដៅ ៨៤,៧ភាគរយ សម្រេចបាន៨៣,៧ភាគរយ
- អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ចំណុចដៅ ៥៣,១ភាគរយ សម្រេចបាន ៥៥,៧ភាគរយ
- អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិចំណុចដៅ ១៤,១ភាគរយ សម្រេចបាន១៧,២ភាគរយ។

#### *លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព*

- ភាគរយបេក្ខជនប្រឡងជាប់សញ្ញាបត្រថ្នាក់ពីរភាសា បារាំង-ខ្មែរ ចំណុចដៅ បឋមភូមិ ៧៦,២ភាគរយ សម្រេចបាន ៧៥,៦ភាគរយ និង ទុតិយភូមិ ៨១,១ភាគរយ សម្រេចបាន ៦៨ភាគរយ
- ចំនួនសាលារៀនបានចុះជួយចំណុចដៅ ១៥០ សម្រេចបាន១៨០ភាគរយ
- ចំនួនសាលារៀនជំនាន់ថ្មី ចំណុចដៅ ៧សាលា សម្រេចបាន ៧សាលា។

#### *បញ្ហាប្រឈម*

- អង្គភាពទើបទទួលបានថវិកាសម្រាប់ដំណើរការកម្មវិធីនៅចុងត្រីមាសទី៤។

### អនុកម្មវិធី ១.៤៖ ការពង្រីកការអប់រំក្រៅប្រព័ន្ធ (នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ)

សកម្មភាពសរុប ១៨ ក្នុងនោះ អនុវត្តចប់ ១៨ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចតាមចំណុចដៅ ៤ ស្មើ ៨០ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ១ ស្មើ ២០ភាគរយ។

#### *លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- ប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម ចំណុចដៅ ១៥ ៧០០ នាក់ សម្រេចបាន ១ ៥៥០០នាក់
- សិស្សបានបញ្ចប់ថ្នាក់កម្មវិធីសមមូល ចំណុចដៅ ៣ ៣០០នាក់ សម្រេចបាន ៣ ១០០នាក់
- ចំនួនកុមារបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញនិងបានបញ្ជូនទៅក្នុងប្រព័ន្ធ ចំណុចដៅ ៣ ២៤៤នាក់ សម្រេចបាន ២ ០០០នាក់
- ចំនួនអ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាល ជំនាញមុខរបរសម្រាប់ការសិក្សាពេញមួយជីវិត ចំណុចដៅ ៨ ៦៩០នាក់ សម្រេចបាន ៩ ៥០០នាក់
- ចំនួនមន្ត្រីអកប.ទទួលការបណ្តុះបណ្តាលសមត្ថភាពការគ្រប់គ្រងលើសេវាអ.ក.ប ចំណុចដៅ ១៣០នាក់ សម្រេចបាន ៦០នាក់។

#### *លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព*

- ចំនួនកម្មករ កម្មការិនីដែលបានបញ្ចប់ថ្នាក់អក្ខរកម្មនៅតាមរោងចក្រសហគ្រាស ចំណុចដៅ ៤០០នាក់ សម្រេចបាន ៤៥០នាក់

- ចំនួនអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់អក្ខរកម្មនៅតាមសហគមន៍ ពន្ធធនាគារ និងមណ្ឌលកែប្រែ ចំណុចដៅ ១៥ ៣០០ សម្រេចបាន ១៥ ០០០នាក់
- អ្នកសិក្សាដែលបានបញ្ចប់ថ្នាក់សមមូលបឋមសិក្សា ចំណុចដៅ ៣ ០០០នាក់ សម្រេចបាន ២ ៩០០នាក់
- ចំនួនអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់សមមូលមធ្យមសិក្សា ៣០០នាក់ សម្រេចបាន ២០០នាក់
- ចំនួនកុមារដែលបានបញ្ជូនចូលរៀនសាលាចំណេះទូទៅក្នុងប្រព័ន្ធ ៣ ២៤៤នាក់ សម្រេចបាន ២ ០០០នាក់
- ចំនួនអ្នកសិក្សាដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញមុខរបរងាយៗ ចំណុចដៅ ៨ ៦៩០នាក់ សម្រេចបាន ៩ ៥០០នាក់
- ចំនួនមន្ត្រីអប់រំក្រៅប្រព័ន្ធទទួលការបណ្តុះបណ្តាលលើការធ្វើផែនការ និងការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ ចំណុចដៅ ១៣០នាក់ សម្រេចបាន ២៥០នាក់
- ចំនួនស្រុកដែលអនុវត្តបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ ១៣០ ក្រុង ស្រុក សម្រេចបាន ៦០ ក្រុង ស្រុក។

### អនុកម្មវិធី ១.៩៖ ការពង្រឹងនិងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា(នាយកដ្ឋានសុខភាពសិក្សា)

សកម្មភាពសរុប ១៣ ក្នុងនោះ អនុវត្តចប់ ១២ ស្មើ ៩២,៣១ភាគរយ មិនបានអនុវត្ត ១ ស្មើ ៧,៦៩ភាគរយ។ សូចនាករសរុប ៧ ក្នុងនោះសម្រេចតាមចំណុចដៅ ៦ ស្មើ ៨៥,៧១ភាគរយ អាចទទួលយកបាន ១ ស្មើ ១៤,២៩ ភាគរយ។

### *លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ១ (ចំណាត់ថ្នាក់ផ្កាយ ១) ចំណុចដៅ ៣៦,១ភាគរយ សម្រេចបាន ៣២,១៥ភាគរយ
- ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ២ (ចំណាត់ថ្នាក់ផ្កាយ ២) ចំណុចដៅ ៤១,៤ភាគរយ សម្រេចបាន ៤៥,១៨ភាគរយ
- ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ៣ (ចំណាត់ថ្នាក់ផ្កាយ៣) ចំណុចដៅ ៤,៨ភាគរយ  សម្រេចបាន ៦,២៧ភាគរយ
- ភាគរយសាលារៀនមានបង្គន់អនាម័យ ចំណុចដៅ ៨៨,៨ភាគរយ  សម្រេចបាន ៩៩,៩០ភាគរយ
- ភាគរយសាលារៀនមានទឹកស្អាត ចំណុចដៅ ៧៩,៩ភាគរយ សម្រេចបាន ៨៣,១០ភាគរយ
- ភាគរយសាលារៀនមានកន្លែងលាងសម្អាតដៃ ចំណុចដៅ ៨១,៨ភាគរយ សម្រេចបាន ៨៥,៦០ភាគរយ
- ភាគរយសាលារៀនមានប្រអប់សង្គ្រោះបឋម ចំណុចដៅ ៤៣ភាគរយ សម្រេចបាន ៥៦,១០ភាគរយ។

### *លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព*

- ចំនួនគរុសិស្ស គរុនិស្សិត មន្ត្រីតែងតាំងស៊ីប់ និងនិស្សិតជាប់អាហារូបករណ៍បានពិនិត្យសុខភាព និងកាយសម្បទា ចំណុចដៅ ៦០០នាក់ សម្រេចបាន ៨៨៥នាក់
- ចំនួនគ្រឹះស្ថានសិក្សាចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីលើកកម្ពស់សុខភាពសិក្សា ចំណុចដៅ ១០រាជធានី ខេត្ត សម្រេចបាន ១៣រាជធានី ខេត្ត
- ចំនួនមន្ត្រីបានចូលរួម សិក្ខាសាលា វគ្គបណ្តុះបណ្តាល វគ្គបំប៉ន និងកិច្ចប្រជុំ ក្នុងនិងក្រៅប្រទេស ចំណុចដៅ ៧០០នាក់ សម្រេចបាន២៩០នាក់
- ចំនួនសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព (ស.ភ.សិស្ស និងស.ភ.គ្រូ) បានបោះពុម្ពតាមកម្រិតថ្នាក់" ចំណុចដៅ ១ ៣៦០ក្បាល សម្រេចបាន ២៨៤ ៦៩៩ក្បាល

- ចំនួនមន្ត្រីសុខភាពសិក្សាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានចូលរួមការអប់រំផ្សព្វផ្សាយអំពីការលើកកម្ពស់សុខភាពសិក្សា" ចំណុចដៅ ៥០០ក្បាល សម្រេចបាន ២ ៣៧២ក្បាល
- ចំនួនសិស្សានុសិស្សនៅតាមគ្រឹះស្ថានសិក្សា បានចូលរួមការអប់រំផ្សព្វផ្សាយការអប់រំសុខភាព និងប្រធានបទសុខភាពសាធារណៈ ចំណុចដៅ ២ ០០០ សម្រេចបាន ២ ៦៨៧នាក់។

*បញ្ហាប្រឈម*

- សម្ភារៈអេឡិចត្រូនិក និង ICT មួយចំនួនមានសភាពចាស់ទ្រុឌទ្រោម និងហួសសម័យ
- ខ្វះមន្ត្រីជំនាញផ្នែកវិទ្យាសាស្ត្រសុខាភិបាលនិងសុខភាពសាធារណៈ និងសម្ភារៈអេឡិចត្រូនិក
- ខ្វះថវិកាផ្សព្វផ្សាយ ស្តីពីការលើកកម្ពស់សុខភាពសិក្សា បន្ទប់សុខភាពនិងការពិនិត្យតាមដាន។

### អនុកម្មវិធី ១.៦៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស (នា.គទវ)

សកម្មភាពសរុប ១២ ក្នុងនោះ អនុវត្តចប់ ២ ស្មើ ១៦,៦៧ភាគរយ កំពុងអនុវត្ត ៤ ស្មើ ៣៣,៣៣ភាគរយ មិនបានអនុវត្ត ៦ ស្មើ ៥០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងនោះសម្រេចតាមចំណុចដៅ ១ ស្មើ ១០០ភាគរយ ។

*លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- ចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ចំណុចដៅ ១៩ សាលា សម្រេចបាន ១៩សាលា។

*លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព*

- សិស្សក្នុងការអប់រំបច្ចេកទេស ចំណុចដៅ ៤ ៣២៥នាក់ សម្រេចបាន ៣ ០៣៣នាក់
- ចំនួនសាលារៀនអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន ចំណុចដៅ ១៩០នាក់ សម្រេចបាន ៦៧៨ នាក់
- ចំនួនគ្រឹះស្ថានមធ្យមសិក្សាទទួលបានការបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ឯកសារណែនាំស្តីពីការជ្រើសរើសប្រភេទថ្នាក់វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម ឬជំនាញបច្ចេកទេសវិជ្ជាជីវៈ ចំណុចដៅ៩៨សាលា សម្រេចបាន ៩៨សាលា។

*បញ្ហាប្រឈម*

- ការទម្លាក់ថវិកាយឺតសម្រាប់ដំណើរការកម្មវិធីនៅចុងត្រីមាស សម្រាប់ឆមាសទី១។

### អនុកម្មវិធី ១.៧៖ ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងរៀត្រឹតការគ្រូបង្រៀន (នា.បវ)

សកម្មភាពសរុប ១៦ ក្នុងនោះ អនុវត្តចប់ ១៥ ស្មើ ៩៣,៧៥ភាគរយ កំពុងអនុវត្ត ១ ស្មើ ៦,២៥ភាគរយ។

*លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- ចំនួនគរុសិស្ស គរុនិស្សិត ៣០០០ នាក់បានទទួលការបណ្តុះបណ្តាល សម្រេចបានតាមចំណុចដៅ
- ចំនួនមន្ត្រីគ្រប់គ្រងអប់រំ និងនាយក នាយករង គ្រូបង្រៀន បឋមសិក្សាមធ្យមសិក្សាចំណេះទូទៅចំនួន ៣៥១ នាក់បានទទួលការលើកកម្ពស់សមត្ថភាពសម្រេចបានតាមចំណុចដៅ
- ចំនួនគ្រូបឋមសិក្សា និងមត្តេយ្យសិក្សាបានតំឡើង គុណវុឌ្ឍិទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំណុចដៅ ១៥០០ សម្រេចមិនបានតាមចំណុចដៅ។

*លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព*

- ចំនួនគរុសិស្ស គរុនិស្សិតត្រូវបានជ្រើសរើសតាមប្រព័ន្ធ ១២+២ និង ១២+៤ និងទទួលការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ចំណុចដៅ ៣ ០០០នាក់ សម្រេចបាន ៣ ០០០នាក់

- ចំនួនឯកសារបោះពុម្ពសម្រាប់វគ្គវិក្រឹតការដំឡើងគុណវុឌ្ឍិគ្រូបឋមសិក្សា និងមត្តេយ្យសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំណុចដៅ ៧ ៦៣០នាក់ សម្រេចបាន ៧ ៦៣០នាក់
- ចំនួននាយកសាលារៀនចំណោះទូទៅបានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន ចំណុចដៅ ៤០នាក់ សម្រេចបាន ៥៤នាក់
- ចំនួនមន្ត្រីអប់រំ គ្រូឧទ្ទេស និងគ្រូបង្រៀនទទួលបានការលើកកម្ពស់សមត្ថភាព ចំណុចដៅ ៣១១នាក់ សម្រេចបាន ៣១១នាក់
- ចំនួនគ្រូបឋមសិក្សានិងមត្តេយ្យសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចូលរួមវគ្គវិក្រឹតការដើម្បីដំឡើងគុណវុឌ្ឍិទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំណុចដៅ ១ ៥០០នាក់ សម្រេចបាន ០។

***បញ្ហាប្រឈម***

- កង្វះមន្ត្រីជំនាញព័ត៌មានវិទ្យា និងកម្មវិធីសិក្សា។

### អនុកម្មវិធី ១.៨៖ ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារៈសិក្សា និងបណ្ណាល័យ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា)

សកម្មភាពសរុប ១៣ ក្នុងនោះ អនុវត្តចប់ ៦ ស្មើ ៤៦,១៥ភាគរយ កំពុងអនុវត្ត ៦ ស្មើ ៤៦,១៥ភាគរយ មិនបានអនុវត្ត ១ ស្មើ ៧,៦៩ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចតាមចំណុចដៅ ២ ស្មើ ១០០ ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ចំនួនសៀវភៅសិក្សាគោលត្រូវបានផ្គត់ផ្គង់សម្រាប់សិស្សថ្នាក់ទី១ដល់ទី១២ ចំណុចដៅ ៥ ២៧៦ ០០០ ច្បាប់ សម្រេចបាន ៥ ៣៥៣ ០០០ច្បាប់
- ចំនួនសិស្សចូលរួមប្រកួតតែងនិពន្ធ សូត្រកំណាព្យនិងសម្តែងសិល្បៈក្នុងទិវាជាតិអំណាន ១១មីនា សម្រេចបានតាមចំណុចដៅ ៧៥នាក់។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនសៀវភៅសិក្សាគោល ដែលសិស្សទទួលបានតាមផលធៀប១:១ សម្រាប់ថ្នាក់ទី១-៩ និង២:១ សម្រាប់មធ្យមសិក្សាទុតិយភូមិសម្រាប់ថ្នាក់ទី១០-ទី១២ ចំណុចដៅ ៥ ២៧៦ ០០០ច្បាប់ សម្រេចបាន ៥ ៣៥៣ ០០០ច្បាប់
- ចំនួនសាលារៀនទទួលបានពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីសិក្សានិងផ្សព្វផ្សាយ ចំណុចដៅ ១០០ សម្រេចបាន ១៦៧
- ចំនួនឯកសារគរុកោសល្យនិងកម្មវិធីសិក្សា ចំណុចដៅ ២ចំណងជើង សម្រេចបាន ២ចំណងជើង
- ចំនួនសិស្សចូលរួមប្រកួតតែងនិពន្ធ សូត្រកំណាព្យ និងសម្តែងសិល្បៈក្នុងទិវាជាតិអំណាន ១១មីនា ចំណុចដៅ ៧៥នាក់ សម្រេចបាន ៧៥នាក់។

***បញ្ហាប្រឈម***

- ការប្រើប្រាស់ប្រព័ន្ធ TnT នៅមានកំណត់ចំនួនអ្នកចូលប្រើប្រាស់
- នាយកសាលានិងបណ្ណារក្សមិនទាន់អាចធ្វើតម្រូវការសៀវភៅសិក្សាបានត្រឹមត្រូវ ហើយសាលារៀនមួយចំនួនមិនទាន់មានបណ្ណារក្ស។

### អនុកម្មវិធី ១.៩៖ ពង្រីកការអប់រំបរិយាបន្នគ្រប់តួមិសិក្សា(នាយកដ្ឋានអប់រំពិសេស)

សកម្មភាពសរុប ១៤ ក្នុងនោះ អនុវត្តចប់ ១១ ស្មើ ៧៨,៥៧ភាគរយ កំពុងអនុវត្ត ៣ ស្មើ ២១,៤៣ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំសរុប ៣ ក្នុងនោះសម្រេចតាមចំណុចដៅ ២ ស្មើ ៦៦,៦៧ភាគរយ អាចទទួលយកបាន ១ ស្មើ ៣៣,៣៣ភាគរយ។

#### *លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- ចំនួនគ្រូបង្រៀនថ្នាក់អប់រំពហុភាសាសម្រាប់បឋមសិក្សា ចំណុចដៅ ២៤២ សម្រេចបាន ២៣៥
- ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធ បានកសាងសមត្ថភាពស្តីពីការអប់រំបរិយាបន្ន និងអប់រំពិសេសចំណុចដៅ ១២០ សម្រេចបាន ២២៤
- ចំនួនសិស្សមានពិការភាព( គ ថ្លង់ ពិការភ្នែក និងសតិបញ្ញា...) ដែលបានរៀននៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្ម ចំណុចដៅ ១ ០០៣ សម្រេចបាន ១ ០៥៩។

#### *លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព*

- ចំនួនគ្រូ និងអ្នកពាក់ពន្ធ័អប់រំពហុភាសាត្រូវបានទទួលវគ្គបំប៉នសមត្ថភាពស្តីពីការអប់រំពហុភាសា ចំណុចដៅ ៣០នាក់ សម្រេចបាន ៣៤នាក់
- ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធត្រូវបានកសាងសមត្ថភាពស្តីពីការអប់រំបរិយាបន្ន និងអប់រំពិសេស" ចំណុចដៅ ១២០នាក់ សម្រេចបាន ១២០នាក់
- ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធត្រូវបានបណ្តុះបណ្តាលជំនាញអប់រំពិសេស ស្តីពីការអប់រំពិសេស សម្រាប់បង្រៀននៅវិទ្យាល័យអប់រំពិសេស ចំណុចដៅ ២០ សម្រេចបាន ៣០។

#### *បញ្ហាប្រឈម*

- គ្រូបង្រៀននៅវិទ្យាល័យអប់រំពិសេសនិងថ្នាក់សមាហរណកម្មមិនទាន់បានបំប៉នសមត្ថភាពវិធីសាស្ត្របង្រៀននិងបច្ចេកទេសថ្មីៗឆ្លើយតបនឹងតម្រូវការ
- ខ្វះថវិកាគាំទ្រការអនុវត្តកម្មវិធីអប់រំបរិយាបន្នគ្រប់ភូមិសិក្សា និងគ្រូបង្រៀនថ្នាក់អប់រំពហុភាសា
- ការផលិតសៀវភៅសិក្សាភាសាចារាយ មិនទាន់សម្រេចបានតាមការគ្រោងទុក។

### អនុកម្មវិធី ១.១០៖ ការគាំទ្រអប់រំបរិយាបន្ន (វិទ្យាស្ថានជាតិអប់រំពិសេស)

#### *លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព*

- ចំនួនគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលកម្រិតឌីប្លូម៉ាស្តីពីការអប់រំបរិយាបន្ននៅវិទ្យាស្ថានជាតិអប់រំពិសេសចំនួន៣០នាក់ក្នុងឆ្នាំសិក្សា២០២៣ ចំណុចដៅ ៣០នាក់ សម្រេចបាន ២៣
- វិក្រិតការគ្រូបង្រៀនសិស្សពិការភ្នែក និងគថ្លង់នៅតាមវិទ្យាល័យអប់រំពិសេសទាំង៥ចំនួន១៥១នាក់ ចំណុចដៅ ២៦៥នាក់ សម្រេចបាន ១៨៥នាក់
- យ៉ាងហោចណាស់សិស្សមានពិការភាពចំនួន៥០០នាក់ ទទួលបានការត្រួតពិនិត្យ និងបំពាក់ឧបករណ៍ជំនួយដល់សិស្សពិការភ្នែក និងគថ្លង់នៅវិទ្យាល័យអប់រំពិសេសទាំង៥ ចំនួន២ដងក្នុង១ឆ្នាំ ចំណុចដៅ ៥០០នាក់ សម្រេចបាន ១ ១៩៤នាក់
- ឯកសារបណ្តុះបណ្តាលចំនួន២ ត្រូវបានផលិតឡើងសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនសិស្សមានបញ្ហាស្តាប់ និងអ្នកបកប្រែភាសាសញ្ញា ចំណុចដៅ ២ឯកសារ សម្រេចបបាន ២ឯកសារ
- វិទ្យាស្ថានជាតិអប់រំពិសេសមានថវិកាគាំទ្រការសិក្សាស្រាវជ្រាវ និងសម្ភារសម្រាប់ស្នាក់នៅសម្រាប់គរុសិស្ស ចំណុចដៅ ៨០សញ្ញា សម្រេចបាន ២៤០សញ្ញា។

## ៤.២. កម្មវិធីទី ២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ

លទ្ធផលសម្រេចបានសូចនាករកម្មវិធីទី២

- អត្រាសរុបនៃការសិក្សានៅឧត្តមសិក្សា (១៨-២២) ចំណុចដៅ ១៥,៧ភាគរយ សម្រេចបាន ១៥,២ភាគរយ
- ភាគរយនិស្សិតចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលស្ទែម ចំណុចដៅ ៣៣,២ភាគរយ សម្រេចបាន ២៨ភាគរយ។

រូបភាពទី ៩៖ វឌ្ឍនភាព នៃការសម្រេចបានសូចនាករអនុកម្មវិធីតាមអង្គភាព (កម្មវិធីទី២)




### ការសម្រេចបានតាមអនុកម្មវិធី

#### អនុកម្មវិធី ២.១៖ ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា (នាយកដ្ឋានឧត្តមសិក្សា)

សកម្មភាពសរុប ៥០ ក្នុងនោះ អនុវត្តចប់ ៤៣ ស្មើ ៨៦ភាគរយ កំពុងអនុវត្ត ៤ ស្មើ ៨ភាគរយ មិនបានអនុវត្ត ៣ ស្មើ ៦ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចតាមចំណុចដៅ ៥ ស្មើ ១០០ភាគរយ។

#### *លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- ចំនួនគ្រឹះស្ថានឧត្តមសិក្សាអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងចំណុចដៅ ២៥ សម្រេចបាន ៣៣
- ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានរៀបចំ និងអនុវត្តការតាំរបស់និស្សិតចំណុចដៅ ១៦ សម្រេចបាន ២៤
- ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានធ្វើការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់សិក្សាចំណុចដៅ១០ សម្រេចបាន ២២
- ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងទិន្នន័យឧត្តមសិក្សា ចំណុចដៅ៣៣ សម្រេចបាន ៤៩
- ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលអនុវត្តកម្មវិធីបណ្តាញសាកលវិទ្យាល័យសាយប័រចំណុចដៅ ៦ សម្រេចបាន៦។

#### *លទ្ធផលក្នុងឆ្នាំកម្រិតបង្គោលសកម្មភាព*

- ចំនួនកម្មវិធីសិក្សាតាមមុខជំនាញដែលបានកែលម្អដោយផ្តោតលើលទ្ធផលរំពឹងទុកស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ ចំណុចដៅ ១២០ សម្រេចបាន ១៣០

- ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានរៀបចំការប្រឡងជ្រើសរើសនិស្សិតចូលរៀនថ្នាក់បរិញ្ញាបត្ររង/បរិញ្ញាបត្រ និងប្រឡង ឬការការពារសារណាបញ្ចប់ការសិក្សាតាមគោលការណ៍ណែនាំ ចំណុចដៅ ៩៤ សម្រេចបាន ៩៥
- ចំនួនសិស្សចូលរួមកម្មវិធីភាពជាដៃគូក្នុងស្រុកសម្រាប់ការអប់រំស្វែមបន្តការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សាគោលដៅ ចំណុចដៅ ៤ ៥៣០ សម្រេចបាន ៣៩១
- ចំនួនគ្រឹះស្ថានឧត្តមសិក្សាគោលដៅរៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ចំណុចដៅ ៩ សម្រេចបាន ៦
- ចំនួនគ្រឹះស្ថានឧត្តមសិក្សាគោលដៅរៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុងរបស់គ្រឹះស្ថាន ចំណុចដៅ ៩ សម្រេចបាន ៦។

***បញ្ហាប្រឈម***

- ការរៀបចំផែនការមិនបានលម្អិតសម្រាប់អនុវត្តផែនការប្រតិបត្តប្រចាំឆ្នាំ។

**អនុកម្មវិធី ២.២៖ ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា (នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ)**

សកម្មភាពសរុប ១៧ ក្នុងនោះ អនុវត្តចប់ ១៧ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ ក្នុងនោះ សម្រេចតាមចំណុចដៅ ៣ ស្មើ ១០០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ភាគរយនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដោយការសរសេររបាយការណ៍ស្រាវជ្រាវសរសេរ ឬនិក្ខេបបទធៀបនឹងនិស្សិតបញ្ចប់ក្នុងឆ្នាំ ចំណុចដៅ ១៤ភាគរយ សម្រេចបាន ១៩,៣៦ភាគរយ
- ចំនួនគ្រឹះស្ថានដែលរៀបចំ និងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងស្នាដៃស្រាវជ្រាវ និងការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រចំណុចដៅ ១០គ្រឹះស្ថាន សម្រេចបាន ១០គ្រឹះស្ថាន
- ចំនួនបុគ្គលិកបង្រៀន មន្ត្រីជំនាញ និងនិស្សិតដែលចូលរួមអភិវឌ្ឍសមត្ថភាពក្នុងការរៀបចំ និងអនុវត្តគម្រោងស្រាវជ្រាវ និងនវានុវត្តន៍ចំណុចដៅ ៣៧នាក់ សម្រេចបាន ៣៩នាក់។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនគ្រឹះស្ថានឧត្តមសិក្សា ត្រូវបានពិនិត្យ និងវាយតម្លៃលើការបណ្តុះបណ្តាល ចំណុចដៅ ២៤គ្រឹះស្ថាន សម្រេចបាន ៤៥គ្រឹះស្ថាន
- ចំនួនគ្រឹះស្ថានដែលរៀបចំ និងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងស្នាដៃស្រាវជ្រាវ និងការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ ចំណុចដៅ ១០គ្រឹះស្ថាន សម្រេចបាន ១០គ្រឹះស្ថាន
- ចំនួនមន្ត្រីអប់រំ និងអ្នកស្រាវជ្រាវបានចូលរួមសិក្ខាសាលាស្តីពីកម្មវិធីមគ្គុទេសស្រាវជ្រាវនៅឧត្តមសិក្សា ចំណុចដៅ ៣៥នាក់ សម្រេចបាន ៤០នាក់
- ចំនួនបុគ្គលិកបង្រៀន មន្ត្រីជំនាញ និងនិស្សិតដែលចូលរួមអភិវឌ្ឍសមត្ថភាពក្នុងការរៀបចំ និងអនុវត្តគម្រោងស្រាវជ្រាវ និងនវានុវត្តន៍ ចំណុចដៅ ៣៧នាក់ សម្រេចបាន ៣៩នាក់។

***បញ្ហាប្រឈម***

- ការទូទាត់ថវិកាស្មុគស្មាញ
- កង្វះមន្ត្រីជំនាញផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ ហិរញ្ញវត្ថុ និងព័ត៌មានវិទ្យា ព្រមទាំងសម្ភារៈអេឡិចត្រូនិក។

### អនុកម្មវិធី ២.៣៖ ការពង្រឹងគុណភាពអប់រំ និងស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព(សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)

សកម្មភាពសរុប ២៤ ក្នុងនោះ អនុវត្តចប់ ២៣ ស្មើ ៩៥,៨៣ភាគរយ មិនបានអនុវត្ត ១ ស្មើ៤,១៧ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងនោះសម្រេចបានតាមចំណុចដៅ ១ ស្មើ ១០០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ភាគរយនិស្សិតអាហារូបករណ៍និងបង់ថ្លៃ(ឆ្នាំទី៤)ប្រឡងជាប់បរិញ្ញាបត្រចំណុចដៅ៩៥ភាគរយ សម្រេចបាន ៩៥ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនប្រព័ន្ធចម្រោះទឹកក្រោមដីខ្នាតតូច និងមធ្យមត្រូវបានបង្កើតនៅ Outdoor Lab. របស់ សភភព (គម្រោងថ្មី ចប់ក្នុងឆ្នាំ២០២៣) ចំណុចដៅ ១គ្រឿង សម្រេចបាន ១គ្រឿង
- ចំនួនពូជដង្កូវនាងដែលបានផលិត (ចាប់ផ្តើមពី ២០១៨) ៖ ពូជសុទ្ធ ពូជពាណិជ្ជកម្ម ចំណុចដៅ ២៣ពូជសុទ្ធ ៦០ ពូជពាណិជ្ជកម្ម សម្រេចបាន ២០ពូជសុទ្ធ ៥៥ពូជពាណិជ្ជកម្ម
- ភាគរយនៃបុគ្គលិកអប់រំទទួលបានការបំប៉នសមត្ថភាពតាមមុខជំនាញ ចំណុចដៅ ៦៥ភាគរយ សម្រេចបាន ៥៧៨នាក់
- ភាគរយនិស្សិតអាហារូបករណ៍និងបង់ថ្លៃ(ឆ្នាំទី៤)ប្រឡងជាប់បរិញ្ញាបត្រ ចំណុចដៅ ៩៥ភាគរយ សម្រេចបាន ៩៥។

***បញ្ហាប្រឈម***

- ការផ្តល់ទិន្នន័យសម្រាប់រៀបចំរបាយការណ៍យឺត។

### អនុកម្មវិធី ២.៤៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំ បណ្តុះបណ្តាលនិងស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព (សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ)

សកម្មភាពសរុប ៦ ក្នុងនោះ អនុវត្តចប់ ២ ស្មើ ៣៣,៣៣ភាគរយ កំពុងអនុវត្ត ៤ ស្មើ ៦៦.៦៧ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ (វាយតម្លៃលទ្ធផលសម្រេចនៅចុងឆ្នាំ)។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ចំនួនសិស្សនិស្សិតចូលរៀនបរិញ្ញាបត្រ បរិញ្ញាបត្ររង និងគុណវុឌ្ឍិ១ ២ ៣ ទាំងអាហារូបករណ៍ និងមិនមែនអាហារូបករណ៍ត្រូវបានបង្កើនចំណុចដៅ ២ ៤៤០ នាក់ សម្រេចមិនបានចំណុចដៅ។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- កម្មវិធីសិក្សានឹងត្រូវកែលម្អតាមតម្រូវការទីផ្សារ ចំណុចដៅ ១៣ សម្រេចបាន ៦
- ភាគរយនៃបុគ្គលិកអប់រំនិងសាស្ត្រាចារ្យកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតត្រូវបានបង្កើនគុណវុឌ្ឍិ ចំណុចដៅ ១០ភាគរយ សម្រេចបាន ៦ភាគរយ។

***បញ្ហាប្រឈម***

- ខ្វះថវិកាសម្រាប់ការស្រាវជ្រាវ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ។

### អនុកម្មវិធី ២.៥៖ ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ (សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ)

សកម្មភាពសរុប ២៤ ក្នុងនោះ អនុវត្តចប់ ២២ ស្មើ ៩១,៦៧ភាគរយ មិនបានអនុវត្ត២ ស្មើ ៨,៣៣ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះ សម្រេចមិនបានតាមចំណុចដៅ ២ ស្មើ ១០០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ភាគរយនិស្សិតដែលបញ្ចប់ការសិក្សា ទទួលបានការងារធ្វើនៅតាមស្ថាប័ននានា ចំណុចដៅ៩៥ភាគរយ សម្រេចមិនបានតាមចំណុចដៅ
- ចំនួនអត្ថបទនៃការសិក្សាស្រាវជ្រាវរបស់គ្រូបុគ្គលិកអប់រំត្រូវបានបោះពុម្ពប្រចាំឆ្នាំ ចំណុចដៅ ៣អត្ថបទ។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួននិស្សិតចូលរៀននៅគ្រប់ជំនាញ និងកម្រិតសិក្សា ចំណុចដៅ ៤ ៤៥០នាក់ សម្រេចបាន ៣ ៩៣៩នាក់
- ចំនួននិស្សិតរៀនមុខវិជ្ជាវិទ្យាសាស្ត្រ STEM ចំណុចដៅ ៩១១ សម្រេចបាន ៧៦៣
- ចំនួនមន្ត្រីអប់រំបានចូលរួមវគ្គសិក្ខាសាលា និងការបណ្តុះបណ្តាលស្តីពីការងារដឹកនាំ និងគ្រប់គ្រង ចំណុចដៅ ១២០ សម្រេចបាន ២១៧។

***បញ្ហាប្រឈម***

- កង្វះថវិកាសម្រាប់ការស្រាវជ្រាវ។

## អនុកម្មវិធី ២.៦៖ ការអភិវឌ្ឍការបណ្តុះបណ្តាល និងស្រាវជ្រាវ (វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា)

សកម្មភាពសរុប ១៤ ក្នុងនោះ អនុវត្តចប់ ១៤ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ ក្នុងនោះសម្រេចតាមចំណុចដៅ ៣ ស្មើ ១០០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ភាគរយនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើ ឬបន្តការសិក្សា ចំណុចដៅ ៩០ភាគរយ សម្រេចបាន ៩២ ភាគរយ
- ចំនួនប្រធានបទស្រាវជ្រាវសរុបដែលបានបោះពុម្ពផ្សាយ ឬចូលរួមធ្វើបទបង្ហាញក្នុងសន្និសីទវិទ្យាសាស្ត្រ ចំណុចដៅ ៥៥ សម្រេចបាន ២២៥
- ភាគរយបុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិត ចំណុចដៅ ២៧,៤ភាគរយ សម្រេចបាន ២៧,៤ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ភាគរយនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើ ឬ បន្តការសិក្សា ចំណុចដៅ ៩០ភាគរយ សម្រេចបាន ៩២ ភាគរយ
- ចំនួនប្រធានបទស្រាវជ្រាវសរុបដែលបានបោះពុម្ពផ្សាយ ឬ ចូលរួមធ្វើបទបង្ហាញក្នុងសន្និសីទវិទ្យាសាស្ត្រ ចំណុចដៅ ៥៥ សម្រេចបាន ២២៥
- ភាគរយបុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិត ចំណុចដៅ ២៧,៤ភាគរយ សម្រេចបាន ២៧,៤ភាគរយ។

***បញ្ហាប្រឈម***

- ខ្វះមន្ត្រីយល់ដឹងពីរចនាសម្ព័ន្ធគោលនយោបាយ កម្មវិធី/អនុកម្មវិធី និងចង្កោមសកម្មភាព។

## អនុកម្មវិធី ២.៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ (វិទ្យាស្ថានជាតិអប់រំ)

សកម្មភាពសរុប ២២ ក្នុងនោះ អនុវត្តចប់ ២២ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចបានតាមចំណុចដៅ ១ ស្មើ ២០ភាគរយ អាចទទួលយកបាន ៤ ស្មើ ៨០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ចំនួនគរុនិស្សិតកម្រិតឧត្តម(បរិញ្ញា+១)និងគរុសិស្សកម្រិតមូលដ្ឋាន(១២+៤)បានទទួលការបណ្តុះបណ្តាលប្រចាំឆ្នាំ ចំណុចដៅ ៤៤៥ សម្រេចបាន ១០០
- ចំនួននិស្សិតថ្នាក់បណ្ឌិតបានទទួលការបណ្តុះបណ្តាលតាមឆ្នាំនីមួយៗចំណុចដៅ ៤៩ សម្រេចបាន ២៥
- ចំនួននិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិធីសាស្ត្របង្រៀនភាសាបារាំង គ្រប់គ្រងអប់រំ ប្រឹក្សាគរុកោសល្យ វិជ្ជាជីវៈនាយកសាលា អធិការអប់រំ និងគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ១ ០០៥ សម្រេចបាន ១ ០០៥
- ចំនួនមន្ត្រីគ្រប់គ្រងផែនការថ្នាក់រាជធានីខេត្ត អធិការអប់រំថ្នាក់រាជធានីខេត្ត នាយកវិទ្យាល័យ ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ទទួលបានការបំប៉ន ដើម្បីបង្កើនសមត្ថភាពវិជ្ជាជីវៈរបស់ពួកគាត់ចំណុចដៅ ១៨០ សម្រេចបាន ១២៦
- ចំនួនបុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំបានទទួលការបំប៉នសមត្ថភាពក្នុងនិងក្រៅប្រទេស ចុះធ្វើការស្រាវជ្រាវ ពិនិត្យតាមដានវាយតម្លៃលើការអនុវត្តការងាររបស់អតីតគរុនិស្សិត គ្រូបង្រៀន ពិសោធន៍វិទ្យាសាស្ត្រ និងកម្មវិធីបណ្តុះបណ្តាល ចំណុចដៅ ១៥៥ សម្រេចបាន ១០៩។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនគរុសិស្ស គរុនិស្សិត និងនិស្សិតបានទទួលបណ្តុះបណ្តាលគ្រប់វគ្គស ចំណុចដៅ ១ ៤៥០ សម្រេចបាន ១ ០១៥
- ចំនួនប្រាក់អាហារូបករណ៍សម្រាប់គរុសិស្ស និងគរុនិស្សិត ចំណុចដៅ ៥៦៩ ៣១៦ ០០០រៀល សម្រេចបាន ៥០ភាគរយ
- ចំនួនមន្ត្រីអប់រំថ្នាក់រាជធានី ខេត្ត និងគ្រូបង្រៀនបានចូលរួមគ្រប់វគ្គបំប៉ន ចំណុចដៅ ១៨០ សម្រេចបាន ១៨០
- បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំបានចុះស្រាវជ្រាវពិនិត្យតាមដាន និងចូលរួមវគ្គបំប៉នក្នុងនិងក្រៅប្រទេស ចំណុចដៅ ១៥៥ សម្រេចបាន ១៥៥។

***បញ្ហាប្រឈម***

- នីតិវិធីច្រើនក្នុងការអនុវត្តថវិកា។

### អនុកម្មវិធី ២.៨៖ ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ (សាកលវិទ្យាល័យស្វាយរៀង)

សកម្មភាពសរុប ២២ ក្នុងនោះ អនុវត្តចប់ ២១ ស្មើ ៩៥,៤៥ភាគរយ មិនបានអនុវត្ត ១ ស្មើ ៤,៥៥ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះ អាចទទួលយកបាន ២ ស្មើ ១០០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ចំនួននិស្សិតបានបញ្ចប់ការសិក្សា ស្របតាមតម្រូវទីផ្សារការងារ ចំណុចដៅ ៧០០នាក់ សម្រេចបាន ៦០៥
- ចំនួនគម្រោងស្រាវជ្រាវបានផលិតសម្រាប់បម្រើឱ្យការអភិវឌ្ឍ ចំណុចដៅ ៤គម្រោង សម្រេចបាន ៣គម្រោង។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនកម្មវិធីសិក្សាត្រូវបានកែលម្អ ឬបង្កើតថ្មី ចំណុចដៅ ៣ សម្រេចបាន ៣
- អត្រានៃសេចក្តីពេញចិត្តលើបរិស្ថានសិក្សា ចំណុចដៅ ៨០ភាគរយ សម្រេចបាន ៨០ភាគរយ
- ចំនួនរបាយការណ៍ស្វ័យវាយតម្លៃកម្រិតកម្មវិធីត្រូវបានផលិត ចំណុចដៅ ៣ សម្រេចបាន ៣

- ចំនួនអត្ថបទស្រាវជ្រាវ ត្រូវបានបោះពុម្ពផ្សាយ ឬធ្វើបទបង្ហាញ ចំណុចដៅ ៤ សម្រេចបាន ៤
- ចំនួនគម្រោងផែនការអាជីវកម្មបានចូលរួមប្រកួតប្រជែង ចំណុចដៅ ៦ សម្រេចបាន ៦។

***បញ្ហាប្រឈម***

- ពុំទាន់បានដំណើរការល្អក្នុងការអនុវត្តន៍ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់គ្រប់គ្រងការងារ
- បញ្ហានិស្សិតរៀនផ្នែក STEM មានចំនួនតិចមិនសម្រេចតាមគោលដៅ។

**អនុកម្មវិធី ២.៩៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការ បណ្តុះបណ្តាល និងការស្រាវជ្រាវ (សាកលវិទ្យាល័យជាតិមានជ័យ)**

សកម្មភាពសរុប ២៥ ក្នុងនោះ អនុវត្តចប់ ២៤ ស្មើ ៩៦ភាគរយ កំពុងអនុវត្ត ១ ស្មើ ៤ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៤ ក្នុងនោះសម្រេចតាមចំណុចដៅ ៣ ស្មើ ៧៥ភាគរយ អាចទទួលយកបាន ១ ស្មើ ២៥ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ចំនួននិស្សិតចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលវិទ្យាសាស្ត្រ និងសង្គម ចំណុចដៅ ៨០០ សម្រេចបាន ៨៦៤
- ចំនួនភាគរយនិស្សិតគ្រប់ជំនាញបញ្ចប់ការសិក្សាមានការងារធ្វើចំណុចដៅ ៨០ភាគរយ សម្រេចបាន ៧២ ភាគរយ
- ចំនួនកម្មវិធីសិក្សាតាមមុខជំនាញដែលបានកែលម្អដោយផ្តោតលើលទ្ធផលរំពឹងទុកស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ ចំណុចដៅ ២ សម្រេចបាន ២
- គ្រឹះស្ថានទទួលបានការទទួលស្គាល់គុណភាពអប់រំកម្រិតគ្រឹះស្ថាន ចំណុចដៅ ១០០ភាគរយ សម្រេចបាន ១០០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនភាគរយអនុវត្តផែនការយុទ្ធសាស្ត្រ ស្វ័យវាយតម្លៃ និងគោលការណ៍វាយតម្លៃគុណភាពផ្ទៃក្នុង ចំណុចដៅ ៨៥ភាគរយ សម្រេចបាន ៨៥ភាគរយ
- ចំនួនឯកសារសិក្សាពិសោធន៍ស្រាវជ្រាវត្រូវបានបង្កើត និងបោះពុម្ព ចំណុចដៅ ២ សម្រេចបាន ២
- ចំនួនកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ចំណុចដៅ ៥គម្រោង សម្រេចបាន ៥គម្រោង។

***បញ្ហាប្រឈម***

- ពុំទាន់បានដំណើរការល្អក្នុងការអនុវត្តន៍ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់គ្រប់គ្រងការងារ
- បញ្ហានិស្សិតរៀនផ្នែក STEM មានចំនួនតិចមិនសម្រេចតាមគោលដៅ។

**អនុកម្មវិធី ២.១០៖ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវ (សាកលវិទ្យាល័យជាតិបាត់ដំបង)**

សកម្មភាពសរុប ៨ ក្នុងនោះ អនុវត្តចប់ ៨ ស្មើ ១០០ភាគរយ មិនបានអនុវត្ត ១ ស្មើ ១១,១១ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ ក្នុងនោះសម្រេចតាមចំណុចដៅ ៣ ស្មើ ១០០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ភាគរយគ្រូបង្រៀនត្រូវបានលើកកម្ពស់គុណវុឌ្ឍិ ចំណុចដៅ ៩៥នាក់ សម្រេចបាន ៩៦នាក់
- ភាគរយនិស្សិតមានការងារស្របតាមជំនាញ ចំណុចដៅ ៧៦ភាគរយ សម្រេចបាន ៦០ភាគរយ
- ចំនួនលទ្ធផលសិក្សាស្រាវជ្រាវផ្សារភ្ជាប់នឹងទីផ្សារត្រូវបានផលិត ចំណុចដៅ ៨ សម្រេចបាន ៨។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្របានទទួលស្គាល់គុណភាពស្តង់ដារជាតិ ចំណុចដៅ ២ សម្រេចបាន ២

- ចំនួននិស្សិតបញ្ចប់ការសិក្សាផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា និងផ្នែកសង្គម (- វ.ស ១៦១នាក់ ស្រី ៧៥នាក់, សង្គម ២៧១នាក់ ស្រី ១៧៧នាក់) ចំណុចដៅ ៤៣២ សម្រេចបាន ៣៩៥
- ចំនួនគម្រោងស្រាវជ្រាវផ្សាភ្ជាប់នឹងទីផ្សារបានអនុវត្តន៍ ចំណុចដៅ ៥ សម្រេចបាន ៤
- ចំនួនបុគ្គលិកអប់រំត្រូវបានវាយតម្លៃការងារ ចំណុចដៅ ៨៦នាក់ សម្រេចបាន ៨១នាក់
- ចំនួនបុគ្គលិកសិក្សា និងសាស្ត្រាចារ្យមានគុណវុឌ្ឍិកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត (បរិ. ២នាក់, បរិ.ខ្ពស់ ៩២នាក់, បណ្ឌិត ៩នាក់) ចំណុចដៅ ១០៣ សម្រេចបាន ១០១។

***បញ្ហាប្រឈម***

- កង្វះបន្ទប់សិក្សានិងគ្រូបង្រៀនលើជំនាញស្ថាបត្យកម្ម សំណង់ អគ្គិសនី អេឡិចត្រូនិច ស្វ័យប្រវត្តិកម្ម បច្ចេកកវិទ្យាព័ត៌មាន និងមន្ត្រីរដ្ឋបាលសកម្មភាពក្នុងផែនការមិនអាចអនុវត្តតាមផែនការ
- ការចូលរួមវាយតម្លៃការបង្រៀនទាំងបីមុំនៅមានសភាពយឺតយ៉ាវ ជាហេតុធ្វើឱ្យការបូកសរុបលទ្ធផលនៃការវាយតម្លៃមិនទាន់តាមផែនការដែលបានកំណត់
- ការបណ្តុះបណ្តាលលើមុខវិជ្ជាមួយចំនួនក្នុងឆមាសទី២ ឆ្នាំសិក្សា២០២២-២០២៣ មិនអាចបញ្ចប់តាមប្រតិទិន្នដែលបានកំណត់។

### អនុកម្មវិធី ២.១៣៖ ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា (គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា)

សកម្មភាពសរុប ៩ ក្នុងនោះ អនុវត្តចប់ ៨ ស្មើ ៨៨,៨៩ភាគរយ មិនបានអនុវត្ត ១ ស្មើ ១១,១១ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងនោះ សម្រេចបានតាមចំណុចដៅ ១ ស្មើ ១០០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលទទួលបានការទទួលស្គាល់គុណភាពអប់រំចំណុចដៅ ១០គ្រឹះស្ថាន សម្រេចបាន ១០គ្រឹះស្ថាន។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលយល់ដឹង និងអាចប្រើប្រាស់សៀវភៅណែនាំ និងនិទ្ទេសបទថ្មីសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា និងអាចសរសេររបាយការណ៍ស្វ័យវាយតម្លៃបែបវិភាគ ចំណុចដៅ ៩គ្រឹះស្ថាន សម្រេចបាន ៩គ្រឹះស្ថាន
- ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលមានសមត្ថភាពអាចប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា និងតាមកម្មវិធី (ពន្យារពេលអនុវត្តនៅឆ្នាំ ២០២៤)។

***បញ្ហាប្រឈម***

- ខ្វះបន្ទប់សិក្សានិងគ្រូបង្រៀនលើជំនាញស្ថាបត្យកម្ម សំណង់ អគ្គិសនី អេឡិចត្រូនិច ស្វ័យប្រវត្តិកម្ម បច្ចេកវិទ្យាព័ត៌មាន និងមន្ត្រីរដ្ឋបាល
- សកម្មភាពក្នុងផែនការមិនអាចអនុវត្តតាមផែនការ។

### អនុកម្មវិធី ២.១៤៖ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវលើផ្នែកបច្ចេកទេស វិជ្ជាជីវៈ និងសេវាសហគមន៍ (វិទ្យាស្ថានកំពង់ឈើទាល)

សកម្មភាពសរុប ១៤ ក្នុងនោះ អនុវត្តចប់ ១២ ស្មើ ៨៥,៧១ភាគរយ កំពុងអនុវត្ត ២ ស្មើ ១៤,២៩ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចតាមចំណុចដៅ ១ ស្មើ ៥០ភាគរយ អាចទទួលយកបាន ១ ស្មើ ៥០ភាគរយ។

### *លទ្ធផលក្នុងថ្នាក់កម្រិតអនុកម្មវិធី*

- ចំនួនសិស្ស និស្សិត គរុសិស្សទទួលបានការបណ្តុះបណ្តាលប្រកបដោយគុណភាព និងបរិយាបន្ន ស្រប តាមការអភិវឌ្ឍនៃបច្ចេកវិទ្យា ចំណុចដៅ ១ ២៥០ សម្រេចបាន ១ ១៤៧
- ភាគរយបុគ្គលិកសិក្សាគ្រប់រូបមានសមត្ថភាពនិងគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន ចំណុចដៅ ១០០ភាគរយ សម្រេចបាន ៩០ភាគរយ។

### *លទ្ធផលក្នុងថ្នាក់កម្រិតចង្កោមសកម្មភាព*

- ចំនួនសិស្ស និស្សិត គរុសិស្ស ទទួលបានអាហារូបករណ៍ឱ្យចូលរៀនមិនបង់ថ្លៃ ចំណុចដៅ ១ ២៥០ សម្រេចបាន ១ ១៤៧
- ភាគរយសិស្ស និស្សិត គរុសិស្សបញ្ចប់ការសិក្សា ដោយជោគជ័យ ចំណុចដៅ ១០០ភាគរយ សម្រេចបាន ៩០ភាគរយ
- ភាគរយសិស្ស និងនិស្សិត ដែលបានបញ្ចប់ការសិក្សា ទទួលបានការងារធ្វើ/បន្តការសិក្សា ចំណុចដៅ ៨០ ភាគរយ សម្រេចបាន ៩០ភាគរយ
- ភាគរយបុគ្គលិកសិក្សាពេញម៉ោងបានបង្កើនគុណវុឌ្ឍិខ្ពស់ជាងបរិញ្ញាបត្រ ចំណុចដៅ ៤០ភាគរយ សម្រេចបាន ៣៦ភាគរយ។

### *បញ្ហាប្រឈម*

- ការទម្លាក់ថវិកាយឺតសម្រាប់សាងសង់អគារសិក្សា និងអគារពិសោធន៍
- សមត្ថភាពមន្ត្រីនៅមានកម្រិតក្នុងការប្រើប្រាស់ឧបករណ៍ទំនើបថ្មីៗ។

### អនុកម្មវិធី ២.១៨៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ(សាកលវិទ្យាល័យក្រចេះ)

សកម្មភាពសរុប ៩ ក្នុងនោះ អនុវត្តចប់ ៩ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៤ ក្នុងនោះ អាចទទួលយកបាន ៣ ស្មើ ៧៥ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ១ ស្មើ ២៥ភាគរយ។

### *លទ្ធផលក្នុងថ្នាក់កម្រិតអនុកម្មវិធី*

- ចំនួនសិស្ស-និស្សិតចូលរៀនថ្នាក់អប់រំបច្ចេកទេស ថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រគ្រប់ជំនាន់ ទាំង អាហារូបករណ៍ និងមិនមែនអាហារូបករណ៍ត្រូវបានបង្កើន ចំណុចដៅ ៤៨០នាក់ ស្រី ២៥០នាក់ សម្រេច បាន ៤២៥ នាក់ ស្រី ២២៨នាក់
- ចំនួនគម្រោងស្រាវជ្រាវត្រូវបានអនុវត្តក្នុងការលើកកម្ពស់គុណភាពនៃការសិក្សាទាំងកម្រិតអប់រំបច្ចេកទេស បរិញ្ញាបត្ររង និងបរិញ្ញាបត្រឆ្លើយតបទៅតាមតម្រូវការទីផ្សារការងារ ចំណុចដៅ ៥គម្រោង សម្រេចបាន ៤ គម្រោង
- ចំនួនកម្មវិធីសិក្សាថ្នាក់អប់រំបច្ចេកទេស ថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បន្តបរិញ្ញាបត្រដែលបានធ្វើបច្ចុប្បន្នភាព និងដាក់ឱ្យអនុវត្តចំណុចដៅ ៨កម្មវិធី សម្រេចបាន ៥កម្មវិធី
- ភាគរយបុគ្គលិក និងគ្រូបង្រៀនដែលទទួលបានការអភិវឌ្ឍសមត្ថភាពបន្ថែមជាប្រចាំលើការងារ ដែលខ្លួន ទទួលខុស ត្រូវតាមរយៈការចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានាចំណុចដៅ៨០ភាគរយ សម្រេចបាន ៦៥ភាគរយ។

### លទ្ធផលក្នុងថ្នាក់កម្រិតចង្កោមសកម្មភាព

- ភាគរយនៃកំណើនសិស្ស-និស្សិតទាំងអាហារូបករណ៍ និងមិនមែនអាហារូបករណ៍ថ្នាក់អប់រំបច្ចេកទេសវិជ្ជាជីវៈ ថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រចុះឈ្មោះចូលរៀនប្រចាំឆ្នាំកើនឡើងធៀបនឹងឆ្នាំមុន ចំណុចដៅ ១៥ភាគរយ សម្រេចបាន ១២ភាគរយ
- ភាគរយសិស្ស និស្សិតទាំងអាហារូបករណ៍ និងមិនមែនអាហារូបករណ៍ថ្នាក់អប់រំបច្ចេកទេសវិជ្ជាជីវៈ ថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រដែលបានបញ្ចប់ការសិក្សាដោយជោគជ័យប្រចាំឆ្នាំកើនឡើងធៀបនឹងឆ្នាំមុន ចំណុចដៅ ៥ភាគរយ សម្រេចបាន ៣ភាគរយ
- ការលើកកម្ពស់គុណភាពនៃការសិក្សាទាំងកម្រិតអប់រំបច្ចេកទេស បរិញ្ញាបត្ររង និងបរិញ្ញាបត្រឆ្លើយតបទៅតាមតម្រូវការទីផ្សារការងារតាមរយៈការអនុវត្តនូវគម្រោងស្រាវជ្រាវនានា ចំណុចដៅ ៥គម្រោង សម្រេចបាន ៤គម្រោង
- ភាគរយបុគ្គលិក និងគ្រូបង្រៀនដែលទទួលបានការអភិវឌ្ឍសមត្ថភាពបន្ថែមប្រចាំឆ្នាំលើការងារដែលខ្លួនទទួលខុសត្រូវតាមរយៈការចូលរួមវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលា(Non-Degree Level) ចំណុចដៅ ៨០ភាគរយ សម្រេចបាន ៧០ភាគរយ
- ភាគរយបុគ្គលិកការិយាល័យ បុគ្គលិកបង្រៀនដែលទទួលបានការអភិវឌ្ឍសមត្ថភាពបន្ថែមលើការងារដែលខ្លួនទទួលខុសត្រូវតាមរយៈការសិក្សាបន្តរយៈពេលវែង (Degree Level) ចំណុចដៅ បណ្ឌិត ១នាក់ អនុបណ្ឌិត ៨នាក់ សម្រេចបាន បណ្ឌិត ១នាក់ អនុបណ្ឌិត ៧នាក់។

### បញ្ហាប្រឈម

- ខ្វះសាស្ត្រាចារ្យ និងថវិកា
- អង្គភាពមិនទាន់ជាអង្គភាពថវិកា
- ការពិបាកទាក់ទាញនិស្សិតបន្តការសិក្សារហូតបញ្ចប់បរិញ្ញាបត្រ។

## អនុកម្មវិធី ២.១៦៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពអប់រំ និងការស្រាវជ្រាវលើផ្នែកអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ (វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ)

សកម្មភាពសរុប ៣១ ក្នុងនោះ អនុវត្តចប់ ៣១ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៤ ក្នុងនោះសម្រេចតាមចំណុចដៅ ៤ ស្មើ ១០០ភាគរយ។

### លទ្ធផលក្នុងថ្នាក់កម្រិតអនុកម្មវិធី

- ចំនួនសិស្ស និស្សិតអាហារូបករណ៍ថ្នាក់អប់រំបច្ចេកទេស និងវិជ្ជាជីវៈ ថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រត្រូវបានជ្រើសរើសចូលរៀនប្រចាំឆ្នាំ ចំណុចដៅ ១៦០ សម្រេចបាន ១៧៤
- ភាគរយសិស្ស និស្សិតថ្នាក់អប់រំបច្ចេកទេស និងវិជ្ជាជីវៈ ថ្នាក់បរិញ្ញាបត្ររងនិងថ្នាក់បន្តបរិញ្ញាបត្រដែលបានបញ្ចប់ការសិក្សាដោយជោគជ័យចំណុចដៅ ៧៥ភាគរយ សម្រេចបាន ៧៥ភាគរយ
- ចំនួនកម្មវិធីសិក្សាថ្នាក់អប់រំបច្ចេកទេស ថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បន្តបរិញ្ញាបត្រដែលបានធ្វើបច្ចុប្បន្នភាព និងដាក់ឱ្យអនុវត្ត ចំណុចដៅ ១១ សម្រេចបាន ១១
- ភាគបុគ្គលិកការិយាល័យ និងបុគ្គលិកបង្រៀនដែលទទួលបានការអភិវឌ្ឍសមត្ថភាពបន្ថែមប្រចាំឆ្នាំលើការងារ ដែលខ្លួនទទួលខុសត្រូវចំណុចដៅ ៨០ភាគរយ សម្រេចបាន ៨០ភាគរយ។

### *លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព*

- ភាគរយនៃកំណើនសិស្ស និស្សិតអាហារូបករណ៍ថ្នាក់អប់រំបច្ចេកទេស និងវិជ្ជាជីវៈ ថ្នាក់បរិញ្ញាបត្ររងនិងថ្នាក់បន្តបរិញ្ញាបត្រចុះឈ្មោះចូលរៀនប្រចាំឆ្នាំធៀបនឹងឆ្នាំមុន ចំណុចដៅ ១០ភាគរយ សម្រេចបាន ១០ភាគរយ
- ភាគរយសិស្ស និស្សិតថ្នាក់អប់រំបច្ចេកទេស និងវិជ្ជាជីវៈ ថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បន្តបរិញ្ញាបត្រដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ៧៥ភាគរយ ចំណុចដៅ ៧៥ភាគរយ សម្រេចបាន៧៥ភាគរយ
- ចំនួនកើនឡើងនៃកម្មវិធីសិក្សាថ្នាក់អប់រំបច្ចេកទេស និងវិជ្ជាជីវៈ ថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បន្តបរិញ្ញាបត្រដែលបានកំពុងអនុវត្ត ចំណុចដៅ ១ សម្រេចបាន ១
- ភាគរយបុគ្គលិកការិយាល័យ បុគ្គលិកបង្រៀនដែលទទួលបានការអភិវឌ្ឍសមត្ថភាពបន្ថែមលើការងារដែលខ្លួនទទួលខុសត្រូវតាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លី (Non-Degree Level) ចំណុចដៅ ៨៥ភាគរយ សម្រេចបាន ៨៥ភាគរយ
- ភាគរយបុគ្គលិកការិយាល័យ បុគ្គលិកបង្រៀនដែលទទួលបានការអភិវឌ្ឍសមត្ថភាពបន្ថែមលើការងារដែលខ្លួនទទួលខុសត្រូវតាមរយៈការសិក្សាបន្តរយៈពេលវែង (Degree Level) ចំណុចដៅ ១០ភាគរយ សម្រេចបាន ៥ភាគរយ។

### *បញ្ហាប្រឈម*

- ការពិបាកក្នុងការប្រើប្រាស់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នីតិវិធីស្នូគស្នា៣)
- កង្វះទឹកស្អាត និងអន្តេវាសិកគ្រូ និងនិស្សិត។

## អនុកម្មវិធី ២.១៧៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំគ្រូបង្រៀនឆ្លើយតបតាមលក្ខខណ្ឌ គុណវុឌ្ឍិជាតិ (វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ)

សកម្មភាពសរុប ៤ ក្នុងនោះ អនុវត្តចប់ ១ ស្មើ ២៥ភាគរយ កំពុងអនុវត្ត ៣ ស្មើ ៧៥ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចតាមចំណុចដៅ ៤ ស្មើ ៨០ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ១ ស្មើ ២០ភាគរយ។

### *លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- ចំនួនគរុនិស្សិតបឋមសិក្សាថ្នាក់បរិញ្ញាបត្រអប់រំ(១២+៤) បានទទួលការបណ្តុះបណ្តាលចំណុចដៅ ៤៤៨ សម្រេចបាន ២៩៨
- ចំនួនគរុនិស្សិតកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ ថ្នាក់បរិញ្ញាបត្រអប់រំ (១២+៤) បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ២៩៨ សម្រេចបាន ១៩៨
- ចំនួនគរុសិស្សកម្រិតមូលដ្ឋាន(១២+២)បានទទួលការបណ្តុះបណ្តាលចំណុចដៅ ២៣ សម្រេចបាន ២៣
- ចំនួនគ្រូបង្រៀនបឋមសិក្សាទទួលបានការបណ្តុះបណ្តាលបង្កើនគុណវុឌ្ឍិជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំណុចដៅ ៥៨៦ សម្រេចបាន ៥៨៦
- ចំនួនបុគ្គលិកអប់រំ ទទួលបានការអភិវឌ្ឍវិជ្ជាជីវៈ ទាំងនៅក្នុង និងក្រៅប្រទេស ចំណុចដៅ ១៨៤ សម្រេចបាន ១៨៤។

### *លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព*

- ចំនួនគរុនិស្សិតបឋមសិក្សាថ្នាក់បរិញ្ញាបត្រអប់រំ(១២+៤)បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ៤៤៨ សម្រេចបាន ៤៤៨

- ចំនួនគរុនិស្សិតកម្រិតមូលដ្ឋាន ថ្នាក់បរិញ្ញាបត្រអប់រំ(១២+៤) បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ២៩៨ សម្រេចបាន ២៩៨
- ចំនួនគរុសិស្សកម្រិតមូលដ្ឋាន (១២+២) បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ១៨៤ សម្រេចបាន ១៨៤
- ចំនួនគ្រូបង្រៀនបឋមសិក្សាទទួលបានការបណ្តុះបណ្តាលបង្កើនគុណវុឌ្ឍិជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំណុចដៅ ៥៨៦ សម្រេចបាន ៥៨៦
- ចំនួនបុគ្គលិកអប់រំ ទទួលបានការអភិវឌ្ឍវិជ្ជាជីវៈ ទាំងនៅក្នុង និងក្រៅប្រទេស ចំណុចដៅ ១៨៤ សម្រេចបាន ១៨៤។

*បញ្ហាប្រឈម*

- កង្វះមន្ត្រីកិច្ចសន្យា
- អង្គភាពមិនទាន់ក្លាយជាអង្គភាពថវិកា។

### អនុកម្មវិធី ២.១៨៖ ពង្រឹងគុណភាពបណ្តុះបណ្តាល វិក្រឹតការគ្រូនិងការស្រាវជ្រាវស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ (វិទ្យាស្ថានគរុកោសល្យបាត់ដំបង)

សកម្មភាពសរុប ៥ ក្នុងនោះ អនុវត្តចប់ ៤ ស្មើ ៨០ភាគរយ មិនបានអនុវត្ត ១ ស្មើ ២០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៤ ក្នុងនោះសម្រេចតាមចំណុចដៅ ៤ ស្មើ ១០០ភាគរយ។

*លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- ចំនួនគរុនិស្សិតបឋមសិក្សាថ្នាក់បរិញ្ញាបត្រអប់រំ (១២+៤) បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ២០២ សម្រេចបាន ២៩៩
- ចំនួនគរុនិស្សិតកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យថ្នាក់បរិញ្ញាបត្រអប់រំ (១២+៤) បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ១៣៤ សម្រេចបាន ១៩៩
- ចំនួនគរុសិស្សបឋមសិក្សា (១២+២) បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ៥៦ សម្រេចបាន ៧០
- ចំនួនគរុសិស្សកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ (១២+២) បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ២៣ សម្រេចបាន ២៩។

*លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព*

- គរុសិស្សកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ(១២+២)ឆ្នាំទី២ បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ២៩ សម្រេចបាន ២៩

*បញ្ហាប្រឈម*

- អង្គភាពមិនទាន់ជាអង្គភាពថវិកា និងកង្វះមន្ត្រីជំនាញហិរញ្ញវត្ថុ។

## ៤.៣. កម្មវិធីទី ៣៖ ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា

លទ្ធផលសម្រេចបានសូចនាករកម្មវិធីទី៣

- ចំនួនមេដាយពីការប្រកួតកីឡាអន្តរជាតិចំណុចដៅ ២៧៤ សម្រេចបាន ៥០២
- ចំនួនមន្ត្រីបច្ចេកទេសកីឡាដែលបានបណ្តុះបណ្តាល ចំណុចដៅ ១០៥០ សម្រេចបាន ១៣៣៨
- ចំនួនប្រជាជនហាត់ប្រាណនិងលេងកីឡាដើម្បីសុខភាព ចំណុចដៅ ២០,៤ភាគរយ សម្រេចបាន ២១,២ ភាគរយ។

រូបភាពទី ១០ ៖ វឌ្ឍនភាព នៃការសម្រេចបានសូចនាករអនុកម្មវិធីតាមអង្គភាព (កម្មវិធីទី៣)




## ការសម្រេចបានតាមអនុកម្មវិធី

### អនុកម្មវិធី ៣.១៖ ការអភិវឌ្ឍកីឡាមហាជន (នាយកដ្ឋានអប់រំកាយ និងកីឡា)

សកម្មភាពសរុប ១១ ក្នុងនោះ អនុវត្តចប់ ៩ ស្មើ ៨១,៨២ភាគរយ កំពុងអនុវត្ត ១ ស្មើ ៩,០៩ភាគរយ មិនបានអនុវត្ត ១ ស្មើ ៩,០៩ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចតាមចំណុចដៅ ២ ស្មើ ១០០ ភាគរយ។

### *លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- ភាគរយមហាជនហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាពចំណុចដៅ ២០,៤ភាគរយសម្រេចបាន ២១,៨ ភាគរយ
- ចំនួនគ្រូបង្វឹក អាជ្ញាកណ្តាល ចៅក្រម និងមន្ត្រីរៀបចំការប្រកួតកីឡាបានបណ្តុះបណ្តាល ចំណុចដៅ ១ ០៥០នាក់ សម្រេចបាន ១៤៨៦នាក់។

### *លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព*

- ចំនួនមហាជនហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាពទូទាំងប្រទេស ចំណុចដៅ ៣ ១១៨ ៨៥២ សម្រេចបាន ៣ ៤៨១ ៥០៩
- ចំនួនអាជ្ញាកណ្តាល ចៅក្រម និងមន្ត្រីរៀបចំការប្រកួតបានបណ្តុះបណ្តាល ចំណុចដៅ ៨៤០ សម្រេចបាន ១ ០១៦
- ចំនួនគ្រូបង្វឹកបានបណ្តុះបណ្តាល ចំណុចដៅ ២១០ សម្រេចបាន ៤៧០
- ចំនួនប្រភេទកីឡាប្រពៃណីត្រូវបានផ្សព្វផ្សាយ ចំណុចដៅ ១ប្រភេទ សម្រេចបាន ១ប្រភេទ។

### *បញ្ហាប្រឈម*

- របាយការណ៍វឌ្ឍនភាព និងហិរញ្ញវត្ថុរបស់សហព័ន្ធកីឡាជាតិផ្តល់មកអង្គភាពជំនាញមានការយឺតយ៉ាវ
- ពុំទាន់មានសម្ភារបច្ចេកទេសវិទ្យាសាស្ត្រតេស្តកាយសម្បទាប្រជាជន។

### អនុកម្មវិធី ៣.២៖ ការអភិវឌ្ឍអប់រំកាយ និងកីឡាសិស្ស និស្សិត (នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត)

សកម្មភាពសរុប ១៤ ក្នុងនោះ អនុវត្តចប់ ១២ ស្មើ ៨៥,៧១ភាគរយ កំពុងអនុវត្ត ១ ស្មើ ៧,១៤ភាគរយ មិនបានអនុវត្ត ១ ស្មើ ៧,១៤ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចតាមចំណុចដៅ ១ ស្មើ ៥០ ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ១ ស្មើ ៥០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ភាគរយសិស្ស និស្សិតហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាពចំណុចដៅ ៤០ភាគរយ សម្រេចបាន ៧៥ ភាគរយ
- ចំនួនមេដាយប្រតិភូកីឡាសិស្សអាស៊ីអាគ្នេយ៍និងសាកលវិទ្យាល័យអាស៊ីអាគ្នេយ៍ចំណុចដៅ ១៨ សម្រេចមិនបានតាមចំណុចដៅ។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនគ្រូបង្រៀន និងសិស្សានុសិស្សបានចូលរួមទិវាអប់រំកាយថ្នាក់ជាតិ និងទទួលបានការផ្សព្វផ្សាយវប្បធម៌កីឡាដល់សហគមន៍ និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ចំណុចដៅ ៦៥០ សម្រេចបាន ៦៥០
- ចំនួនទីលានកីឡាបាល់ទាត់ ត្រូវបានជួសជុល និងថែទាំ សម្រាប់អនុវត្តសកម្មភាពអប់រំកាយ និងកីឡាក្នុងម៉ោង និងក្រៅម៉ោងសិក្សា ចំណុចដៅ ៨ទីលាន សម្រេចបាន ៨ទីលាន
- ចំនួនប្រតិភូកីឡាត្រូវបានបញ្ជូនទៅចូលរួមប្រកួតកីឡាសិស្សអាស៊ានលើកទី១២ និងកីឡាសាកលវិទ្យាល័យរដូវក្តៅពិភពលោកលើកទី៣១ ចំណុចដៅ ២១ សម្រេចបាន ១៩
- សៀវភៅទិវាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិ ត្រូវបានចងក្រងថ្មី និងបោះពុម្ព ដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ចំណុចដៅ សៀវភៅទិវាអប់រំកាយ ចងក្រងថ្នាក់ទី៧ ចំនួន ៧មុខវិជ្ជារង ថ្នាក់ទី៨ ចំនួន ៧មុខវិជ្ជារង ថ្នាក់ទី៩ ចំនួន ៨មុខវិជ្ជារង សម្រេចបាន ១០០ភាគរយ
- ចំនួនសិក្ខាកាមត្រូវបានលើកកម្ពស់សមត្ថភាពក្នុងការប្រើប្រាស់សៀវភៅគ្រូមុខវិជ្ជាអប់រំកាយនៅបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ចំណុចដៅ ១៤០ សម្រេចបាន ១៤០។

***បញ្ហាប្រឈម***

- ការអនុវត្តសកម្មភាពអប់រំកាយ និងកីឡាមិនឆ្លើយតបក្របខណ្ឌកម្មវិធីសិក្សា។

**អនុកម្មវិធី ៣.៣៖ ការបណ្តុះបណ្តាលធនធានមនុស្សផ្នែកអប់រំកាយ និងកីឡា (វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា)**

សកម្មភាពសរុប ១១ ក្នុងនោះ អនុវត្តចប់ ១០ ស្មើ ៩០,៩១ភាគរយ មិនបានអនុវត្ត ១ ស្មើ ៩,០៩ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចតាមចំណុចដៅ ១ ស្មើ ៥០ភាគរយ អាចទទួលយកបាន ១ ស្មើ ៥០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ចំនួនគរុសិស្សទទួលបានការបណ្តុះបណ្តាលអប់រំកាយនិងកីឡាកម្រិតមូលដ្ឋានតាមប្រព័ន្ធ១២+២ និង ១២+៤ ចំណុចដៅ ២១៦ សម្រេចបាន ១៨០
- ចំនួនគ្រូឧទ្ទេស នៅវ.អ.ក និងគ្រូអប់រំកាយ និងកីឡានៅអនុវិទ្យាល័យ និងវិទ្យាល័យតាមរាជធានី ខេត្ត ទទួលបានការបំប៉នសមត្ថភាពចំណុចដៅ ៦២នាក់ សម្រេចបាន ៦៩នាក់។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនគរុសិស្ស ទទួលបានការបណ្តុះបណ្តាលអប់រំកាយ និងកីឡាកម្រិតមូលដ្ឋានតាមប្រព័ន្ធ១២+២ ចំណុចដៅ ១៨៩ សម្រេចបាន ១១៤
- ចំនួនគរុសិស្ស ទទួលបានការបណ្តុះបណ្តាលអប់រំកាយ និងកីឡាកម្រិតមូលដ្ឋានតាមប្រព័ន្ធ១២+៤ ចំណុចដៅ ៩១ សម្រេចបាន ៦៦
- ចំនួនគ្រូអប់រំកាយ និងកីឡានៅអនុវិទ្យាល័យ និងវិទ្យាល័យតាមរាជធានី ខេត្ត ទទួលបានការបំប៉នសមត្ថភាព ចំណុចដៅ ៥០ សម្រេចបាន ៤៥

- ចំនួនគ្រូឧទ្ទេសត្រូវបានបំប៉នសមត្ថភាពលើឯកទេសសម្រាប់អនុវត្តកម្មវិធីសិក្សាកម្រិតមូលដ្ឋាន តាមប្រព័ន្ធ ១២+២ និងតាមប្រព័ន្ធ១២+៤ បរិញ្ញាបត្រនៅក្នុងប្រទេស និងនៅក្រៅប្រទេស ចំណុចដៅ ៧នាក់ សម្រេចបាន ២៤នាក់។

**អនុកម្មវិធី ៣.៤៖ ការអភិវឌ្ឍកីឡាកម្រិតខ្ពស់ (មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា)**

សកម្មភាពសរុប ៨ ក្នុងនោះ អនុវត្តចប់ ៨ ស្មើ ១០០ភាគរយ។ សូចនាករ លទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងនោះ សម្រេចតាមចំណុចដៅ ១ ស្មើ ១០០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ចំនួនមេដាយការប្រកួតកីឡាជាលក្ខណៈហ្គេម ចំណុចដៅ ២៣៨ មេដាយ សម្រេចបាន ៣៥៥មេដាយ។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនគ្រូបង្វឹក អនុក្សេ និងកីឡាករជម្រើសជាតិប្រមូលផ្តុំហាត់ហ្វឹកហ្វឺនបង្កើនគុណផលប្រចាំឆ្នាំ ចំណុចដៅ ១ ០០០ សម្រេចបាន ១ ៣៨៤
- ចំនួនមេដាយប្រកួតកីឡាស៊ីហ្គេម និងអន្តរជាតិនានា ចំណុចដៅ ១៩២មេដាយ សម្រេចបាន ៤៧១ មេដាយ
- ចំនួនមេដាយប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេម ចំណុចដៅ ៤៦មេដាយ សម្រេចបាន ៧៣មេដាយ
- ចំនួនគ្រូបង្វឹកជម្រើសជាតិត្រូវបានលើកកម្ពស់សមត្ថភាព ចំណុចដៅ ៥០ សម្រេចបាន១៥១។

***បញ្ហាប្រឈម***

- ខ្វះមន្ត្រីជំនាញវេជ្ជសាស្ត្រកីឡាសម្រាប់ជួយព្យាបាលកីឡាការមានរបួសក្នុងពេលហ្វឹកហាត់
- ខ្វះមន្ត្រីផ្នែកវិទ្យាសាស្ត្រកីឡា សម្រាប់គ្រប់គ្រង និងបង្កើនគុណផលកីឡាដោយត្រួតពិនិត្យទៅលើការប្រើប្រាស់ឧបករណ៍នៃការហាត់ជំនួយសាច់ដុំ។

**អនុកម្មវិធី ៣.៥៖ ការអភិវឌ្ឍការប្រកួត និងគ្រប់គ្រង ព្រឹត្តិការណ៍កីឡាគ្រប់កម្រិត (នាយកដ្ឋានរៀបចំ និងគ្រប់គ្រងព្រឹត្តិការណ៍កីឡា)**

សកម្មភាពសរុប ៧ ក្នុងនោះ អនុវត្តចប់ ៧ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ (វាយតម្លៃ ២ឆ្នាំម្តង)។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ចំនួនប្រភេទកីឡាបានដាក់បញ្ចូលក្នុងការប្រកួតកីឡាជាតិ (អនុវត្ត ២ឆ្នាំម្តង)។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនប្រភេទកីឡាបានដាក់បញ្ចូលក្នុងការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិ ចំណុចដៅ ១០ប្រភេទកីឡា សម្រេចបាន ប្រតិភូកីឡាចំនួន ៣ ០០០នាក់ ចូលរួមការប្រកួត
- ចំនួនប្រភេទកីឡាបានដាក់បញ្ចូលក្នុងការប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ជាតិ ១២ប្រភេទកីឡា សម្រេចបាន ប្រតិភូកីឡា ចំនួន ៣ ៥០០នាក់ ចូលរួមប្រកួត
- ចំនួនវិញ្ញាសាកីឡាបានដាក់បញ្ចូលក្នុងការប្រកួតកីឡានិស្សិតឧត្តមសិក្សាថ្នាក់ជាតិ ១៣ប្រភេទ (អនុវត្តពីរឆ្នាំម្តង)
- ចំនួនបុគ្គលិកអប់រំទទួលបន្ទុកកីឡាបានបំប៉នសមត្ថភាពស្តីពីការរៀបចំ និងគ្រប់គ្រងព្រឹត្តិការណ៍កីឡា ចំណុចដៅ ៨០ សម្រេចបាន ៩៨។

### អនុកម្មវិធី ៣.៦៖ ការអភិវឌ្ឍផ្នែកព័ត៌មាន និងស្ថិតិកីឡាគ្រប់ប្រភេទ (មជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យា និងស្ថិតិកីឡា)

សកម្មភាពសរុប ៥ ក្នុងនោះ អនុវត្តចប់ ៥ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះ សម្រេចបានតាមចំណុចដៅ អាចទទួលយកបាន ២ ស្មើ ១០០ភាគរយ។

*លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- ចងក្រងទិន្នន័យ និងផ្សព្វផ្សាយព្រឹត្តិការណ៍កីឡាគ្រប់ប្រភេទចំណុចចដៅ ២៥ រាជធានី ខេត្ត ៤០ សហព័ន្ធ១១ ក្រសួង សម្រេចបានតាមចំណុចដៅ

*លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព*

- ចំនួនមធ្យោបាយផ្សព្វផ្សាយព្រឹត្តិការណ៍កីឡាជាតិ និងអន្តរជាតិ ចំណុចដៅ ៣ សម្រេចបាន ៣
- ចំនួនមន្ត្រីអប់រំកីឡាត្រូវបានពង្រឹងសមត្ថភាពលើផ្នែកព័ត៌មានវិទ្យា សម្រេចបាន១០០ភាគរយ។

*បញ្ហាប្រឈម*

- កិច្ចដំណើរការឯកសារថវិកាច្រើនដំណាក់កាល និងយឺតយ៉ាវ
- មន្ត្រីជំនាញផ្នែកប្រព័ន្ធព័ត៌មានវិទ្យាសមត្ថភាពនៅមានកម្រិត
- កង្វះមន្ត្រី សម្ភារៈ និងកញ្ចប់ថវិកានៅមានកម្រិតខ្លាំង។

## ៤.៤. កម្មវិធីទី៤៖ យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត

លទ្ធផលសម្រេចបានសូចនាករកម្មវិធីទី៤

- ចំនួនយុវជនទទួលបានការបណ្តុះបណ្តាលរយៈពេលខ្លី ស្តីពីជំនាញបច្ចេកទេស ឌីជីថល សហគ្រិន និងជំនាញទន់ ចំណុចដៅ ២៧៧៧នាក់ សម្រេចបាន ២២២០នាក់។

**រូបភាពទី១១ ៖ វឌ្ឍនភាព នៃការសម្រេចបានសូចនាករអនុកម្មវិធីតាមអង្គភាព (កម្មវិធីទី៤)**




## ការសម្រេចបានតាមអនុកម្មវិធី

### អនុកម្មវិធី ៤.១៖ ការអភិវឌ្ឍសកម្មភាពយុវជន (នាយកដ្ឋានយុវជន)

សកម្មភាពសរុប ១២ ក្នុងនោះ អនុវត្តចប់ ១២ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចតាមចំណុចដៅ ២ ស្មើ ១០០ភាគរយ។

*លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- ចំនួនយុវជនចូលរួមចលនាប្រឡងប្រណាំង ៣ល្អ ការងារក្រុមប្រឹក្សាយុវជនកម្ពុជា ក្រុមប្រឹក្សាកុមារកម្ពុជា និងការលើកកម្ពស់ និងអភិវឌ្ឍកម្មវិធីពាក់ព័ន្ធឌីជីថល សហគ្រិនភាព ស្វែម ភាពជាអ្នកដឹកនាំ ស្មាដៃវិទ្យាសាស្ត្រ និងជំនាញទន់សម្រាប់ការអភិវឌ្ឍយុវជនចំណុចដៅ ៨០២៧នាក់ សម្រេចបាន ១៦ ៥៥០នាក់
- ចំនួនគ្រូបង្រៀននៅវិទ្យាល័យចំណេះដឹងទូទៅទទួលបានការបំប៉ន ចំណុចដៅ ១២នាក់ សម្រេចបាន ១២នាក់។

### លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព

- ចំនួនយុវជននិងកុមារទទួលបានការលើកទឹកចិត្ត និងបង្កើនការចូលរួមអនុវត្តការងារក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារកម្ពុជា ចំណុចដៅ ២០០ សម្រេចបាន ៣១០
- ភាគរយក្រុមប្រឹក្សាកុមារកម្ពុជាកំពុងដំណើរការ ចំណុចដៅ ២០,២ភាគរយ សម្រេចបាន ២០,២ភាគរយ
- ភាគរយក្រុមប្រឹក្សាយុវជនកម្ពុជាកំពុងដំណើរការ ចំណុចដៅ ៣១,៩ភាគរយ សម្រេចបាន ៣១,៩ភាគរយ
- ចំនួនយុវជនចូលរួមកម្មវិធីស្នាដៃវិទ្យាសាស្ត្រ និងនវានុវត្តន៍ កម្មវិធីអប់រំ សហគ្រិនភាព និងជំនាញទន់ និងចូលរួមផ្លាស់ប្តូរបទសោធន៍ទំនាក់ទំនងជាតិ និងអន្តរជាតិ ចំណុចដៅ ៧ ៨២៧ សម្រេចបាន ១៦ ៥៥០
- ចំនួនគ្រូសម្របសម្រួលការអប់រំសហគ្រិនភាពទទួលបានការបំប៉នសមត្ថភាព ចំណុចដៅ ១២នាក់ សម្រេចបាន ១២នាក់។

### បញ្ហាប្រឈម

- ការផ្លាស់ប្តូរសមាសភាពមន្ត្រីហិរញ្ញវត្ថុ ដែលធ្វើអោយការគ្រោងថវិកាអនុវត្តកម្មវិធីមានភាពយឺតយ៉ាវ
- គោលការណ៍ណែនាំទូទាត់ថវិកា នៃការអនុវត្តកម្មវិធី តាមប្រព័ន្ធអនឡាញមិនទាន់មានភាពច្បាស់លាស់។

### អនុកម្មវិធី ៨.២៖ ការអភិវឌ្ឍមជ្ឈមណ្ឌលយុវជន (នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល)

សកម្មភាពសរុប ១២ ក្នុងនោះ អនុវត្តចប់ ១២ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចតាមចំណុចដៅ ១ ស្មើ ៥០ភាគរយ អាចទទួលយកបាន ១ ស្មើ ៥០ភាគរយ។

### លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី

- ចំនួនយុវជនដែលទទួលបានជំនាញបច្ចេកទេស និងជំនាញទន់ ចំណុចដៅ ២ ៧៧៥នាក់ សម្រេចបាន ៥ ៩១១នាក់
- ចំនួនមជ្ឈមណ្ឌលយុវជនដែលបានអភិវឌ្ឍន៍ ចំណុចដៅ ២ សម្រេចបាន ២។

### លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព

- ចំនួនយុវជនទទួលបានការបណ្តុះបណ្តាលរយៈពេលខ្លីស្តីពីជំនាញវិជ្ជាជីវៈ ឌីជីថល និងបច្ចេកទេស ចំណុចដៅ ២ ៧៧៥ សម្រេចបាន ៣ ៤៦០
- ចំនួនយុវជនទទួលបានការបណ្តុះបណ្តាល និងអនុវត្តគម្រោងការងារស្ម័គ្រចិត្ត ចំណុចដៅ ១ ៧៥០ សម្រេចបាន ២ ១២៣
- ចំនួនយុវជន ក្រៅសាលាចូលរួមសិក្សាក្នុងកម្មវិធីអប់រំសមមូលកម្រិតមូលដ្ឋាន "ប៊ីប" ចំណុចដៅ ៣៥០ សម្រេចបាន ៣២៨។

### បញ្ហាប្រឈម

- ខ្វះមន្ត្រីរដ្ឋបាល និងបច្ចេកវិទ្យាព័ត៌មានវិទ្យា។

### អនុកម្មវិធី ៨.៣៖ ការអភិវឌ្ឍកាយវប្បកម្ម (នាយកដ្ឋានសហប្រតិបត្តិការកាយវប្បធម៌)

សកម្មភាពសរុប ១៤ ក្នុងនោះ អនុវត្តចប់ ១៤ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងនោះសម្រេចតាមចំណុចដៅ ១ ស្មើ ១០០ភាគរយ។

### លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី

- កុមារ និងយុវជន នៅបឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និងសហគមន៍ចូលរួមចលនាកាយវប្បធម៌សម្រេចបាន ១៧៥ ០០០នាក់ ចំណុចដៅ ១៧៥ ០០០នាក់។

*លទ្ធផលក្នុងថ្នាក់កម្រិតចង្កោមសកម្មភាព*

- ចំនួនកាយរឹទ្ធិបានចូលរួមការងារស្ម័គ្រចិត្ត ក្នុងសហគមន៍ ចំណុចដៅ ១៥០ សម្រេចបាន ២០០
- ចំនួនកាយរឹទ្ធិទទួលបានការបណ្តុះបណ្តាលស្តីពីកាយរឹទ្ធិកម្ម និងភាពជាអ្នកដឹកនាំ ចំណុចដៅ ៤០០ សម្រេចបាន ៩០០
- ចំនួនកាយរឹទ្ធិទទួលបានការបណ្តុះបណ្តាលរយៈពេលខ្លី ស្តីពីជំនាញឌីជីថល និងបច្ចេកទេស" ចំណុចដៅ ៧០ សម្រេចបាន ១០០
- ចំនួនមន្ត្រីទទួលបន្ទុកការងារយុវជន និងកាយរឹទ្ធិទទួលបានការបណ្តុះបណ្តាល ចំណុចដៅ ២៥ សម្រេចបាន ៣១។

*បញ្ហាប្រឈម*

- ខ្វះគ្រឿងឥស្សរិយយសកាយរឹទ្ធិ និងបណ្ណសញ្ញាវឌ្ឍនកម្មកាយរឹទ្ធិ
- ខ្វះមន្ត្រីជំនាញកាយរឹទ្ធិកម្មនៅតាមគ្រឹះស្ថានសិក្សា។

## ៤.៥. កម្មវិធីទី ៥៖ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ

លទ្ធផលសម្រេចបានសូចនាករកម្មវិធីទី៥

- អត្រាការទូទាត់ចំណាយថវិកាកម្មវិធីចំណុចដៅ៩៥ភាគរយ សម្រេចបាន ៩៥ភាគរយ។

**រូបភាពទី ១២ ៖ វឌ្ឍនភាព នៃការសម្រេចបានសូចនាករអនុកម្មវិធីតាមអង្គភាព (កម្មវិធីទី៥)**



### ការសម្រេចបានតាមអនុកម្មវិធី

**អនុកម្មវិធី ៥.១៖ ការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធផែនការអប់រំ (នាយកដ្ឋានផែនការ)**

សកម្មភាពសរុប ២៧ ក្នុងនោះ អនុវត្តចប់ ២៤ ស្មើ ៨៨,៨៩ភាគរយ កំពុងអនុវត្ត ១ ស្មើ ៣,៧០ភាគរយ មិនបានអនុវត្ត ២ ស្មើ ៧,៤១ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចតាមចំណុចដៅ ១ ស្មើ ២០ភាគរយ អាចទទួលយកបាន ៣ ស្មើ ៦០ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ១ ស្មើ ២០ភាគរយ។

*លទ្ធផលក្នុងថ្នាក់កម្រិតអនុកម្មវិធី*

- របាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ត្រូវបានរៀបចំ ចំណុចដៅ ១០០ភាគរ សម្រេចបាន ១០០ភាគរយ
- ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨ ត្រូវបានរៀបចំ ចំណុចដៅ ១០០ភាគរយ សម្រេចបាន ៧០ភាគរយ
- ចំនួនរាជធានី ខេត្ត មានផែនការប្រតិបត្តិប្រចាំឆ្នាំមានគុណភាពចំណុចដៅ ១៧ សម្រេចបាន ១៤

- ភាគរយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានផែនការប្រតិបត្តិប្រចាំឆ្នាំ ចំណុចដៅ ៧៥ភាគរយ សម្រេចបាន ៦៥,២ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនរាជធានី ខេត្ត ត្រូវបានពិនិត្យតាមដាន និងវាយតម្លៃលើការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ចំណុចដៅ ១០ សម្រេចបាន ២៥
- ភាគរយសាលារៀនបានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ចំណុចដៅ ៨០ភាគរយ សម្រេចបាន ៨៩ភាគរយ
- ភាគរយសាលារៀនបានរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ចំណុចដៅ ១០០ភាគរយ សម្រេចបាន ៩៨ភាគរយ
- ផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានរៀបចំ ចំណុចដៅ ផែនការយុទ្ធថវិកា ២០២៤-២០២៦ សម្រេចបាន បាន និងកំពុងរៀបចំសេចក្តីព្រាង
- ចំនួនបុគ្គលិកអប់រំទទួលបានការបំប៉នសមត្ថភាពស្តីពីការកសាងផែនការប្រតិបត្តិប្រចាំឆ្នាំតាមអនុវិស័យ តាមប្រព័ន្ធ (Software) ថ្នាក់ជាតិ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ចំណុចដៅ ៣១ សម្រេចបាន ៩០ ភាគរយ។

***បញ្ហាប្រឈម***

- ខ្វះមន្ត្រីបច្ចេកទេសកសាងផែនការអប់រំ
- ខ្វះមន្ត្រីផ្នែកបច្ចេកវិទ្យាព័ត៌មាន។

**អនុកម្មវិធី ៥.២៖ ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស (នាយកដ្ឋានបុគ្គលិក)**

សកម្មភាពសរុប ១៨ ក្នុងនោះ អនុវត្តចប់ ១៤ ស្មើ ៧៧,៧៨ភាគរយ កំពុងអនុវត្ត ២ ស្មើ ១១,១១ភាគរយ មិនបានអនុវត្ត ២ ស្មើ ១១,១១ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៤ ក្នុងនោះសម្រេចតាមចំណុចដៅ ៣ ស្មើ ៧៥ភាគរយ អាចទទួលយកបាន ១ ស្មើ ២៥ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ចំនួនអង្គភាពបានបំពេញសលាកបត្រជូនគរុសិស្ស និស្សិតដែលត្រៀមចេញបម្រើការងារ ដើម្បីរៀបចំប្រាក់បៀវត្សចំណុចដៅ ២៥អង្គភាព សម្រេចបាន ២៥អង្គភាព
- ចំនួនអង្គភាពដែលត្រូវបានចុះសហការពិនិត្យផ្ទៀងផ្ទាត់ការអនុវត្តគោលការណ៍ស្តីពីការគ្រប់គ្រងនិងការបំពេញភារកិច្ចរបស់ បុគ្គលិកអប់រំ គ្រូបង្រៀន និងមន្ត្រីជាប់កិច្ចសន្យាចំណុចដៅ ២៥ អង្គភាព សម្រេចបាន ១០អង្គភាព
- ចំនួនរាជធានី ខេត្ត និង គ្រឹះស្ថានសិក្សាត្រូវបានចុះពិនិត្យផ្ទៀងផ្ទាត់ការអនុវត្តគោលការណ៍ស្តីពីការប្រឡងជ្រើសរើសចូលក្របខណ្ឌគ្រូបង្រៀន ចំណុចដៅ ២៥អង្គភាព សម្រេចបាន ២៥អង្គភាព
- ចំនួនគរុសិស្ស និស្សិត ដែលប្រឡងបញ្ចប់ការបណ្តុះបណ្តាលទទួលបានការតម្រង់ទិសមុនពេល ចេញបម្រើការងារចំណុចដៅ ៣ ០០០នាក់ សម្រេចបាន ២ ១៣០នាក់។

**អនុកម្មវិធី ៥.៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុ ការអភិវឌ្ឍសមត្ថភាព ការគាំទ្រការលើកកម្ពស់គុណភាពអប់រំ និងមូលដ្ឋានសម្ភារៈ (នា.ហិរញ្ញវត្ថុ)**

សកម្មភាពសរុប ៧ ក្នុងនោះកំពុងអនុវត្ត ៧ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះ អាចទទួលយកបាន ២ ស្មើ ១០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- អត្រាការទូទាត់ចំណាយថវិកាកម្មវិធីចំណុចដៅ ៩៥ភាគរយ សម្រេចបាន ៩៥ភាគរយ

- អត្រាកំណើនថវិកាចំណាយចរន្តធៀបនឹងចំណាយចរន្តថ្នាក់ជាតិ ចំណុចដៅ ១៦ភាគរយ សម្រេចបាន ១៦ភាគរយ។

*លទ្ធផលក្នុងថ្នាក់កម្រិតចង្កោមសកម្មភាព*

- អត្រាកំណើនថវិកាចំណាយចរន្តក្រៅបន្ទុកបុគ្គលិករបស់ក្រសួងអប់រំ យុវជន និងកីឡា ចំណុចដៅ ១៨,៩ ភាគរយ សម្រេចបាន ១០០ភាគរយ
- អត្រាអង្គភាពបានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា ចំណុចដៅ ១០០ ភាគរយ សម្រេចបាន ១០០ភាគរយ
- ចំនួនគរុសិស្ស គរុនិស្សិតបានទទួលការបណ្តុះបណ្តាលនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ចំណុចដៅ ២ ៤៧៩នាក់ សម្រេចបាន ២ ១៦០នាក់
- ចំនួនមាតិកាអប់រំឌីជីថលត្រូវបានផលិត ចំណុចដៅ វីដេអូ ៣ ៣៤៦ សន្លឹកកិច្ចការ ២ ៥០០ សម្រេចបាន វីដេអូ ៧០០ សន្លឹកកិច្ចការ ២ ៥០០។

*បញ្ហាប្រឈម*

- ឥណទានថវិការបស់ក្រសួងមិនទាន់ឆ្លើយតបនឹងសូចនាករគោលដៅ ២០ភាគរយនៃចំណាយចរន្តថ្នាក់ជាតិ
- ចំណាយក្រៅបន្ទុកបុគ្គលិកមិនទាន់ឆ្លើយតបទៅនឹងសូចនាករគោលដៅយ៉ាងតិច ២២ភាគរយ នៃថវិការួម របស់ក្រសួងសម្រាប់ចំណាយលើការអភិវឌ្ឍសមត្ថភាពនិងស្ថាប័ន
- ការកំណត់ពិតានគោលនៅក្នុងសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP)
- ការសម្រួចផែនការសកម្មភាពអាទិភាពមិនទាន់ឆ្លើយតបទៅនឹងពេលវេលានៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ
- អង្គភាពមានចរិកលក្ខណៈជាអង្គភាពគាំទ្រពិបាកក្នុងការវិភាជថវិកាតាមអនុវិស័យនិងចំណាត់ថ្នាក់មុខងារ
- ចំនួនអង្គភាពថវិកាច្រើន និងរចនាសម្ព័ន្ធនៃអង្គភាពថវិកានីមួយៗ ខុសប្លែកគ្នា ( កម្រិតនាយកដ្ឋាន វិទ្យាស្ថាន សាកលវិទ្យាល័យ និងកម្រិតអគ្គនាយកដ្ឋាន)
- មិនអាចបូកសរុបថវិការបស់ការិយាល័យ អ.យ.ក នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងមិនបានរំលេច នូវថវិកាអប់រំ ដាច់ដោយឡែកពីអនុវិស័យផ្សេងៗនៃសៀវភៅថវិកានៅថ្នាក់ក្រោមជាតិ
- ការផ្តល់ថវិកាប្រជុំបច្ចេកទេសដល់សាលារៀន និងថវិកាដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍មិនទាន់ស្របតាម ប្រកាស៥០៨ សហវ.ប្រក ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី នៅក្រសួងអប់រំ យុវជន និងកីឡា
- ការយល់ដឹងរបស់សាលារៀនសាធារណៈ នៃការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងមូលនិធិដំណើការសាលារៀន នៅមានកម្រិត
- អង្គភាពថវិកាមួយចំនួនមានការផ្លាស់ប្តូររដ្ឋទេយ្យករនិងរដ្ឋទេយ្យកររង
- ការអនុវត្តកិច្ចលទ្ធកម្មមានច្រើនដំណាក់កាល និងប្រើប្រាស់ពេលវេលាច្រើន
- អង្គភាពអនុវត្តមូលនិធិ CDPF មួយចំនួនមិនបានផ្តល់របាយការណ៍ទូទាត់មកនាយកដ្ឋានហិរញ្ញវត្ថុទាន់ពេលវេលា និង បណ្តាលឱ្យការបំពេញទិន្នន័យរបាយការណ៍ទូទាត់ទៅក្នុងប្រព័ន្ធគណនេយ្យ SAGE ៥០ មិនបានពេញលេញ
- គម្រោងមួយចំនួន មិនបានផ្តល់របាយការណ៍ហិរញ្ញវត្ថុតាម COA ប្រចាំឆ្នាំ២០២២ មកការិយាល័យទាន់ពេល វេលា ដូចបានកំណត់ក្នុងលិខិតជូនដំណឹង។ គម្រោងដែលមិនទាន់បានផ្តល់របាយការណ៍មក ការិយាល័យមានដូចជា៖ គម្រោង SEIP, គម្រោងសាងសង់និងជួសជុលសាលាបឋមសិក្សានិងមធ្យមសិក្សានៅទូទាំងប្រទេសជំហានទី១, គម្រោងសាងសង់ និងជួសជុលសាលាបឋមសិក្សា និងមធ្យមសិក្សានៅទូទាំងប្រទេសជំហានទី២, និងគម្រោងកែលម្អបរិស្ថានសាលារៀន និងការផ្គត់ផ្គង់សម្ភារៈនៅកម្ពុជា។

### អនុកម្មវិធី ៥.៤៖ ការពង្រឹងការងារសវនកម្មផ្ទៃក្នុង (នាយកដ្ឋានសវនកម្មផ្ទៃក្នុង)

សកម្មភាពសរុប ៥ ក្នុងនោះ អនុវត្តចប់ ៥ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៦ ក្នុងនោះ សម្រេចតាមចំណុចដៅ ៥ ស្មើ ៨៣,៣៣ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ១ ស្មើ ១៦,៦៧ភាគរយ។

*លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- ចំនួនអង្គភាពបានត្រួតពិនិត្យតាមដានការកែលម្អតាមអនុសាសន៍ ចំណុចដៅ ២០ សម្រេចបាន ២១
- ចំនួនអង្គភាពរងសវនកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំណុចដៅ១២៤ សម្រេចបាន ៩៥
- ចំនួនអង្គភាពរងសវនកម្មសមិទ្ធកម្ម និងអង្គភាពរងសវនកម្មបច្ចេកវិទ្យាព័ត៌មាន (សាកល្បង) ១២ សម្រេចបាន ១៥
- ចំនួនអង្គភាពរងសវនកម្មលើគម្រោងដែលប្រើហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន ចំណុចដៅ ៤ សម្រេចបាន ១០
- ចំនួនមន្ត្រីសវនកម្មផ្ទៃក្នុងទទួលបានការពង្រឹងសមត្ថភាព ចំណុចដៅ ២២០ សម្រេចបាន ១៨៤។

*បញ្ហាប្រឈម*

- មន្ត្រីសវនកម្មផ្ទៃក្នុង មិនទាន់ឆ្លើយតបទៅនឹងការធ្វើសវនកម្មសមិទ្ធកម្ម ប្រព័ន្ធព័ត៌មានវិទ្យា និងសវនកម្មគម្រោង ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ
- ការអនុវត្តវិធីសាស្ត្រ និងនីតិវិធីសវនកម្មផ្ទៃក្នុងមិនទាន់ឆ្លើយតបទៅនឹងស្តង់ដាសវនកម្មផ្ទៃក្នុងនៅឡើយ។

### អនុកម្មវិធី ៥.៥៖ ការពិនិត្យតាមដាន វាយតម្លៃ និងអធិការកិច្ចប្រព័ន្ធធានាគុណភាពអប់រំ (នាយកដ្ឋានធានាគុណភាពអប់រំ)

សកម្មភាពសរុប ៣០ ក្នុងនោះ អនុវត្តចប់ ២៧ ស្មើ ៩០ភាគរយ កំពុងអនុវត្ត ១ ស្មើ ៣,៣៣ភាគរយ មិនបានអនុវត្ត ២ ស្មើ ៦,៦៧ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៦ ក្នុងនោះសម្រេចតាមចំណុចដៅ ៣ ស្មើ ៥០ភាគរយ អាចទទួលយកបាន ៣ ស្មើ ៥០ភាគរយ។

*លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ថ្នាក់ជាតិ ថ្នាក់ទី៣,៦,៨ និងទី១១ ថ្នាក់ទី១១ (២៣០ សាលា) សម្រេចបាន ១០០ភាគរយ
- តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស បឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ ថ្នាក់ទី៥ អនុវត្តសាកល្បង SEA-PLM ២០២៤ (៣៥សាលា) ១០០ភាគរយ
- កម្មវិធីអន្តរជាតិស្តីពីតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស វិភាគ និងសរសេររបាយការណ៍ PISA-២០២២ សម្រេចបាន ១០០ភាគរយ
- ចំនួនគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សានឹងត្រូវបានធ្វើអធិការកិច្ចតាមប្រធានបទចំនួន២ ចំណុចដៅ បឋមសិក្សា ១០០ មធ្យមសិក្សា ១០០ សម្រេចបាន ១០០ភាគរយ
- ចំនួនរាជធានី ខេត្ត ត្រូវបានចុះពិនិត្យតាមដានគុណភាព និងប្រសិទ្ធភាពអប់រំចំណុចដៅ ២៥រាជធានី ខេត្ត សម្រេចបាន ៩៥ភាគរយ។

*លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព*

- ការអនុវត្តតេស្ត វង្វាយតម្លៃថ្នាក់ជាតិ ចំណុចដៅ ២៣០សាលា សម្រេចបាន ១០០ភាគរយ
- ការអនុវត្តតេស្ត វង្វាយតម្លៃថ្នាក់តំបន់ ចំណុចដៅ ៣០សាលា សម្រេចបាន ១០០ភាគរយ
- ការអនុវត្តតេស្តកម្រិតអន្តរជាតិគរយ ចំណុចដៅ ២ប្រធានបទ សម្រេចបាន ៩០,២៣ភាគរយ
- ចំនួនគ្រឹះស្ថានសិក្សាត្រូវបានអធិការកិច្ចតាមប្រធានបទ ចំណុចដៅ បឋម ៨០ មធ្យម ៨០ សម្រេចបាន ៥០ភាគរយ

- ចំនួនរាជធានី ខេត្ត ត្រូវបានពិនិត្យតាមដានគុណភាព និងប្រសិទ្ធភាពអប់រំ ចំណុចដៅ ២៥រាជធានី ខេត្ត សម្រេចបាន ៩០,២៣ភាគរយ។

*បញ្ហាប្រឈម*

- ខ្វះថវិកាអធិការកិច្ច និងកង្វះកុំព្យូទ័រយួរដៃ។

### អនុកម្មវិធី ៥.៦៖ អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ (អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ)

សកម្មភាពសរុប ៦ ក្នុងនោះ អនុវត្តចប់ ៣ ស្មើ ៥០ភាគរយ កំពុងអនុវត្ត ១ ស្មើ ១៦,៦៧ភាគរយ មិនបានអនុវត្ត ២ ស្មើ ៣៣,៣៣ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៤ ក្នុងនោះសម្រេចតាមចំណុចដៅ ២ ស្មើ ៥០ភាគរយ អាចទទួលយកបាន ២ ស្មើ ៥០គរយ។

*លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- ចំនួនអង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានចុះធ្វើអធិការកិច្ចជាប្រចាំ ចំណុចដៅ ៣៤៩ សម្រេចបាន ៣៤៥
- ចំនួនអង្គភាពត្រូវបានពិនិត្យវឌ្ឍនភាពនៃការកែលម្អតាមអនុសាសន៍ ចំណុចដៅ២០ សម្រេចបាន ២០
- អភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញ និងផ្សព្វផ្សាយរបាយការណ៍អធិការកិច្ច ចំណុចដៅ ២វគ្គ សម្រេចបាន ១វគ្គ
- អធិការកិច្ចចៃដន្យ ចំណុដៅ ១២ករណី សម្រេចបាន ១៣ករណី។

*បញ្ហាប្រឈម*

- ការដាក់ពាក្យបណ្ដឹងតវ៉ាមិនតាមឋានានុក្រម
- កង្វះការបណ្តុះបណ្តាលមន្ត្រីជំនាញលើស្តង់ដាអធិការកិច្ចទាំងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។

### អនុកម្មវិធី ៥.៧៖ លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានអប់រំ និងសហប្រតិបត្តិការអាស៊ាន-ស៊ីមេអូ (នាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន)

សកម្មភាពសរុប ២២ ក្នុងនោះ អនុវត្តចប់ ១១ ស្មើ ៥០ភាគរយ កំពុងអនុវត្ត ៩ ស្មើ ៤០,៩១ភាគរយ មិនបានអនុវត្ត ២ ស្មើ ៩,០៩ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចតាមចំណុចដៅ ១ ស្មើ ២០ភាគរយ អាចទទួលយកបាន ២ ស្មើ ៤០ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ២ ស្មើ ៤០ភាគរយ។

*លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី*

- ព័ត៌មានស្តីពីការអប់រំត្រូវបានប្រមូល ចងក្រង និងផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន (ទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវដ្ដី ផ្ទាំងរូបភាព និងប័ណ្ណផ្ទត់)ចំណុចដៅ ៩ ០០០ ផ្ទាំង ២៥ ០០០ សន្លឹក សៀវភៅ ១ ២០០ ក្បាល សម្រេចបាន ១ ០០០ ផ្ទាំង សៀវភៅ ៤០០ក្បាល
- ចំនួនសិស្សនិស្សិត ដែលចូលរួម និងទទួលបានលទ្ធផលក្នុងការធ្វើតេស្តវាយតម្លៃ ចំណេះដឹងអាស៊ាន-ស៊ីមេអូ តាមឌីជីថល និងដោយផ្ទាល់ ចំណុចដៅ ៤០០នាក់ សម្រេចបាន ៣០០នាក់
- ភាពយន្ត-វីដេអូអប់រំ-ស្ប៉តអប់រំ និងឯកសារសមិទ្ធផលអប់រំ យុវជន និងកីឡាត្រូវបានផលិត និងផ្សព្វផ្សាយ ចំណុចដៅ ៨៥% សម្រេចបាន ៨៥%
- ចំនួនមន្ត្រីអប់រំត្រូវបានអភិវឌ្ឍសមត្ថភាព លើជំនាញព័ត៌មាន និងលើកកម្ពស់ចំណេះដឹង និងផ្សព្វផ្សាយចក្ខុវិស័យលទ្ធផលកិច្ចប្រជុំអាស៊ាន-ស៊ីមេអូ ចំណុចដៅ ២០០នាក់ សម្រេចបាន ១០០នាក់
- ចំនួនកិច្ចប្រជុំអាស៊ាន-ស៊ីមេអូ ត្រូវផលិត និងផ្សព្វផ្សាយ ចំណុចដៅ ១៥០លើក សម្រេចបាន ៥០លើក។

*លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព*

- ព័ត៌មានស្តីពីការអប់រំត្រូវបានប្រមូល ចងក្រង និងផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន (ទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវដ្ដី ផ្ទាំងរូបភាព និងប័ណ្ណផ្ទត់) ចំណុចដៅ ៩ ០០០ផ្ទាំង ២៥ ០០០សន្លឹក សៀវភៅ ១ ២០០ ក្បាល សម្រេចបាន ១ ០០០ផ្ទាំង សៀវភៅ ៤០០ក្បាល

- ចំនួនសិស្សនិស្សិត ដែលចូលរួម និងទទួលបានលទ្ធផលក្នុងការធ្វើតេស្តវាយតម្លៃ ចំណេះដឹងអាស៊ាន-ស៊ីមេអូ តាមឌីជីថល និងដោយផ្ទាល់ ចំណុចដៅ ៤០០នាក់ សម្រេចបាន ៣០០នាក់
- ភាពយន្ត-វីដេអូអប់រំ-ស្ប៉តអប់រំ និងឯកសារសមិទ្ធផលអប់រំ យុវជន និងកីឡាត្រូវបានផលិត និងផ្សព្វផ្សាយ ចំណុចដៅ ៨៥ភាគរយ សម្រេចបាន ៨៥ភាគរយ
- ចំនួនបុគ្គលិកអប់រំ និងទទួលបានជំនាញពីវគ្គបណ្តុះបណ្តាលលើជំនាញប្រមូលសរសេរ និងឆ្លើយតបព័ត៌មាន ចំណុចដៅ ១០០នាក់ សម្រេចបាន ៦០នាក់។

***បញ្ហាប្រឈម***

- កង្វះកាម៉ារ៉ា កុំព្យូទ័រកាត់ត សម្ភារបម្រើការថត មន្ត្រីមានជំនាញថត និងកាត់ត
- ការសហការពីអង្គភាពពាក់ព័ន្ធមិនទាន់បានប្រសើរ។

### អនុកម្មវិធី ៥.៨៖ ការពង្រឹងការងារនីតិកម្ម (នាយកដ្ឋាននីតិកម្ម)

សកម្មភាពសរុប ៩ ក្នុងនោះ អនុវត្តចប់ ៥ ស្មើ ៥៥,៥៦ភាគរយ កំពុងអនុវត្ត ៤ ស្មើ ៤៤,៤៤ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ ក្នុងនោះអាចទទួលយកបាន ៣ ស្មើ ១០០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ចំនួនលិខិតបទដ្ឋានគតិយុត្តិវិស័យអប់រំត្រូវបានរៀបចំ ចំណុចដៅ ៣០ សម្រេចបាន ១៩
- ចំនួនបុគ្គលិកអប់រំ និងគរុនិស្សិតទទួលបានការអភិវឌ្ឍសមត្ថភាពលើការងារនីតិកម្មវិស័យអប់រំ ចំណុចដៅ ៣ ១៦០នាក់ សម្រេចបាន ១ ៦៧៧នាក់
- ចំនួនបុគ្គលិកអប់រំដែលត្រូវបានធ្វើការសិក្សាលើប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌច្បាប់វិស័យអប់រំចំណុចដៅ ២០០ សម្រេចបាន ១៤៥។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនលិខិតបទដ្ឋានគតិយុត្តិត្រូវបានរៀបចំ ចំណុចដៅ ៣០ សម្រេចបាន ១៩
- ចំនួនបុគ្គលិកអប់រំ និងគរុនិស្សិតដែលទទួលបានការពង្រឹងសមត្ថភាពលើច្បាប់ស្តីពីការអប់រំ និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ចំណុចដៅ ៣ ០០០ សម្រេចបាន ៥១៤
- ចំនួនបុគ្គលិកអប់រំដែលបានធ្វើការសិក្សាស្តីពីប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌច្បាប់វិស័យអប់រំ ចំណុចដៅ ២០០
- ចំនួនបុគ្គលិកអប់រំត្រូវបានពង្រឹងសមត្ថភាពលើការងាររឹមជ្ឈការ និងវិសហមជ្ឈការ ចំណុចដៅ ៨០ សម្រេចបាន ១ ១៦៣។

***បញ្ហាប្រឈម***

- ការគ្រោងផែនការនៅក្នុង BSP និង AOP មានការខុសគ្នាដោយសារមានកំហុសនៅពេលគ្រោងរប
- ការិយាល័យតាមប្រព័ន្ធ បណ្តាលឱ្យមានការប្រែប្រួលថវិកាតាមចង្កោមនៅពេលបង្កើត AOP ចុងក្រោយ។

### អនុកម្មវិធី ៥.៩៖ ការពង្រឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ (នាយកដ្ឋានសំណង់)

សកម្មភាពសរុប ១០ ក្នុងនោះ អនុវត្តចប់ ៥ ស្មើ ៥០ភាគរយ កំពុងអនុវត្ត ៥ ស្មើ ៥០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ ក្នុងនោះ អាចទទួលយកបាន ២ស្មើ ៦៦,៦៧ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ១ ស្មើ ៣៣,៣៣ ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ចំនួនទីតាំងគម្រោងសាងសង់ថ្មី ជួសជុល និងចុះពិនិត្យតាមដានលក្ខណៈបច្ចេកទេសព្រមទាំងការងារគ្រប់គ្រង ហេដ្ឋារចនាសម្ព័ន្ធអប់រំ ៦០០ សម្រេចបាន ៥៥០

- ចំនួនអគារសិក្សាសាលារៀនដែលរងផលប៉ះពាល់ដោយគ្រោះធម្មជាតិខ្នាតតូច ត្រូវបានជួសជុលបំពេញតម្រូវការ ចំណុចដៅ ៩២ សម្រេចបាន ៩

***លទ្ធផលក្នុងថ្នាក់កម្រិតចង្កោមសកម្មភាព***

- ចំនួនទីតាំងដែលត្រូវសិក្សាលើគម្រោងសាងសង់ និងជួសជុល និងចុះពិនិត្យតាមដានលក្ខណៈបច្ចេកទេស ព្រមទាំងការងារគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ ចំណុចដៅ ៦០០ សម្រេចបាន ៦០០
- ចំនួនសាលារៀនដែលរងផលប៉ះពាល់ដោយគ្រោះធម្មជាតិខ្នាតតូចត្រូវបានជួសជុលបំពេញតម្រូវការ ចំណុចដៅ ៩២ សម្រេចបាន ៩

***បញ្ហាប្រឈម***

- កង្វះមន្ត្រីជំនាញ ព័ត៌មានវិទ្យា ស្ថាបត្យករ ភាសាអង់គ្លេស សម្ភារៈការិយាល័យ និងមធ្យោបាយធ្វើដំណើរ
- កង្វះថវិកាតាមការស្នើសុំរបស់ខេត្តក្រុង និងនីតិការទូទាត់ស្មុគស្មាញប្រើពេលយូរ។

**អនុកម្មវិធី ៥.១០៖ ការពង្រឹងការគ្រប់គ្រងការផ្គត់ផ្គង់សម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ (នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ)**

សកម្មភាពសរុប ៦ ក្នុងនោះ អនុវត្តចប់ ៦ ស្មើ ១០០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះ សម្រេចតាមចំណុចដៅ ២ ស្មើ ១០០ភាគរយ។

***លទ្ធផលក្នុងថ្នាក់កម្រិតអនុកម្មវិធី***

- ចំនួនអង្គភាពរដ្ឋបាលកណ្តាល និងមន្ទីរ មានបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ចំណុចដៅ ៦១ សម្រេចបាន ៦១
- ចំនួនគ្រឹះស្ថានសិក្សា និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូមានសម្ភារបរិក្ខារសម្រាប់រដ្ឋបាល ចំណុចដៅ ៧៥ សម្រេចបាន ២៤៣។

***លទ្ធផលក្នុងថ្នាក់កម្រិតចង្កោមសកម្មភាព***

- ចំនួនសាលារៀនបានទទួលសម្ភារបរិក្ខារសម្រាប់រដ្ឋបាល ចំណុចដៅ ៥០ សម្រេចបាន ២១៨
- ចំនួនសាលារៀនបានទទួលកុំព្យូទ័រសម្រាប់បង្រៀនដល់សិស្ស (Computer Lab) ចំណុចដៅ ៥សាលា សម្រេចបាន ៥សាលា
- ចំនួនគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបានទទួលសម្ភារបរិក្ខារព័ត៌មានវិទ្យានិងសង្ហារិម ចំណុចដៅ ២០សាលា សម្រេចបាន ២០សាលា
- ចំនួនអង្គភាពរដ្ឋបាល កណ្តាល មន្ទីរ និងសាលារៀនត្រូវបានពិនិត្យតាមដាន ចំណុចដៅ ១០០ សម្រេចបាន ១០២
- ចំនួនមន្ត្រីអប់រំថ្នាក់រដ្ឋបាលកណ្តាល រាជធានី ខេត្ត និងនាយកសាលាបានចូលរួមវគ្គបំប៉នស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ចំណុចដៅ ២០០ សម្រេចបាន ២០៥។

***បញ្ហាប្រឈម***

- ការប្រើប្រាស់ប្រព័ន្ធ SARMIS សម្រាប់ថ្នាក់មូលដ្ឋាន នៅមានកម្រិត
- ការចូលរួមផ្ទៀងបញ្ជីសារពើភណ្ឌអន្តរក្រសួងដើម្បីបំពេញនីតិវិធីនៅមានកម្រិត។

**អនុកម្មវិធី ៥.១១៖ ការអភិវឌ្ឍ និងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងការធានាគាពស័ក្តសិទ្ធនៃសេវារដ្ឋបាលអប់រំ (នាយកដ្ឋានរដ្ឋបាល)**

សកម្មភាពសរុប១៤ ក្នុងនោះ អនុវត្តចប់ ១២ ស្មើ ៨៥,៧១ភាគរយ មិនបានអនុវត្ត២ ស្មើ១៤,២៩ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៤ ក្នុងនោះសម្រេចតាមចំណុចដៅ ១ ស្មើ ២៥ភាគរយ អាចទទួលយកបាន ១ ស្មើ ២៥ ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ២ ស្មើ ៥០ភាគរយ។

***លទ្ធផលក្នុងថ្នាក់កម្រិតអនុកម្មវិធី***

- ចំនួនបុគ្គលិកអប់រំ ថ្នាក់ជាតិ ក្រោមជាតិ អង្គការជាតិ និងអន្តរជាតិ បានចូលរួមពិធីសន្និបាតអប់រំប្រចាំឆ្នាំ ចំណុចដៅ ៥០០ សម្រេចបាន ១០០ភាគរយ
- ចំនួនបុគ្គលិកអប់រំ បានចូលរួមវគ្គបំប៉នស្តីពីការគ្រប់គ្រងរដ្ឋបាល បណ្ណសារ ពិធីការអប់រំ និងប្រព័ន្ធគ្រប់គ្រងឯកសាររដ្ឋបាលចំណុចដៅ ១៦៨។

***លទ្ធផលក្នុងថ្នាក់កម្រិតចង្កោមសកម្មភាព***

- ចំនួនបុគ្គលិកអប់រំ ថ្នាក់ជាតិ ក្រោមជាតិ អង្គការជាតិ និងអន្តរជាតិ ចូលរួមពិធីសន្និបាតអប់រំប្រចាំឆ្នាំ ចំណុចដៅ ១ ៥០០ សម្រេចបាន ៥០០
- ចំនួនបុគ្គលិកអប់រំ ចូលរួមការងារសង្គមតាមប្រតិទិនការងាររបស់រាជរដ្ឋាភិបាល (បុណ្យមាឃបូជា វិសាខបូជា ច្រត់ព្រះនង្គ័ល ចូលឆ្នាំខ្មែរប្រពៃណីជាតិ ចម្រើនព្រះជន្ម ពិធីគ្រងរាជ្យសម្បត្តិ ភ្ជុំបិណ្ឌ បុណ្យអុំទូក ) ចំណុចដៅ ១ ០០០ សម្រេចបាន ៥០០
- ចំនួនបុគ្គលិកអប់រំឆ្នើមបានទទួលការបំពាក់គ្រឿងឥស្សរិយយស និងមេដាយការងារ ពីថ្នាក់ដឹកនាំក្រសួង ចំណុចដៅ ៤៧០ សម្រេចបាន ៣៩១។

**អនុកម្មវិធី ៨.១២៖ ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិលើវិស័យអប់រំ (នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍)**

សកម្មភាពសរុប ១៧ ក្នុងនោះ អនុវត្តចប់ ១៣ ស្មើ ៧៦,៤៧ភាគរយ កំពុងអនុវត្ត ២ ស្មើ ១១,៧៦ភាគរយ មិនបានអនុវត្ត ២ ស្មើ ១១,៧៦ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងអាចទទួលយកបាន ១ ស្មើ ១០០ ភាគរយ។

***លទ្ធផលក្នុងថ្នាក់កម្រិតអនុកម្មវិធី***

- ចំនួនកម្មវិធីប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ទៅសិក្សានៅបរទេស និងសកម្មភាពកិច្ចសហប្រតិបត្តិការ ជាតិ-អន្តរជាតិលើវិស័យអប់រំ និងសេវាអន្តេវាសិកដ្ឋាននិស្សិតនារី ត្រូវបានអនុវត្តចំណុចដៅ ១៥ សម្រេចបាន ១០។

***លទ្ធផលក្នុងថ្នាក់កម្រិតចង្កោមសកម្មភាព***

- ចំនួនកម្មវិធីអាហារូបករណ៍ទៅសិក្សានៅបរទេសត្រូវបានរៀបចំប្រឡងជ្រើសរើស ចំណុចដៅ ១៥លើក សម្រេចបាន ១០លើក
- ចំនួនវគ្គបំប៉នជំនាញទន់ សិក្ខាសាលា ទស្សនកិច្ចសិក្សា ការលំហែកម្សាន្តនៃនិស្សិតអាហារូបករណ៍បរទេស និងការជូនដំណើរនិស្សិតអាហារូបករណ៍ទៅបរទេស ចំណុចដៅ ១៨លើក សម្រេចបាន ១១លើក
- ចំនួន នៃការទទួលភ្ញៀវ ការរៀបចំបុណ្យជាតិ-អន្តរជាតិ ការផ្តល់មេដាយគ្រឿងឥស្សរិយយសជូនអង្គការដៃគូសប្បុរសជន និងការចុះពិនិត្យតាមដានការអនុវត្តសកម្មភាពអង្គការដៃគូនិងគ្រួសារនិស្សិតក្រីក្រ ចំណុចដៅ ២៧លើក សម្រេចបាន ១១លើក
- ចំនួននិស្សិតទទួលបានការស្នាក់នៅនិងគាំទ្រសុខភាពបឋមក្នុងមជ្ឈមណ្ឌលអន្តេវាសិកនិស្សិតនារី ចំណុចដៅ ៨១៦នាក់ សម្រេចបាន ៧៩១នាក់
- ប្រាក់វិភាគទានសមាជិកភាព និងប្រាក់អាហារូបករណ៍ប្រចាំខែដល់និស្សិតបរទេស និងនិស្សិតកម្ពុជានៅបរទេស ត្រូវបានផ្តល់តាមរបបកំណត់ ចំណុចដៅ ១០លើក សម្រេចបាន ១៣លើក។

***បញ្ហាប្រឈម***

- ការទម្លាក់ថវិកាមិនទាន់ពេលវេលាអនុវត្ត នីតិវិធីស្មុគស្មាញ
- ក្រុមការងារថ្មីអនុវត្តនីតិវិធីការងារមិនរលូន។

### អនុកម្មវិធី ៥.១៣៖ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ)

សកម្មភាពសរុប ១៨ ក្នុងនោះអនុវត្តចប់ ១៦ ស្មើ ៨៨,៨៩ភាគរយ កំពុងអនុវត្ត ១ ស្មើ ៥,៥៦ភាគរយ មិនបានអនុវត្ត ១ ស្មើ ៥,៥៦ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចតាមចំណុចដៅ ២ ស្មើ ១០០ ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- សៀវភៅស្ថិតិ និងសូចនាករអប់រំត្រូវបានផលិត និងផ្សព្វផ្សាយតាមឆ្នាំសិក្សាចំណុចដៅ ១០០ភាគរយ សម្រេចបាន ១០០ភាគរយ
- បង្កើនការប្រមូល និងផលិតស្ថិតិសូចនាករអប់រំ ចំណុចដៅ ១០០ភាគរយ សម្រេចបាន ១០០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនរាជធានី ខេត្ត ត្រូវបានពិនិត្យតាមដានលើការប្រមូលស្ថិតិ និងសូចនាករអប់រំ ចំណុចដៅ ២៥ សម្រេចបាន ១០០ភាគរយ
- ស្ថិតិ និង សូចនាករអប់រំត្រូវបានប្រើប្រាស់រួមគ្នាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំណុចដៅ ២៥រាជធានី ខេត្ត សម្រេចបាន រៀបចំផលិតសៀវភៅស្ថិតិថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត សម្រាប់សន្និបាត
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យអប់រំអនឡាញ (Online) ត្រូវបានដាក់ឱ្យប្រើប្រាស់ ចំណុចដៅ ២៥រាជធានី ខេត្ត សម្រេចបាន រាជធានី ខេត្ត បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យអប់រំសាធារណឯកជន និងមត្តេយ្យសិក្សាសហគមន៍អនឡាញ។

***បញ្ហាប្រឈម***

- ខ្វះមន្ត្រីបច្ចេកទេសផ្នែក ICT & AI ដើម្បីធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យថ្មី(EMIS, QEMIS, SDS, SRC &STS )ជំនាញផ្នែក ICT & AI មន្ត្រីក្រុមការងារផ្នែក IT & AI ព្រមទាំងកង្វះមន្ត្រីផែនការ និងស្ថិតិ

### អនុកម្មវិធី ៥.១៤៖ ការស្រាវជ្រាវ និងអភិវឌ្ឍគោលនយោបាយអប់រំ (នាយកដ្ឋានគោលនយោបាយ)

សកម្មភាពសរុប ១៦ ក្នុងនោះ អនុវត្តចប់ ៧ ស្មើ ៤៣,៧៥ភាគរយ កំពុងអនុវត្ត ៤ ស្មើ ២៥ភាគរយ មិនបានអនុវត្ត ៥ ស្មើ ៣១,២៥ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចតាមចំណុចដៅ ១ ស្មើ ៥០ភាគរយ អាចទទួលយកបាន ១ ស្មើ ៥០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ចំនួនគោលនយោបាយអប់រំ យុវជន និងកីឡា ត្រូវបានពិនិត្យតាមដាន វាយតម្លៃ និងសម្របសម្រួលការអនុវត្ត ១គោលនយោបាយ សម្រេចបាន ៥០ភាគរយ
- ចំនួនគោលនយោបាយអប់រំ យុវជន និងកីឡា ត្រូវបានរៀបចំ កែសម្រួល និងផ្សព្វផ្សាយ ១គោលនយោបាយ សម្រេចបាន ៣០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនរបាយការណ៍ស្រាវជ្រាវត្រូវបានផលិត និងផ្សព្វផ្សាយ ចំណុចដៅ ១០០ភាគរយ សម្រេចបាន ៣០ ភាគរយ
- ចំនួនសាលាមធ្យមសិក្សា ត្រូវបានគាំទ្របច្ចេកទេសដើម្បីប្រែក្លាយទៅជាសាលារៀនមានប្រសិទ្ធភាព ចំណុចដៅ ២៦សាលា សម្រេចបាន ៦០ភាគរយ
- ចំនួនបេក្ខបណ្ឌិតត្រូវបានបណ្តុះបណ្តាលចំណុចដៅ ១៣ សម្រេចបាន ១០០ភាគរយ។

***បញ្ហាប្រឈម***

- លំហូរថវិកាយឺតមិនទាន់ការអនុវត្តសកម្មភាព

- ការកំណត់ប្រធានបទស្រាវជ្រាវគោលនយោបាយយឺតធ្វើឱ្យការសិក្សាស្រាវជ្រាវខ្ជី។

**អនុកម្មវិធី ៥.១៥៖ ការអភិវឌ្ឍនិងពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ (នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ)**

សកម្មភាពសរុប ១២ ក្នុងនោះអនុវត្តចប់១០ ស្មើ ៨៣,៣៣ភាគរយ មិនបានអនុវត្ត២ ស្មើ១៦,៦៧ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចតាមចំណុចដៅ ២ ស្មើ ១០០ភាគរយ។

***លទ្ធផលក្នុងថ្នាក់កម្រិតអនុកម្មវិធី***

- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំត្រូវបានរៀបចំ ចំណុចដៅ ១០០ភាគរយ (៤ដងក្នុង១ឆ្នាំ) សម្រេចបាន ១០០ភាគរយ
- របាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាប្រចាំឆ្នាំ ចំណុចដៅ ១០០ភាគរយ សម្រេចបាន ១០០ភាគរយ។

***លទ្ធផលក្នុងថ្នាក់កម្រិតចង្កោមសកម្មភាព***

- ចំនួនរាជធានី ខេត្តដែលបានចុះពិនិត្យតាមដានការអនុវត្តគម្រោងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា ចំណុចដៅ ១៥ខេត្ត សម្រេចបាន ១៥ខេត្ត
- ចំនួនរាជធានី ខេត្ត ដែលបានវាយតម្លៃពីការរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ចំណុចដៅ ៩ខេត្ត សម្រេចបាន ១១ខេត្ត
- ចំនួនរាជធានី ខេត្ត ដែលទទួលបានការគាំទ្របច្ចេកទេសលើការរៀបចំរបាយការណ៍សមិទ្ធកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក និងសាលារៀន ចំណុចដៅ ៨ខេត្ត សម្រេចបាន ៨ខេត្ត
- ចំនួនបុគ្គលិកអប់រំ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានចូលរួមវគ្គបំប៉នសមត្ថភាពលើការរៀបចំរបាយការណ៍សមិទ្ធកម្ម ចំណុចដៅ ៥០នាក់ សម្រេចបាន ១៥០នាក់
- ចំនួនរាជធានី ខេត្ត ដែលទទួលបានការគាំទ្របច្ចេកទេសលើការរៀបចំរបាយការណ៍ សន្និបាតអប់រំ យុវជន និងកីឡា ចំណុចដៅ ៩ខេត្ត សម្រេចបាន ១២ខេត្ត
- ចំនួនបុគ្គលិកអប់រំទទួលការបំប៉នសមត្ថភាពស្តីពីក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ ថវិកាសមិទ្ធកម្ម ចំណុចដៅ ៦០នាក់ សម្រេចបាន ៦០នាក់
- ចំនួនបុគ្គលិកអប់រំទទួលបានការបំប៉នសមត្ថភាពស្តីពីប្រព័ន្ធ និងឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលអនុវិស័យអភិវឌ្ឍយុវជន និងអប់រំកាយ និងកីឡា ចំណុចដៅ ៤០នាក់ (មិនទាន់អនុវត្ត)
- ចំនួនបុគ្គលិកអប់រំថ្នាក់រាជធានី ខេត្តបានបំប៉នសមត្ថភាពស្តីពីការរៀបចំក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ថ្នាក់រាជធានី ខេត្ត ចំណុចដៅ ៧៥នាក់ (មិនទាន់អនុវត្ត)។

***បញ្ហាប្រឈម***

- ខ្វះមន្ត្រីជំនាញបច្ចេកវិទ្យាព័ត៌មាន ថវិកា និងពេលវេលា។

**អនុកម្មវិធី ៥.១៦៖ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានសម្រាប់ការងារអប់រំ យុវជន និងកីឡា (នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន)**

សកម្មភាពសរុប ១៧ ក្នុងនោះ អនុវត្តចប់ ៨ ស្មើ ៤៧,០៦ភាគរយ កំពុងអនុវត្ត ៧ ស្មើ ៤១,១៨ភាគរយ មិនបានអនុវត្ត ២ ស្មើ ១១,៧៦ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ ក្នុងនោះ អាចទទួលយកបាន ២ ស្មើ ៦៦,៦៧ភាគរយ និងសម្រេចមិនបានតាមចំណុចដៅ ១ ស្មើ ៣៣,៣៣ ភាគរយ។

***លទ្ធផលក្នុងថ្នាក់កម្រិតអនុកម្មវិធី***

- ចំនួនមាតិកាអប់រំឌីជីថល ត្រូវបានផលិតគាំទ្រដល់ការបង្រៀន និងរៀនពីចម្ងាយនិង តាមប្រព័ន្ធ អេឡិចត្រូនិក និងការផ្សព្វផ្សាយព័ត៌មានអប់រំឌីជីថលនៅលើគេហទំព័រធនធានអប់រំ និងបណ្តាញសង្គម ផ្លូវការក្រសួងអប់រំ យុវជន និងកីឡា ឱ្យកាន់តែសម្បូរបែប ចំនុចដៅ ២៥០ មាតិកា សម្រេចបាន ១៤៩ មាតិកា

- ចំនួនសាលារៀនដែលបានតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការផ្គត់ផ្គង់សម្ភារបច្ចេកទេសព័ត៌មានវិទ្យា និងការកសាងប្រព័ន្ធគ្រប់គ្រងមាតិកាអប់រំ សម្រាប់គាំទ្រការបង្រៀននៅកម្រិតបឋម និងមធ្យមសិក្សា ក្នុងបរិបទថ្មីឱ្យកាន់តែទូលំទូលាយចំនុចដៅ ៥០ សម្រេចបាន ២៥
- ចំនួនបុគ្គលិកអប់រំ និងគ្រូបង្រៀន ទទួលបានការអភិវឌ្ឍសមត្ថភាពបំណិនបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការងារ គ្រប់គ្រងអប់រំ ការបង្រៀនរៀន ទាំងក្នុង-ក្រៅប្រទេស តាមរយៈការសិក្សាតាមប្រព័ន្ធអេឡិចត្រូចនិក និងតាម បែបចម្រុះ ចំនុចដៅ ១ ០០០ សម្រេចបាន ៣០០។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនមាតិកាអប់រំឌីជីថល ត្រូវបានផលិតគាំទ្រដល់ការបង្រៀន និងរៀនពីចម្ងាយនិងតាមប្រព័ន្ធអេឡិចត្រូនិក និងការផ្សព្វផ្សាយព័ត៌មានអប់រំឌីជីថលនៅលើគេហទំព័រធនធានអប់រំ និងបណ្តាញសង្គមផ្លូវការក្រសួងអប់រំ យុវជន និងកីឡា ឱ្យកាន់តែសម្បូរបែប ចំណុចដៅ ២៥០មាតិកា សម្រេចបាន ១៥០មាតិកា
- ចំនួនសាលារៀនដែលបានតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការផ្គត់ផ្គង់សម្ភារបច្ចេកទេសព័ត៌មានវិទ្យា និងការកសាងប្រព័ន្ធគ្រប់គ្រងមាតិកាអប់រំ សម្រាប់គាំទ្រការបង្រៀននៅកម្រិតបឋម និងមធ្យមសិក្សាក្នុងបរិបទថ្មីឱ្យកាន់តែទូលំទូលាយ ចំណុចដៅ ៥០ សម្រេចបាន ២៥
- ចំនួនបុគ្គលិកអប់រំ និងគ្រូបង្រៀន ទទួលបានការអភិវឌ្ឍសមត្ថភាព បំណិនបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការងារគ្រប់គ្រងអប់រំ ការបង្រៀន-រៀន ទាំងក្នុង-ក្រៅប្រទេស តាមរយៈការសិក្សាតាមប្រព័ន្ធអេឡិចត្រូចនិក និងតាមបែបចម្រុះ ចំណុចដៅ ១ ០០០ សម្រេចបាន ៣០០។

**អនុកម្មវិធី ៩.១៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពការងារប្រឡងនៅមធ្យមសិក្សានិងអប់រំបច្ចេកទេស(នាយកដ្ឋានកិច្ចការប្រឡង)**

សកម្មភាពសរុប ២៣ ក្នុងនោះ អនុវត្តចប់ ២១ ស្មើ ៩១,៣០ភាគរយ មិនបានអនុវត្ត ២ ស្មើ ៨,៧០ភាគរយ។ សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងនោះសម្រេចតាមចំណុចដៅ ១ ស្មើ ១០០ភាគរយ។

***លទ្ធផលក្នុងឆ្នាំកម្រិតអនុកម្មវិធី***

- ចំនួនបុគ្គលិកអប់រំ ទទួលបានការបំប៉នសមត្ថភាពស្តីពីការធ្វើអក្សរសម្ងាត់ និងចូលរួមសិក្ខាសាលា ស្តីពីតួនាទី និងភារកិច្ចជំនួយការនិងអប្បមាទទូទាំងប្រទេសសម្រាប់ដំណើរការប្រឡងសញ្ញាបត្រមធ្យម សិក្សាទុតិយភូមិចំណុចដៅ ៣ ៧០៧នាក់ សម្រេចបាន ៣ ៧០៧នាក់។

***លទ្ធផលក្នុងឆ្នាំកម្រិតចង្កោមសកម្មភាព***

- ចំនួនសិស្សចូលរួមការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចំណុចដៅ ១៤៨ ៦៦៦ សម្រេចបាន ១៤៨ ៦៦៦
- ចំនួនសិស្សចូលរួមការប្រឡងសិស្សពូកែគណិតវិទ្យា រូបវិទ្យា និងភាសាខ្មែរ និងសិស្សពូកែអូឡាំព្យាដក្នុងប្រទេស ចំណុចដៅ ៤៨ សម្រេចបាន ៤៨០
- ចំនួនសិស្សទទួលបានការបំប៉ន និងការបញ្ជូនសិស្សពូកែអូឡាំព្យាដ ទៅចូលរួមនៅក្រៅប្រទេស ចំណុចដៅ ៤០ សម្រេចបាន ២០
- ចំនួនសិក្ខាកាមទទួលបានការបំប៉នសមត្ថភាពលើការធ្វើបច្ចុប្បន្នភាពលើកម្មវិធីចុះឈ្មោះសិស្ស គ្រូដោយប្រើប្រាស់ កុំព្យូទ័រសម្រាប់ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចំណុចដៅ ៧២០ សម្រេចបាន ៧២០។

***បញ្ហាប្រឈម***

- ខ្វះថវិកាអនុវត្តសកម្មភាព។

អនុកម្មវិធី ៥.១៨៖ ការងារមជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេស

*លទ្ធផលក្នុងឆ្នាំកម្រិតបង្គោលសកម្មភាព*

- ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ចំណុចដៅ ១០០ភាគរយ សម្រេចបាន ១០០ភាគរយ។

## ៥. សេចក្តីសន្និដ្ឋាន

ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តនូវមុខងារ ភារកិច្ច និងតួនាទីរបស់អង្គភាពដែលអនុវត្តថវិកាថ្នាក់ជាតិ ប្រកបដោយការទទួលខុសត្រូវខ្ពស់ សំដៅជានាឱ្យទទួលបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងផលសម្រេចបានស្របតាម គោលនយោបាយកំណែទម្រង់អាទិភាពថវិកាសមិទ្ធកម្ម និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ សមិទ្ធកម្មនៃការអនុវត្ត ផែនការប្រតិបត្តិប្រចាំប្រចាំឆ្នាំ២០២៣ ពិតជាបានបង្ហាញពីការខិតខំរបស់អង្គភាពនៅកម្រិតថ្នាក់ជាតិក្នុងភាពជាម្ចាស់ក្នុងការអភិវឌ្ឍក្របខណ្ឌការងារ ក្របខណ្ឌច្បាប់ ឯកសារគតិយុត្តសម្រាប់ការគាំទ្រ និងការបង្កើតកម្មវិធីឬគម្រោងនានា ដើម្បីអភិវឌ្ឍសមត្ថភាពនៃការអនុវត្តសកម្មភាពដែលបានគ្រោងទុកក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ និងការងារពិនិត្យតាមដាន និងវាយតម្លៃនៅកម្រិតមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងសាលារៀនផងដែរ។

ថ្ងៃទី អង្គារ ២រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

| ឧបសម្ព័ន្ធ ៖ វឌ្ឍនភាព សូចនាករហិរញ្ញវត្ថុ សូចនាករសមិទ្ធកម្ម (តាមជានការអនុវត្ត កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| គោលបំណងគោលនយោបាយ | គ.ប.ទី១៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយ សមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា។<br>គ.ប.ទី២៖ ពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ | | | | | | | | |
| ឥណទានថវិការបស់ក្រសួង | លានរៀល | | | | | | | | |
| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆ្នាំ | % ចំណាយ | គោលដៅ ប្រចាំឆ្នាំ | អនុវត្ត ប្រចាំឆ្នាំ | %នៃ គោលដៅ | ស្ថានភាព | | |
| **សរុបចំណាយថវិកាកម្មវិធី** | 377,478,600.0 | 293,347,858.7 | 77.71% | | | | | | |
| **កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធក្រៅប្រព័ន្ធ និងមិនផ្លូវការ** | 62,890,800.0 | 58,693,852.4 | 93.33% | | | | | | |
| សូចនាករលទ្ធផលចុងក្រោយ១.១៖ អត្រាចូលរៀនកុមារអាយុ៥ឆ្នាំគ្រប់រូបភាព(មត្តេយ្យសិក្សារដ្ឋ សហគមន៍ និងឯកជន) | | | | 63.1% | 64.8% | 102.7% | ↑ | | |
| សូចនាករលទ្ធផលចុងក្រោយ១.២៖ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | | | | 87.5% | 86.8% | 99.2% | → | | |
| សូចនាករលទ្ធផលចុងក្រោយ១.៣៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | 53.1% | 55.7% | 104.9% | ↑ | សូចនាករ សមិទ្ធកម្ម EMIS ផលិតបាននៅដើមខែកុម្ភៈ ២០២៤ | |

| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆ្នាំ | % ចំណាយ | គោលដៅ ប្រចាំឆ្នាំ | អនុវត្ត ប្រចាំឆ្នាំ | %នៃ គោលដៅ | ស្ថានភាព | | |
| សូចនាករលទ្ធផលចុងក្រោយ១.៤៖ អត្រាអក្ខរកម្មពេញវ័យ (អាយុ១៥ ឆ្នាំឡើង) | | | | 90.7% | 84.7% | 93% | → | លទ្ធផលឆ្នាំ២០២១ ចេញដោយក្រសួងផែនការ | |
| **អនុកម្មវិធី១.១៖ ការពង្រីកការអប់រំកុមារតូច (នាយកដ្ឋានអប់រំកុមារតូច)** | 12,799.5 | 12799.5 | 100% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.ក៖ អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ នៅមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងឯកជន | | | | 63.1% | 64.8% | 102.7% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.ខ៖ អត្រារួមនៃការសិក្សានៅ មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងមត្តេយ្យសិក្សាឯកជន | | | | 37.4% | 37.1% | 99.2% | ↑ | | |
| **ចង្កោមសកម្មភាពទី១.១.១៖ ការគាំពារនិងការអភិវឌ្ឍកុមារតូច** | 12,475.0 | 12,475.0 | 100% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.១.ក៖ ចំនួនមត្តេយ្យសិក្សាសហគមន៍ ដែលមានលក្ខណៈស្តង់ដា | | | | 1350 | 1305 | 96.7% | → | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.១.ខ៖ ចំនួនមត្តេយ្យសិក្សាបើកថ្មីនៅ ក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ | | | | 378 | 0 | 0 | ↓ | | មិនទាន់អនុវត្ត |
| **ចង្កោមសកម្មភាពទី១.១.២៖ អភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រី អនុវិស័យអប់រំកុមារតូច** | 324.5 | 324.5 | 100% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.២.ក៖ ចំនួនសាលាមត្តេយ្យសិក្សា ធនធាន សម្រេចបានតាមលក្ខណៈស្តង់ដា | | | | 4 | 10 | 250 | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.២.ខ៖ ចំនួនសាលាមត្តេយ្យសិក្សារដ្ឋ បានអនុវត្តការគ្រប់គ្រងសាលារៀនសម្រាប់មត្តេយ្យសិក្សា | | | | 213 | 213 | 100.0% | ↑ | | |

| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆ្នាំ | % ចំណាយ | គោលដៅ ប្រចាំឆ្នាំ | អនុវត្ត ប្រចាំឆ្នាំ | %នៃ គោលដៅ | ស្ថានភាព | | |
| **អនុកម្មវិធី១.២៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា (នាយកដ្ឋានអប់រំបឋមសិក្សា)** | 1,938.3 | 1681.0 | 86.7% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.ក អត្រាពិតនៃការសិក្សា | | | | 93% | 93% | 100.0% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.ខ អត្រាត្រួតថ្នាក់ | | | | 5% | 7% | 71.4% | → | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.គ អត្រាបោះបង់ការសិក្សា | | | | 6.2% | 7% | 88.6% | → | | |
| **ចង្កោមសកម្មភាពទី១.២.១៖ ការអភិវឌ្ឍការអប់រំបឋមសិក្សា ដើម្បីធានាឱ្យការចូលរៀនមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន** | **1,392.3** | **1304.3** | **93.7%** | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.១.ក ៖ ចំនួនបុគ្គលិកអប់រំបឋមសិក្សាទទួលការបំប៉នសមត្ថភាពបន្ថែមលើវិធីសាស្ត្ររៀននិងបង្រៀន | | | | 10,000 | 9,875 | 98.75% | → | | |
| **ចង្កោមសកម្មភាពទី១.២.២៖ ការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំបឋមសិក្សា** | **546.0** | **376.7** | **69%** | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.២.ក៖ ចំនួនមន្ត្រីអប់រំបឋមសិក្សាបានទទួលការបំប៉នសមត្ថភាពលើការគាំទ្រការគ្រប់គ្រងតាមសាលារៀន | | | | 500 | 650 | 130.0% | ↑ | | |
| **អនុកម្មវិធី១.៣៖ ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ)** | **6,613.5** | **0.0** | **0.0%** | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ក៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | 70.4% | 64.8% | 92.0% | → | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ខ៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | | | | 38.6% | 44.2% | 114.5% | ↑ | | |

| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆ្នាំ | % ចំណាយ | គោលដៅប្រចាំឆ្នាំ | អនុវត្តប្រចាំឆ្នាំ | %នៃគោលដៅ | ស្ថានភាព | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.គ៖ អត្រាឆ្លងកូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិ | | | | 84.7% | 83.7% | 98.8% | → | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ឃ៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | 53.1% | 55.7% | 104.9% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ង៖ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | 14.1% | 17.2% | 122.0% | ↓ | | |
| **ចង្កោមសកម្មភាពទី១.៣.១៖ បង្កើនការចូលរៀននៅមធ្យមសិក្សា និងជួយសិស្សរៀនមានសមត្ថភាពបញ្ញាល្អប្រសើរ និងរៀនចប់នៅមធ្យមសិក្សា** | 863.5 | - | - | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.១.ក៖ ចំនួនភ្នាក់ងារផ្លាស់ប្តូរនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើកម្មវិធីការគ្រប់គ្រងតាមសាលារៀន | | | | 450នាក់ | - | - | ↓ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.១.ខ៖ ភាគរយបេក្ខជនប្រឡងជាប់សញ្ញាបត្រថ្នាក់ពីរភាសា បារាំង-ខ្មែរ | | | | បឋមភូមិ ៧៦,២% | 75.60% | 99.30% | → | | |
| | | | | ទុតិយភូមិ ៨១,១% | 68% | 83.90% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.១.គ៖ ចំនួនសាលារៀនបានចុះជួយ (ពិនិត្យតាមដាន និងវាយតម្លៃ) | | | | 150 | 180 | 120.0% | ↑ | | |
| **ចង្កោមសកម្មភាពទី១.៣.២៖ ការលើកកម្ពស់ការងារគ្រប់គ្រងថ្នាក់ជាតិ និងក្រោមជាតិ** | 5,750.0 | - | - | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.២.ក៖ ចំនួនសាលារៀនជំនាន់ថ្មី | | | | ៧ សាលា | ៧ សាលា | 100.0% | ↑ | | |

| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆ្នាំ | % ចំណាយ | គោលដៅ ប្រចាំឆ្នាំ | អនុវត្ត ប្រចាំឆ្នាំ | %នៃ គោលដៅ | ស្ថានភាព | | |
| **អនុកម្មវិធី១.៤៖ ការពង្រីកការអប់រំក្រៅប្រព័ន្ធ (នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ)** | 2,149.0 | 1835.1 | 85.4% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.ក៖ ប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | | | | 15700 | 15500 | 98.73% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.ខ៖ សិស្សបានបញ្ចប់ថ្នាក់កម្មវិធីសមមូល | | | | 3300 | 3100 | 93.94% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.គ៖ ចំនួនកុមារបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញនិងបានបញ្ជូនទៅក្នុងប្រព័ន្ធ | | | | 3244 | 2000 | 61.65% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.ឃ៖ ចំនួនអ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាល ជំនាញមុខរបរសម្រាប់ការសិក្សាពេញមួយជីវិត (ម.ស.ស) | | | | 8690 | 9500 | 109% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.ង៖ ចំនួនមន្ត្រីអកបទទួលការបណ្តុះបណ្តាលសមត្ថភាពការគ្រប់គ្រងលើសេវាអកប | | | | 130 | 60 | 46.15% | ↓ | | |
| **ចង្កោមសកម្មភាពទី១.៤.១៖ ការអភិវឌ្ឍការអប់រំក្រៅប្រព័ន្ធ** | 1,779.9 | 1680.0 | 94.4% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ក៖ ចំនួនកម្មករ-កម្មការិនីដែលបានបញ្ចប់ថ្នាក់អក្ខរកម្មនៅតាមរោងចក្រសហគ្រាស | | | | 400 នាក់ | 450 នាក់ | 113% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ខ៖ ចំនួនអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់អក្ខរកម្មនៅតាមសហគមន៍ ពន្ធធនាគារ និងមណ្ឌលកែប្រែ | | | | 15 300 នាក់ | 15 000 នាក់ | 98.00% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.គ៖ ចំនួនអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់សមមូលបឋមសិក្សា | | | | 3 000 នាក់ | 2 900 នាក់ | 96.66% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ឃ៖ ចំនួនអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់សមមូលមធ្យមសិក្សា | | | | 300 នាក់ | 200 នាក់ | 66.66% | ↑ | | |

| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆ្នាំ | % ចំណាយ | គោលដៅ ប្រចាំឆ្នាំ | អនុវត្ត ប្រចាំឆ្នាំ | %នៃ គោលដៅ | ស្ថានភាព | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ង៖ ចំនួនកុមារដែលបានបញ្ជូនចូលរៀនសាលាចំណេះទូទៅក្នុងប្រព័ន្ធ | | | | 3 244 នាក់ | 2 000 នាក់ | 62.00% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ច៖ ចំនួនអ្នកសិក្សាដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញមុខរបរងាយៗ | | | | 8 690 នាក់ | 9 500 | 109% | ↑ | | |
| **ចង្កោមសកម្មភាពទី១.៤.២៖ អភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់** | 369.1 | 155.1 | 42.0% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.២.ក៖ ចំនួនមន្ត្រីអប់រំក្រៅប្រព័ន្ធទទួលការបណ្តុះបណ្តាលលើការធ្វើផែនការ និងការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ | | | | 130 នាក់ | 250 នាក់ | 192.00% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.២.ខ៖ ចំនួនស្រុកដែលអនុវត្តបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ | | | | 130 ក្រុងស្រុក | 60 | 46.15% | ↓ | | |
| **អនុកម្មវិធី១.៥៖ ការពង្រឹងនិងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា (នាយកដ្ឋានសុខភាពសិក្សា)** | **1,152.0** | **574.7** | **49.9%** | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ក៖ ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ១ (ចំណាត់ថ្នាក់ផ្កាយ ១) | | | | 36.1% | 32.15% | 89.06% | → | EMIS 22-23 | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ខ៖ ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាត<br>និងអនាម័យកម្រិត ២ (ចំណាត់ថ្នាក់ផ្កាយ ២) | | | | 41.4% | 45.18% | 109% | ↑ | EMIS 22-23 | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.គ៖ ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ៣ (ចំណាត់ថ្នាក់ផ្កាយ៣) | | | | 4.8% | 6.27% | 131% | ↑ | EMIS 22-23 | |

| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆ្នាំ | % ចំណាយ | គោលដៅ ប្រចាំឆ្នាំ | អនុវត្ត ប្រចាំឆ្នាំ | %នៃ គោលដៅ | ស្ថានភាព | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ឃ៖ ភាគរយសាលារៀនមានបង្គន់អនាម័យ | | | | 80.8% | 99.90% | 124% | ↑ | EMIS 22-23 | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ង៖ ភាគរយសាលារៀនមានទឹកស្អាត | | | | 79.9% | 83.10% | 104% | ↑ | EMIS 22-23 | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ច៖ ភាគរយសាលារៀនមានកន្លែងលាងសម្អាតដៃ | | | | 81.8% | 85.60% | 105% | ↑ | EMIS 22-23 | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ឆ៖ ភាគរយសាលារៀនមានប្រអប់សង្គ្រោះបឋម | | | | 43.0% | 56.10% | 130% | ↑ | EMIS 22-23 | |
| **ចង្កោមសកម្មភាពទី១.៥.១៖ ការលើកកម្ពស់សុខភាពសិក្សា** | 739.5 | 200.7 | 27.1% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.ក៖ ចំនួនគរុសិស្ស គរុនិស្សិត មន្ត្រីតែងតាំងស៊ីប និងនិស្សិតជាប់អាហារូបករណ៍បានពិនិត្យសុខភាព និងកាយសម្បទា | | | | 600 នាក់ | 885 នាក់ | 147.5% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.ខ៖ ចំនួនគ្រឹះស្ថានសិក្សាចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីលើកកម្ពស់សុខភាពសិក្សា | | | | 10 រាជធានី ខេត្ត | 13 រាជធានី ខេត្ត | 130.0% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.គ៖ ចំនួនមន្ត្រីបានចូលរួម សិក្ខាសាលា វគ្គបណ្តុះបណ្តាល វគ្គបំប៉ន និងកិច្ចប្រជុំ ក្នុងនិងក្រៅប្រទេស | | | | 700 នាក់ | 290 នាក់ | 41.4% | ↓ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.ឃ៖ ចំនួនសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព (ស.ភ.សិស្ស និងស.ភ.គ្រូ) បានបោះពុម្ពតាមកម្រិតថ្នាក់ | | | | 1 360 000 ក្បាល | 284 699 ក្បាល | 29.9% | ↓ | ខ្វះថវិកាអនុវត្ត | បង្កើនថវិកាបោះពុម្ព |
| **ចង្កោមសកម្មភាពទី១.៥.២៖ អភិវឌ្ឍស្ថាប័ននិងសមត្ថភាពមន្ត្រីសុខភាពសិក្សាគ្រប់លំដាប់ថ្នាក់** | 412.5 | 374.0 | 90.7% | | | | | | |

| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆ្នាំ | % ចំណាយ | គោលដៅ ប្រចាំឆ្នាំ | អនុវត្ត ប្រចាំឆ្នាំ | %នៃ គោលដៅ | ស្ថានភាព | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.២.កៈ ចំនួនមន្ត្រីសុខភាពសិក្សាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានចូលរួមការអប់រំផ្សព្វផ្សាយអំពីការលើកកម្ពស់សុខភាពសិក្សា | | | | 500 នាក់ | 2372 នាក់ | 264.0% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.២.ខៈ ចំនួនសិស្សានុសិស្សនៅតាមគ្រឹះស្ថានសិក្សា បានចូលរួមការអប់រំផ្សព្វផ្សាយការអប់រំសុខភាព និងប្រធានបទសុខភាពសាធារណៈ | | | | 2000 នាក់ | 3687 នាក់ | 184.4% | ↑ | | |
| **អនុកម្មវិធី១.៦៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស (នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ)** | **2,442.3** | **1860.0** | **76.2%** | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.កៈ ចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស | | | | 19សាលា | 19សាលា | 100% | ↑ | | |
| **ចង្កោមសកម្មភាពទី១.៦.១៖ អភិវឌ្ឍការបណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត អប់រំតម្រង់ទិសវិជ្ជាជីវៈ និងប្រឹក្សាអាជីព** | 2,416.8 | 1,860.0 | 77.0% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.១.កៈ ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស | | | | 4 324 នាក់ | 3 033 នាក់ | 70.1% | → | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.១.ខៈ ចំនួនសាលារៀនអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន | | | | 190 សាលា | 678 សាលា | 100% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.១.គៈ ចំនួនគ្រឹះស្ថានមធ្យមសិក្សាទទួលបានការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ឯកសារណែនាំស្តីពីការជ្រើសរើសប្រភេទថ្នាក់វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម ឬជំនាញបច្ចេកទេសវិជ្ជាជីវៈ | | | | 98សាលា | 98សាលា | 100% | ↑ | | |

| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆ្នាំ | % ចំណាយ | គោលដៅ ប្រចាំឆ្នាំ | អនុវត្ត ប្រចាំឆ្នាំ | %នៃ គោលដៅ | ស្ថានភាព | | |
| **ចង្កោមសកម្មភាពទី១.៦.២៖ ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ** | 25.5 | 0.0 | 0.0% | | | | | | |
| **អនុកម្មវិធី១.៧៖ ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ)** | **8,139.5** | **2,138.5** | **26.3%** | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.ក៖ ចំនួនគរុសិស្ស គរុនិស្សិតបានទទួលការបណ្តុះបណ្តាល នៅសាលាគរុកោសល្យ | | | | 3 000 នាក់ | 3 000 នាក់ | 100% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.ខ៖ ចំនួនមន្ត្រីគ្រប់គ្រងអប់រំ និងនាយកនាយករង គ្រូបង្រៀន បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅបានទទួលការលើកកម្ពស់សមត្ថភាព | | | | 351នាក់ | 351នាក់ | 100% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.គ៖ ចំនួនគ្រូបឋមសិក្សា និងមត្តេយ្យសិក្សាបានតំឡើង គុណវុឌ្ឍិទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន | | | | 1 500នាក់ | 0នាក់ | 0.00% | ↓ | | |
| **ចង្កោមសកម្មភាពទី១.៧.១៖ ជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀន** | 7,345.5 | 1,344.5 | 18.3% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.១.ក៖ ចំនួនគរុសិស្ស គរុនិស្សិតត្រូវបានជ្រើសរើសតាមប្រព័ន្ធ ១២+២ និង ១២+៤ និងទទួលការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | | | | ៣ 000 នាក់ | ៣ 000 នាក់ | 100.0% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នា ១.៧.១.ខ៖ ចនួនឯកសារបោះពុម្ពសម្រាប់វគ្គវក្រឹតការដំឡើងគុណវុឌ្ឍិគ្រូបឋមសិក្សា និងមត្តេយ្យសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន | | | | 7 630 ក្បាល | 7 630 ក្បាល | 100% | ↑ | | |

| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆ្នាំ | % ចំណាយ | គោលដៅ ប្រចាំឆ្នាំ | អនុវត្ត ប្រចាំឆ្នាំ | %នៃ គោលដៅ | ស្ថានភាព | | |
| **ចង្កោមសកម្មភាពទី១.៧.២៖ លើកកម្ពស់សមត្ថភាពវិជ្ជាជីវៈ និងគុណវុឌ្ឍិ គណៈគ្រប់គ្រង គ្រូឧទ្ទេស និងគ្រូបង្រៀន** | 794.0 | 794.0 | 100% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.២.ក៖ ចំនួននាយកសាលារៀនចំណេះទូទៅបានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន | | | | 40 នាក់ | 54 នាក់ | 135% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.២.ខ៖ ចំនួនមន្ត្រីអប់រំ គ្រូឧទ្ទេស និងគ្រូបង្រៀនទទួលបានការលើកកម្ពស់សមត្ថភាព | | | | 311 នាក់ | 311 នាក់ | 100% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.២.គ៖ ចំនួនគ្រូបឋមសិក្សានិងមត្តេយ្យសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចូលរួមវគ្គវិក្រឹតការដើម្បីដំឡើងគុណវុឌ្ឍិទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន | | | | 1 500 នាក់ | 0 នាក់ | 0% | ↓ | | បើកវគ្គបបន មិនទាន់បាន ដោយសារពេលវេលា |
| **អនុកម្មវិធី១.៨៖ ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារៈសិក្សា និងបណ្ណាល័យ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា)** | **27,279.7** | **26,565.0** | **97.4%** | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៨.ក៖ ចំនួនសៀវភៅសិក្សាគោលត្រូវបានផ្គត់ផ្គង់សម្រាប់សិស្សថ្នាក់ទី១ដល់ទី១២ | | | | ៥ ២៧៦ 000 ច្បាប់ | ៥ ៣៥៣ 000 ច្បាប់ | 101.5% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៨.ខ៖ ចំនួនសិស្សចូលរួមប្រកួតតែងនិពន្ធ សូត្រកំណាព្យនិងសម្តែងសិល្បៈក្នុងទិវាជាតិអំណាន ១១មីនា | | | | ៧៥ នាក់ | ៧៥ នាក់ | 100% | ↑ | | |
| **ចង្កោមសកម្មភាពទី១.៨.១៖ អភិវឌ្ឍ ផ្សព្វផ្សាយ និងពិនិត្យតាមដានកម្មវិធីសិក្សា សម្ភារសិក្សា ឯកសារគរុកោសល្យ និងការងារបណ្ណាល័យ** | 27,256.9 | 26,565.0 | 97.5% | | | | | | |

| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆ្នាំ | % ចំណាយ | គោលដៅ ប្រចាំឆ្នាំ | អនុវត្ត ប្រចាំឆ្នាំ | %នៃ គោលដៅ | ស្ថានភាព | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៨.១.ក៖ ចំនួនសៀវភៅសិក្សាគោល ដែលសិស្សទទួលបានតាមផលធៀប១:១ សម្រាប់ថ្នាក់ទី១-៩ និង២:១ សម្រាប់មធ្យមសិក្សាទុតិយភូមិសម្រាប់ថ្នាក់ទី១០-ទី១២ | | | | ៥ ២៧៦ ០០០ ច្បាប់ | ៥ ៣៥៣ ០០០ ច្បាប់ | 101.5% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៨.១.ខ៖ចំនួនសាលារៀនទទួលបានពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីសិក្សានិងផ្សព្វផ្សាយ | | | | 100 | 167 | 167.0% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៨.១.គ៖ ចំនួនឯកសារគរុកោសល្យនិងកម្មវិធីសិក្សា | | | | ២ ចំណងជើង | ២ ចំណងជើង | 80% | → | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៨.១.ឃ៖ ចំនួនសិស្សចូលរួមប្រកួតតែងនិពន្ធ សូត្រកំណាព្យ និងសម្តែងសិល្បៈក្នុងទិវាជាតិអំណាន ១១មីនា | | | | ៧៥ នាក់ | ៧៥ នាក់ | 100% | ↑ | | |
| **ចង្កោមសកម្មភាពទី១.៨.២៖ អភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រី ស្តីពីការអភិវឌ្ឍកម្មវិធីសិក្សា ឯកសារគរុកោសល្យ** | 22.8 | 0.0 | 0.0% | | | | | | |
| **អនុកម្មវិធី១.៩៖ ពង្រីកការអប់រំបរិយាបន្នគ្រប់កម្រិតសិក្សា (នាយកដ្ឋានអប់រំពិសេស)** | **571.1** | – | – | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.ក៖ ចំនួនគ្រូបង្រៀនថ្នាក់អប់រំពហុភាសាសម្រាប់បឋមសិក្សា | | | | 242 | 235 | 97.1% | → | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.ខ៖ ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធ បានកសាងសមត្ថភាពស្តីពីការអប់រំបរិយាបន្ន និងអប់រំពិសេស | | | | 120 | 224 | 186.7% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.គ៖ ចំនួនសិស្សមានពិការភាព(គ ថ្លង់ ពិការភ្នែក និងសតិបញ្ញា...) ដែលបានរៀននៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្ម | | | | 1003 | 1059 | 105.6% | ↑ | | |

| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆ្នាំ | % ចំណាយ | គោលដៅ ប្រចាំឆ្នាំ | អនុវត្ត ប្រចាំឆ្នាំ | %នៃ គោលដៅ | ស្ថានភាព | | |
| **ចង្កោមសកម្មភាពទី១.៩.១៖ លើកកម្ពស់ និងអភិវឌ្ឍការអប់រំបរិយាបន្នគ្រប់ភូមិសិក្សា** | 278.3 | _ | _ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.១.ក៖ ចំនួនសៀវភៅសិក្សាអប់រំពហុភាសាត្រូវបានបោះពុម្ពសម្រាប់បឋមសិក្សា | | | | ៤ ០០០ ក្បាល | 0 | 0% | ↓ | | |
| **ចង្កោមសកម្មភាពទី១.៩.២៖ លើកកម្ពស់សមត្ថភាពមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់លើការអប់រំបរិយាបន្ន** | 292.8 | _ | _ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.២.ក៖ ចំនួនគ្រូ និងអ្នកពាក់ពន្ធ័អប់រំពហុភាសាត្រូវបានទទួលវគ្គបំប៉នសមត្ថភាពស្តីពីការអប់រំពហុភាសា | | | | 30នាក់ | 34នាក់ | 100% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.២.ខ៖ ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធត្រូវបានកសាង សមត្ថភាពស្តីពីការអប់រំបរិយាបន្ន និងអប់រំពិសេស | | | | 120 នាក់ | 120 នាក់ | 100% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.២.គ៖ ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធត្រូវបានបណ្តុះបណ្តាលជំនាញអប់រំពិសេស ស្តីពីការអប់រំពិសេស សម្រាប់បង្រៀននៅវិទ្យាល័យអប់រំពិសេស | | | | 20 | 23 | 115.0% | ↑ | | |
| **១.១០ សេវាគាំទ្រការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការរបស់មន្ទីរជំនាញរាជធានី ខេត្ត** | **244,493.1** | | | គាំទ្រ និងសម្រេចឱ្យបានចំណុចដៅរបស់ថ្នាក់ជាតិ លើការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ | | | | | |
| **កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ** | 33,348,900.0 | 28,600,191.5 | 85.76% | | | | | | |

| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆ្នាំ | % ចំណាយ | គោលដៅ ប្រចាំឆ្នាំ | អនុវត្ត ប្រចាំឆ្នាំ | %នៃ គោលដៅ | ស្ថានភាព | | |
| សូចនាករលទ្ធផលចុងក្រោយ ២.១ ៖អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២) | | | | 15.7% | 15.0% | 95.5% | → | ស្ថិតិនេះបានមកពីការបូកសរុបទិន្នន័យដែល ទទួលបានពីគ្រឹះស្ថាន ឧត្តមសិក្សាចំនួន១០៦ (ជាគ្រឹះស្ថាននៅក្រោមឱវាទក្រសួងអប់រំ) ត្រឹមខែធ្នូ ឆ្នាំ ២០២៣ | |
| សូចនាករលទ្ធផលចុងក្រោយ ២.២ ៖ភាគរយនិស្សិតចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលស្នែម | | | | 33.2% | 31.5% | 94.9% | ↓ | ស្ថិតិនេះបានមកពីការបូកសរុបទិន្នន័យដែល ទទួលបានពីគ្រឹះស្ថាន ឧត្តមសិក្សាចំនួន១០៦ (ជាគ្រឹះស្ថាននៅក្រោមឱវាទក្រសួងអប់រំ) ត្រឹមខែធ្នូ ឆ្នាំ ២០២៣ | |

| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆ្នាំ | % ចំណាយ | គោលដៅ ប្រចាំឆ្នាំ | អនុវត្ត ប្រចាំឆ្នាំ | %នៃ គោលដៅ | ស្ថានភាព | | |
| **អនុកម្មវិធី២.១៖ ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា(នាយកដ្ឋានឧត្តមសិក្សា)** | 7,503.2 | 4,194.9 | 55.9% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.ក ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង | | | | 25 | 33 | 132.0% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.ខ ៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានរៀបចំនិងអនុវត្តការតេរ៉ារបស់និស្សិត | | | | 16 | 24 | 150.0% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.គ ៖ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានធ្វើការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់សិក្សា | | | | 10 | 22 | 220% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.ឃ៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងទិន្នន័យឧត្តមសិក្សា | | | | 33 | 49 | 148.5% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.ង៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានអនុវត្តកម្មវិធី<br>បណ្ដាញសាកលវិទ្យាល័យសាយប័រ | | | | 6 | 6 | 100.0% | ↑ | | |
| **ចង្កោមសកម្មភាពទី២.១.១៖ ជំរុញសេវាអប់រំប្រកបដោយសមធម៌ បរិយាបន្ន ប្រសិទ្ធភាព និងការពិនិត្យតាមដាន** | 2,199.2 | 1824.4 | 83.0% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.១.ក៖ ចំនួនកម្មវិធីសិក្សាតាមមុខជំនាញដែលបានកែលម្អដោយផ្ដោតលើលទ្ធផលរំពឹងទុកស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ | | | | 120 | 130 | 108.3% | ↑ | | |

